00936756 E1/218.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jul-2013, 09:15
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី២០៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វ៉ែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក សំ សុគង

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ស៊ុម អាឡាត់ (TCW-689) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការបន្តសួរសំណួរទៅសាក្សី៖ លោក ស៊ុម អាឡាត់** (TCW-689)


សួរបន្តដោយលោក វីល្លៀម ស្មីត ផ្ដើមពី៖ ........ ទំព័រ ២
សួរដោយលោកស្រី ជេត វណ្ណលី ផ្ដើមពី៖ ........ ទំព័រ ៣៤
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី៖ ........ ទំព័រ ៤១
សួរដោយលោក សុន អរុណ ផ្ដើមពី៖ ........ ទំព័រ ៤៦
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី៖ ........ ទំព័រ ៥២
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី៖ ........ ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ុម អាឡាត់។

ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមការបញ្ជាក់ពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែលអង្គជំនុំជម្រះបានសាកសួរពីម្សិលមិញ ដើម្បីអង្គជំនុំជម្រះមានលទ្ធភាពក្នុងការរៀបចំនូវកាលវិភាគសម្រាប់ធ្វើសវនាការនៅសប្តាហ៍ក្រោយ និងការប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព។ តើអាចបញ្ជាក់បានទេ?

**លោក អាកឡូរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំបានផ្តល់ដំណឹងជូនទៅក្រឡាបញ្ជីរួចហើយ។ ខ្ញុំគិតថាប្រហែលជាគាត់ប្រាប់លោកប្រធាន។ ក៏ប៉ុន្តែយើងខ្ញុំសូមជម្រាបជូនថា យើងខ្ញុំនឹងប្រើប្រាស់ពេលវេលាកន្លះថ្ងៃដូចដែលអង្គជំនុំជម្រះបានប្រគល់ជូនលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការឆ្លើយបញ្ជាក់ច្បាស់លាស់នេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ុម អាឡាត់។ សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី និងភាគីទាំងអស់។ ហើយសូមជម្រាបសួរលោកសាក្សី ស៊ុម អាឡាត់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ថ្ងៃនេះ ខ្ញុំសូមសួរលោកសំណួរមួយចំនួនអំពីតួនាទីរបស់លោកនៅក្នុងពេលមានជម្លោះក្នុង

ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥នៅកម្ពុជា។ លោកបានផ្តល់សេចក្តីសង្ខេបជូនទៅអ្នកស៊ើបអង្កេតមកពីអង្គជំនុំជម្រះបីបួនឆ្នាំមកហើយ ថាខ្ញុំនឹងជូនជាសេចក្តីដកស្រង់ ហើយនិងខ្ញុំសូមសួរបញ្ជាក់មួយចំនួន។ នៅក្នុងឯកសារ E 00 -- បាទ ខ្មែរ 00196809, បារាំង 00271429។ លោកបាននិយាយថា "តើលោកធ្វើអ្វីមុនឆ្នាំ១៩៧៥? តើលោករស់នៅឯណា? ខ្ញុំបានបញ្ចប់ការសិក្សា និងបានចូលធ្វើទាហានជើងគោកខាងផ្នែកសឹករងខេត្តពោធិ៍សាត់នៅក្នុងឆ្នាំដដែលនោះ។ ពេលនោះ ខ្ញុំជាឋានៈនាយទាហានជាន់ទាបមានសមមិត្តពលបាលត្រី។ ខ្ញុំធ្វើការនៅក្នុងសេនាធិការខេត្ត។ ខ្ញុំធ្លាប់បានចូលក្នុងសមរភូមិប្រយុទ្ធនៅភ្នំក្រវាញ ស្រុកភ្នំក្រវាញ ជាសមរភូមិធ្ងន់ធ្ងរជាងគេនៅក្នុងឆ្នាំ១៩៧៣ ហើយបានដកប៉ុស្តិ៍ និងនាំប្រជាជនរាប់ពាន់នាក់ពីតំបន់លាជស្រុកក្រវាញ ចូលមកខេត្តពោធិ៍សាត់។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានធ្វើការនៅក្នុងសេនាធិការខេត្តវិញ។ ខែមេសា ឆ្នាំ១៩៧៥ មេបញ្ជាការបានឲ្យទៅធ្វើការនៅអង្គភាពកាន់កាំភ្លើងធំនៅសមរភូមិស្វាយ ស្ពានស្វាយដូនកែវ រួចត្រឡប់មកនៅពោធិ៍សាត់វិញ នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ខេត្ត"។

[០៩:០៧:២២]

សំណួរទី១របស់ខ្ញុំទៅលោក តើត្រឹមត្រូវដែរទេ នៅពេលដែលលោកមានអាយុ១៦ឆ្នាំនៅពេលដែលមានសង្គ្រាម ហើយមានអាយុ២១ឆ្នាំនៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ខេត្តពោធិ៍សាត់?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ចំពោះអាយុពុំទាន់ត្រឹមត្រូវទេ។

**ស៖** សូមអរគុណ។ អ៊ីចឹងនៅក្នុងឆ្នាំ១៩៧០ លោកមានអាយុប៉ុន្មាន?

**ឆ៖** ក្នុងឆ្នាំ១៩៧០ ខ្ញុំអាយុជិត២០ហើយ ប្រហែលជា១៩ ឬ២០។ ឆ្នាំ១៩៧០ ខ្ញុំជាប់ឌីប្លូមហើយ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកចូលកងទ័ពជើងគោកនៅក្នុងឆ្នាំ១៩៧២ តើលោកស្ថិតនៅក្នុងកងអនុសេនាធំ ឬក៏នៅក្នុងអង្គភាពណាមួយដែលលោកចាំឈ្មោះបានច្បាស់ទេ?

[០៩:០៨:៥០]

**ឆ៖** នៅពេលដែលខ្ញុំចូលអង្គភាព ហៅថាទាហាន ផ្នែកខាង លន់ នល់ ហ្នឹង គេហៅថា ផ្នែកសឹករងខេត្តពោធិ៍សាត់ នៅក្នុងអង្គភាពហ្នឹង គឺគេជ្រើសតាំងឲ្យចូលជា*អេតា-ម៉ាហ្ស៊័រ* ខេត្ត១ ទីតាំងគឺនៅសាលាខេត្ត។ ខ្ញុំធ្វើការនៅក្នុងអង្គភាពហ្នឹងឯង។

**ស៖** នៅពេលដែលលោកមិនចូលសមរភូមិ តើការងារមួយចំនួនដែលបានធ្វើ កាលណោះជាទាហាន គេឲ្យធ្វើអ្វី បើមិនទៅច្បាំងទេនោះ?

**ឆ៖** ខ្ញុំជាបុគ្គលិកអេតា-ម៉ាហ្សឺរ ជាអគ្គសេនាធិការនៅខេត្ត នៅសាលាខេត្ត តំណាងឲ្យផ្នែកសឹករងហ្នឹង គឺគេធ្វើអគ្គសេនាមាន *ព្រឹមីញ៉េប៊ុយរ៉ូ, ដឺហ្សៀមប៊ុយរ៉ូ, ត្រ័រហ្សៀមប៊ុយរ៉ូ, កាត់ទ្រីយាមប៊ុយរ៉ូ (តាមសូរស័ព្ទ)* ជាដើម គឺខ្ញុំជាបុគ្គលិក *ត្រ័រហ្សៀមប៊ុយរ៉ូ* ផ្នែក*អ៊ុបប៉េរ៉ាស្យុង*។

[០៩:១០:០៦]

**ស៖** ដូច្នេះ លោកមានធ្វើសេចក្តីសង្ខេប លោកបានដឹងយ៉ាងច្បាស់លាស់អំពីសកម្មភាពយោធាមួយចំនួន ហើយនិងការវាយប្រហារមួយចំនួននៅក្នុងខេត្តពោធិ៍សាត់ ថាតើសមរភូមិនៅខាងមុខដូចម្តេច? តើសកម្មភាពយោធាយ៉ាងដូចម្តេចនៅពេលដែលលោកធ្វើការនៅក្នុងការិយាល័យរបស់លោកនាកាលណោះ?

**ឆ៖** នៅពេលជំនាន់ដែលខ្ញុំធ្វើការនៅក្នុង អេតា-ម៉ាហ្សឺរ នៅអគ្គសេនាធិការ សភាពការណ៍នៅកម្ពុជាពេលនោះគឺមានភាពច្របូកច្របល់ហើយ មួយផ្នែកតំបន់ជាច្រើនដែលកាន់កាប់ដោយខ្មែរក្រហម។ ហើយទ័ពទាំងសងខាងមានការប្រយុទ្ធគ្នាទៅតាមតំបន់គ្រប់ទីកន្លែង។

**ស៖** នៅក្នុងនោះលោកបញ្ជាក់ថានៅក្នុងឆ្នាំ១៩៧៣ នៅស្រុកភ្នំក្រវាញ គឺជាសមរភូមិក្តៅ។ តើចម្ងាយប្រហែលប៉ុន្មានសមរភូមិនោះដែលនៅឆ្ងាយពីទីរួមខេត្តពោធិ៍សាត់ហ្នឹងចម្ងាយប៉ុនណាដែរ?

**ឆ៖** ទីតាំងស្រុកភ្នំក្រវាញ កាលពីដើមគេហៅថា លាជ – ស្រុកលាជ – គឺស្រុកមួយទាំងមូលចម្ងាយ ៣០ប្លាយគីឡូម៉ែត្រពីទីក្រុងពោធិ៍សាត់ ដែលត្រូវដកចេញទាំងប្រជាពលរដ្ឋទាំងអស់ចូលមករួមរស់នៅក្នុងខេត្តពោធិ៍សាត់ក្នុងឆ្នាំ១៩៧៣។

**ស៖** តើអ្នកណាជាអ្នករៀបចំឲ្យពួកគេមកនៅក្នុងទីក្រុង ថាតើកងកម្លាំងទាហាន លន់ នល់ ឬក៏ខាងកងកម្លាំងខាងរំដោះ? តើនរណាជាអ្នកដកប្រជាជននោះ?

[០៩:១១:២១]

**ឆ៖** សូមជម្រាបជូនថា នេះគឺបញ្ជាពីថ្នាក់លើ ផ្នែកខាងទាហាន លន់ នល់។

**ស៖** ដោយសារថាលោកចាញ់សមរភូមិនៅក្នុងខេត្តនោះ ឬក៏ដោយមូលហេតុអ្វី?

**ឆ៖** មូលហេតុពិតប្រាកដពុំបានដឹងទេ ព្រោះខ្ញុំគ្រាន់ទទួលដឹងថាជាបញ្ជាថ្នាក់លើ ពីភ្នំពេញ។

**ស៖** សូមអរគុណ។ រវាងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥ នៅខេត្តពោធិ៍សាត់ តើមានសមរភូមិមាន

ការវាយប្រយុទ្ធគ្នាច្រើនកន្លែងដែរឬទេ នៅក្នុងខេត្តពោធិ៍សាត់?

**ឆ៖** ព្រឹត្តិការណ៍នៅក្នុងខេត្តពោធិ៍សាត់នាពេលនេះគឺការដកជាបន្តបន្ទាប់ បន្ទាប់ពីប៉ុស្តិ៍ពីស្រុកក្រវាញដកមកអស់ហើយ ក្រោយមកទៀតសភាពការណ៍នៅខាងបំណាក់ ស្រុកក្រគរក៏ដកមកដែរ ដកបន្តបន្ទាប់រហូតដល់ថ្ងៃ១៧ មេសា។

**សៈ** យើងអាចនិយាយថា មុនថ្ងៃទី១៧ ខែមេសា គឺមុនពេលដែលខ្មែរក្រហមចូលកាន់កាប់ខេត្ត តើមានសមរភូមិមុខប៉ុន្មាន? តើប្រវែងសមរភូមិមុខហ្នឹងប្រវែងប្រហែលប៉ុនណាដែរ ដែលជាខ្សែក្រវាត់ការពារក្រុង ឬក៏ខេត្តនាអង្កាល់នោះ?

**ឆ៖** នៅសម័យនោះក្រវាត់ក្រុងមិនឆ្ងាយជាងប្រមាណ៣០គីឡូម៉ែត្រជុំវិញទេ មិនលើសទេ មានតែពីក្រោម។

[០៩:១៥:០៣]

**សៈ** តើសមរភូមិមុខ តើសមរភូមិនោះនៅចម្ងាយប៉ុន្មានព័ទ្ធជុំវិញទីរួមខេត្ត ឬក៏ទប់ទល់ខាងខ្មែរក្រហម ឬក៏នៅផ្នែកខាងណា តំបន់ណាខ្លះនៅជុំវិញទីរួមខេត្តកាលនោះ?

**ឆ៖** សូមសំណួរម្តងទៀត។

**សៈ** លោកបាននិយាយថាមុនពេលដែលខ្មែរក្រហមចូលកាន់កាប់ខេត្តពោធិ៍សាត់នោះ គឺសមរ-ភូមិប្រហែលជាចម្ងាយ ៣០ម៉ែត្រ -- ៣០គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍សាត់។ តើសមរភូមិនោះជារង្វង់ជុំវិញខេត្ត -- ទីរួមខេត្តពោធិ៍សាត់ ឬក៏លាតសន្ធឹងទៅខាងជើង ទៅខាងត្បូង ខាងលិច ឬក៏មានទ្រង់ទ្រាយដូចម៉េច បាទ និយាយពីសមរភូមិ?

**ឆ៖** សមរភូមិនេះគឺចង់បញ្ជាក់ថា នៅតាមស្រុក គឺជុំវិញស្រុកមានតិចតួចបាទ ហើយតាមខេត្តក៏មានតិចតួចដែរ នៅជុំវិញ គឺនិយាយជុំវិញ -- *អង់សិកក្លេន(តាមសូរស័ព្ទ)*នៅជុំវិញ។ ទ័ពខាងខ្មែរក្រហមគឺថាមានការហ៊ុមព័ទ្ធ គឺថាកាន់តែចូលរួម មកបន្តិចម្តងៗពី១ថ្ងៃទៅ១ថ្ងៃ។ ឯការទប់ទល់គ្នា ចេះតែច្រានទៅមក គឺមិនឆ្ងាយទេ។ ដូចខ្ញុំបញ្ជាក់ជូនអ៊ីចឹង នៅតាមស្រុកក៏មានបញ្ហា នៅតាមខេត្តក៏មានបញ្ហា។

[០៩:១៧:០២]

**សៈ** តើត្រឹមត្រូវឬទេ គឺថា -- និយាយថាភ្លាមៗបន្ទាប់ពីខ្មែរក្រហមកាន់កាប់ខេត្តពោធិ៍សាត់នៅសាលាខេត្ត ថាតើមានសមរភូមិមួយចំនួនដែលគេប្រយុទ្ធគ្នាច្រើនកន្លែងនៅក្នុងខេត្តពោធិ៍សាត់?

**ឆ៖** នៅពេលនោះ គឺខ្ញុំពុំឃើញមានសមរភូមិណាក្រោយពេលដែលខ្មែរក្រហមចូលមកកាន់

កាប់ខេត្ត គឺអត់ មិនមានសមរភូមិណាចេញចូលជាអាវុធទៀតទេ ព្រោះអីពេលនោះចងអាវុធអស់ហើយខេត្តពោធិ៍សាត់។

**ស៖** បាទ ប៉ុន្តែភ្លាមៗមុនពេលដែលខ្មែរក្រហមកាន់កាប់ខេត្ត តើមានការប្រយុទ្ធគ្នា មានការផ្ទុះអាវុធក្នុងសមរភូមិច្រើនទេ នៅក្នុងទីរួមខេត្ត និយាយពីមុនពេលដែលខ្មែរក្រហមចូលកាន់មកវិញបាទ?

**ឆ៖** ជាការពិតនៅពេលដែលមុនៗនឹងបន្តិច មុនខ្មែរក្រហមចូលមកកាន់កាប់សមរភូមិ គ្រប់កន្លែងទាំងអស់ គឺមានការប្រយុទ្ធខ្លាំងក្លា។

[០៩:១៨:៣៤]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងសួរលោកមួយចំនួនអំពីហេតុការណ៍ដែលថាលោកនិយាយពីបញ្ហានេះនៅក្នុងកំណត់ហេតុ ខ្ញុំសូមអានជូនលោកនៅក្នុង -- ខ្ញុំសូមសួរសំណួរមួយចំនួនក្រោយពីអានជូនស្តាប់ ដែលលោកបាននិយាយឲ្យអ្នកស៊ើបអង្កេតសាលាក្តីនេះបាន គឺថាឯកសារ 00242123 ដល់ 24, ខ្មែរ 0019689 *(ស៊ីក)*, បារាំង 00274129។ គេបានសួរលោកថា “តើលោកធ្វើអ្វីនៅក្នុងឆ្នាំ១៩៧៥ តើលោករស់នៅឯណា? នៅខែមេសា ឆ្នាំ១៩៧៥ ខ្ញុំដូរពីកន្លែងកាំភ្លើងធំខេត្តពោធិ៍សាត់ ពេលនោះ ខ្មែរក្រហមបានកាន់កាប់ខេត្តពោធិ៍សាត់ហើយ។ ទាហាន លន់ នល់ ខេត្តពោធិ៍សាត់បានទទួលការណែនាំពីភ្នំពេញឲ្យទម្លាក់អាវុធ តាមការប្រកាសតាមវិទ្យុលោក ម៉ីស៊ី ចន ឧត្តមសេនីយ៍ត្រីនៅអគ្គសេនាធិការភ្នំពេញ។ នៅពេលដែលយើងទម្លាក់អាវុធ ខ្មែរក្រហមបាន បាញ់រះយើងរហូតនៅតាមសងខាងផ្លូវជាតិ។ ខ្មែរក្រហមដែលបាញ់ពួកយើងគឺគេលាក់ខ្លួននៅក្នុងព្រៃ។ គេបាញ់រះមកមិនគិតថាជាមនុស្ស ឬសត្វទេ។ ខ្ញុំដើរពេញ១ថ្ងៃពីស្វាយដូនកែវ មកត្រពាំងជង ស្រុកបាកាន”។ តើកងកម្លាំងលន់ នល់ ទាំងអស់នៅខេត្តពោធិ៍សាត់តាមដែលលោកដឹង តើមានលទ្ធភាពក្នុងការស្តាប់ការប្រើប្រាស់វិទ្យុទាក់ទងខាងយោធាដែរឬទេ?

**ឆ៖** មិនយល់សំណួរ។ សូម--

[០៩:២១:២៦]

**ស៖** លោកបានបញ្ជាក់ថាការណែនាំឲ្យទម្លាក់អាវុធមកពីភ្នំពេញហ្នឹង ពីប្រកាសតាមវិទ្យុ។ តើវិទ្យុហ្នឹងគឺថាជាវិទ្យុផ្សាយទូទៅ ឬក៏ជាវិទ្យុដែលគេប្រកាសណែនាំទៅកងកម្លាំងទាហានរបស់ លន់ នល់ ទេ?

**ឆ៖** សូមជម្រាបថាវិទ្យុដែលផ្សាយហ្នឹងគឺផ្សាយទូទាំងប្រទេស ជាព្រឹត្តិការណ៍ទូទាំងប្រទេស

ផ្សាយតាមវិទ្យុជាតិ។ "យើងតំណាងឲ្យអគ្គសេនាធិការភ្នំពេញ ម៉ី ស៊ីចន សូមជម្រាបជូនអំពីកងយុទ្ធពលខេមរជាតិទាំងអស់ចងបាច់អាវុធ លើកទង់ជ័យស ចុះចូល និងរកសន្តិភាព"។ ដូច្នេះគ្រប់អង្គភាពទាំងអស់ត្រូវតែគោរពតាម។

**ស៖** តើលោកនៅចាំទេ លោកនៅកន្លែងណានៅពេលដែលលោកស្តាប់ឮសេចក្តីប្រកាសនោះ?

**ឆ៖** ខ្ញុំនៅចាំបានច្បាស់គឺនៅក្នុងទឹកដីស្វាយដូនកែវ ដែលជាអង្គភាពខ្ញុំផ្ទាល់។

[០៩:២២:៥៧]

**ស៖** ដើម្បីឲ្យយើងដឹងច្បាស់នៅក្នុងស្វាយដូនកែវនោះ តើនៅចម្ងាយប៉ុន្មានពីទីក្រុង -- ទីរួមខេត្តពោធិ៍សាត់ ហើយនៅទិសខាងណាពីទីរួមខេត្តពោធិ៍សាត់?

**ឆ៖** ស្វាយដូនកែវ គឺជាចំណុចបែងចែកព្រំដែនបាត់ដំបង និងខេត្តពោធិ៍សាត់ តាមបណ្តោយផ្លូវជាតិលេខ៥ នៅទិសខាងលិចពីក្រុង ចម្ងាយជាង៣០គីឡូម៉ែត្រ។

**ស៖** សូមអរគុណ នេះជាចម្លើយដ៏ច្បាស់។ លោកក៏បាននិយាយអំពីការដាក់អាវុធ ទម្លាក់អាវុធ ហើយខ្មែរក្រហមបានបន្តបាញ់ប្រហារនៅតែទៅទៀត គឺថាបាញ់ដោយមិនរើសមុខ។ តើកងទ័ពខ្មែរក្រហមបានដឹងថា លោកបានទម្លាក់អាវុធហើយឬនៅកាលនោះនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរ។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ។ សាក្សីនេះមិនអាចដឹង ថាតើខ្មែរក្រហមដឹង ឬមិនដឹងថាពួកគាត់ទម្លាក់អាវុធនោះទេ។ បើសួរបែបនេះគឺឲ្យសាក្សីនិយាយដោយស្មានទៅលើហេតុការណ៍

[០៩:២៤:២៩]

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបលោកប្រធាន លោកចៅក្រមថា គាត់អាចនឹងដឹងនៅពេលដែលគេទម្លាក់អាវុធ គេលើកទង់ជ័យស គឺខ្ញុំមិនឲ្យគាត់សន្មត ឬក៏និយាយព្រាវទេ។ គាត់អាចនឹងជម្រាបតុលាការបានថា តើគាត់ដឹងនេះ។ អ៊ីចឹងហើយគឺគាត់ជាអ្នកផ្តល់ចម្លើយបែបនេះ ហើយគាត់ថាគាត់ទម្លាក់អាវុធ ថាតើគាត់ដឹង ឬមិនដឹងតាមអំពីរបស់ពួកគាត់ តាមអំពើរបស់ខាងខ្មែរក្រហម គាត់អាចដឹង។ ដូច្នេះ គាត់ -- ខ្ញុំមិន

សុំឲ្យគាត់និយាយព្រាវ ឬក៏ស្មានអំពីហេតុការនេះទេ។ អ៊ីចឹង គឺដូច្នេះតុលាការគួរតែពិចារណា ឲ្យគាត់ឆ្លើយ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនមានមូលហេតុសមស្របទេ។ អង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីរូបនេះ ចំពោះសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាដែលបានសួរសាក្សីចុងក្រោយអម្បាញ់មិញនេះ។

សូមលោកសាក្សីឆ្លើយតបទៅនឹងសំណួរ!

**លោក ស៊ុម អាឡាត់៖**

ខ្ញុំសូមការអនុញ្ញាតពិភាក្សាជាមួយមេធាវី។

**ប្រធានអង្គជំនុំ៖**

សំណួរនេះមិនមែនជាសំណួរដាក់បន្ទុកនាំឲ្យលោកឆ្លើយដាក់បន្ទុកលើខ្លួនឯងទេ ប្រសិនបើសំណួរនេះមិន -- លោកភ្លេចលោកអាចសុំឲ្យម្ចាស់សំណួរសួរសាជាថ្មីឡើងវិញដើម្បីលោកចងចាំ។ ហើយលោកតំណាងសហព្រះរាជអាជ្ញាទំនងជាសាក្សីភ្លេចនូវសំណួរដែលលោកសួរចុងក្រោយអម្បាញ់មិញនេះហើយ។ សូមលោករៀបចំនូវសំណួរចុងក្រោយអម្បាញ់មិញសួរគាត់សាជាថ្មីម្ដងទៀត។

[០៩:២៦:២៤]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ ខ្ញុំនឹងសួរឡើងវិញ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** នៅពេលអង្គភាពរបស់លោកបានឮថាឲ្យទម្លាក់អាវុធ តើលោកបានបញ្ជូនដំណឹងហ្នឹងទៅខាងខ្មែរក្រហមឲ្យដឹងទេ ដើម្បីឲ្យគេដឹងថាលោកទម្លាក់អាវុធហើយកុំឲ្យបាញ់មកលើរូបលោកទៀត។ តើបានធ្វើបែបនោះដែរឬទេ?

**លោក ស៊ុម ឡាត់៖**

**ឆ៖** សូមបញ្ជាក់ថាបញ្ហានេះនៅពេលដែលវិទ្យុឲ្យទម្លាក់អាវុធនោះ ពីល្ងាចអង្គភាពនៅទល់មុខគ្នារវាងខ្មែរក្រហម ហើយនិងយើង បញ្ជាក់ច្បាស់។ ពីល្ងាចគឺយើងចងអាវុធរៀងៗខ្លួនហ្នឹង ដាក់រៀងៗខ្លួនមកវាំវង់ជាមួយគ្នា តែព្រលឹមឡើងមានផែនការផ្សេងគឺយើងលើកទង់ជ័យស គេកាន់អាវុធ។ នេះស

បញ្ជាក់ឲ្យឃើញច្បាស់។

**ស៖** នៅពេលដែលលោកលើកទង់ជ័យស តើការបាញ់ប្រហារនៅតែបន្ត ឬក៏គេបានបញ្ឈប់?

[០៩:២៨:០៥]

**ផ៖** នៅពេលដែលលើកទង់ជ័យសភ្លាមៗនៅពេលល្ងាច សភាពការណ៍គឺបានផ្អាកមិនមានបាញ់គ្នាទៀតទេ ប៉ុន្តែព្រលឹមឡើងដែលយើងចាកចេញកាន់ទង់ជ័យសដើរពីស្វាយដូនកែវមកខេត្តពោធិ៍សាត់ គឺជាព្រឹត្តិការណ៍មួយខុសប្លែកពីល្ងាច។

**ស៖** តើមានការបាញ់ដែរឬទេ នៅពេលព្រឹកនោះ?

**ផ៖** នៅពេលដែលយើងដកទាំងប្រជាជន និងពលទាហានត្រឡប់មកអង្គភាពតាមផ្លូវជាតិលេខ៥ គឺសងខាងផ្លូវ គេបាញ់រះយើងរហូត។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់ឲ្យលោក ខ្ញុំពិនិត្យមើលចម្លើយរបស់លោកដែលលោកនិយាយថាលោកបានចូលរួមអង្គប្រជុំនៅមន្ទីរស្រុកបាកាននោះ អង់គ្លេស 00242124,ខ្មែរ 00196809 និង 10 ដល់ 10, បារាំង 00274130។ លោកបាននិយាយថា "នៅម៉ោងប្រាំពីរព្រឹកនៅថ្ងៃដដែលនោះគឺថ្ងៃដែលលោកបានទម្លាក់អាវុធនោះឯង ប្រធានខ្មែរក្រហមបានប្រមូលទាំងទាហាន ទាំងប្រជាជន អ្នកមន្ត្រីរាជការនៅសាលាស្រុកបាកាន ដែលមានមនុស្សប្រហែលជិត៥០០នាក់។ ខ្ញុំមិនដឹងថាមេខ្មែរក្រហមដែលដឹកនាំប្រជុំនោះឈ្មោះអ្វីទេ។ នៅពេលនោះ ខ្ញុំបានផ្លាស់ខោអាវទាហានចេញ ហើយស្លៀកពាក់ស៊ីវិលមកវិញ។ ឯខ្លឹមសារប្រជុំគេបំពាក់បំប៉នផ្នែកនយោបាយឲ្យប្រជាជនចេញពីខេត្តទៅតាមជនបទ ដោយប្រាប់ថាធ្វើបែបនេះ ដើម្បីជៀសវាងការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក។ ខ្ញុំបានរត់គេចខ្លួនក្នុងខណៈពេលពួកគេកំពុងប្រជុំ ដោយមានកាំភ្លើងខ្លីមួយដើមមកជាប់ជាមួយខ្លួន ដោយល្បូនធ្វើដំណើរអស់រយៈ១យប់ ទើបទៅដល់ស្វាយអាត់"។ សំណួរទី១ របស់ខ្ញុំ តើចម្ងាយប៉ុន្មាន តើនៅស្រុកបាកាននៅចម្ងាយប៉ុន្មានពីទីរួមខេត្តពោធិ៍សាត់?

**ផ៖** ស្រុកបាកាននៅទិសខាងលិចនៃខេត្តពោធិ៍សាត់ ចម្ងាយជា១៥គីឡូ ជាង១៥គីឡូម៉ែត្រ ទៅ២០គីឡូម៉ែត្រ។

**ស៖** ដូច្នេះលោកនិយាយថាស្រុកបាកាន មន្ទីរស្រុកហ្នឹងគឺចម្ងាយ២០គីឡូម៉ែទ្រពីក្រុងពោធិ៍សាត់ តើអ៊ីចឹងឬទេ?

[០៩:៣១:៥០]

**ឆ៖** ប្រហែលជាប៉ុណ្ណឹង ត្រឹមត្រូវ។

**ស៖** តើពួកខ្មែរក្រហមធ្វើយ៉ាងដូចម្ដេចដើម្បីអាចប្រមូលពួកទាហាន ប្រជាជន ឬក៏មន្ត្រីរាជការទាំង៥០០នាក់នោះ?

**ឆ៖** នីតិវិធីនៃការប្រមូល ខ្ញុំពុំបានដឹងទេ ប៉ុន្តែពេលដែលខ្ញុំមកដល់ គឺគេជួបជុំគ្នាអស់ហើយ។ គេថែមទាំងឃាត់យើងខ្ញុំឲ្យចូលរួមជាមួយនឹងគេ។

**ស៖** តើលោកអាចពន្យល់បានដែរឬទេថាហេតុអ្វីបានជាលោកទៅមន្ទីរស្រុកបាកាននោះ បន្ទាប់ពីចេញពីទាហានហ្នឹងមក?

**ឆ៖** នៅថ្ងៃជាមួយនោះដែរ យើងបានបញ្ជាក់ជូននៅក្នុងកំណត់ហេតុជូនហើយ ចេញដំណើរពីស្វាយដូនកែវទាំងព្រឹក១ថ្ងៃ មកទល់គ្នាដល់បាកានគឺ១ថ្ងៃ នៅពេលយប់ព្រលប់ យប់ទៅហើយៗបានយើងមកដល់ គឺគេប្រជុំតែម្ដង។ ដូច្នេះរយៈពេលដ៏ខ្លីទេ ប៉ុន្តែដោយការបាញ់រះ ដោយការគេចពួន គឺយើងធ្វើដំណើរ១ថ្ងៃពីស្វាយដូនកែវ មកបាកាន។

[០៩:៣៣:៤៧]

**ស៖** សូមលោកជួយពន្យល់លម្អិតបន្តិចអំពីអ្វីដែលគេបាននិយាយនៅក្នុងកិច្ចប្រជុំនោះ? គឺខ្ញុំចង់ដឹងថាតើខ្លឹមសារនៃការប្រជុំហ្នឹង ជាការបណ្ដុះបណ្ដាលមនោគមន៍វិជ្ជា ឬក៏ជាការបញ្ចុះបញ្ចូលឲ្យប្រជាជនចេញពីទីក្រុងចេញពីទីរួមខេត្ត តើលោកអាចពន្យល់បានទេ គេនិយាយអ្វីខ្លះនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** សភាពការណ៍ពេលនោះ ខ្ញុំពុំបានចាប់អារម្មណ៍ធ្ងន់ធ្ងរទៅលើបញ្ហាអ្វីនោះទេ គឺខ្លួនខ្ញុំកំពុងតែភ័យ តក់ស្លុត និងបញ្ហាដែលមិនអាចធានាជីវិតខ្លួនឯងផង។ ដូច្នេះ ពុំបានចាប់អារម្មណ៍អ្វីទេ។

**ស៖** លោកបាននិយាយថា គេបានបញ្ចុះបញ្ចូលឲ្យប្រជាជនចាកចេញពីរួមខេត្តទៅជនបទ។ តើវាជាការបង្ខំ ឬមួយក៏ជាការស្នើឲ្យចាកចេញ?

**ឆ៖** រូបភាពនេះ គឺជាព្រឹត្តិការណ៍នោះ យើងឃើញថា ជាការបង្ខំៗ ត្រូវតែចេញ។

**ស៖** តើលោកដឹងដែរឬទេ ថាតើមន្ត្រីខ្មែរក្រហមមួយណាដែលដឹកនាំការប្រជុំនោះ? តើអ្នកណាជាអ្នកនិយាយនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** ខ្ញុំពុំបានដឹងទេ។

**ស៖** បន្ទាប់ពីការប្រជុំ ដែលគេឲ្យប្រជាជនចេញពីរួមខេត្តនោះ តើបន្ទាប់ពីប្រជុំហ្នឹង ប្រជាជនគាត់ចាកចេញពីខេត្តពោធិ៍សាត់ ចាកចេញពីទីរួមខេត្តពោធិ៍សាត់តែម្ដង ឬមួយក៏យ៉ាងម៉េច?

[០៩:៣៦:០៦]

**ឆ៖** បាទដំណាក់កាលដែលយើងនិយាយនេះគឺប្រជុំនៅក្នុងស្រុកបាកានទេ មិនទាន់ដល់ចូលដល់ទៅទីរួមខេត្តនៅឡើយទេ។

**ស៖** តើលោកដឹងថាមានការប្រជុំនៅក្នុងទូទាំងខេត្តពោធិ៍សាត់ដែរឬទេ? តើមានការប្រជុំច្រើនកន្លែងដែរឬទេនៅក្នុងខេត្តពោធិ៍សាត់? គឺខ្ញុំចង់ដឹងថាតើមានការប្រជុំនៅកន្លែងផ្សេងៗទៀត ឧទាហរណ៍ដូចជានៅទីរួមខេត្តពោធិ៍សាត់ ថាមានការប្រជុំដើម្បីឲ្យប្រជាជនចេញពីទីរួមខេត្តដែរឬទេ? ប្រសិនបើលោកដឹង សូមលោកជួយប្រាប់ ប្រសិនបើលោកអត់ដឹងទេ លោកឆ្លើយថាអត់ដឹងចុះ។

**ឆ៖** នៅពេលដែលខ្ញុំនៅប្រជុំនៅស្រុកបាកាន ខ្ញុំពុំបានដឹងថាខាងគេប្រជុំទេ ប៉ុន្តែជាក់ស្តែងគឺនៅក្នុងស្រុកបាកានដែលខ្ញុំមកដល់ហ្នឹង គឺនៅពេលប្រជុំហ្នឹង។ នៅពេលនោះ គឺខ្ញុំមិនបានដឹងពីកន្លែងណាដែលគេប្រជុំដែរឬទេ អត់ដឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីការជម្លៀសពីទីរួមខេត្តពោធិ៍សាត់។ នៅក្នុងចម្លើយរបស់លោកគឺនៅត្រង់ឯកសារលេខ 00242124 ដល់ 25, ភាសាខ្មែរគឺត្រង់លេខ 00196810, និងភាសាបារាំងមានលេខ 00274130។ គេសួរលោកដូចតទៅនេះ "តើស្ថានភាពនៅខេត្តពោធិ៍សាត់យ៉ាងដូចម្តេចដែរនៅពេលដែលទាហានខ្មែរក្រហមចូលកាន់កាប់ទាំងស្រុងនៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥?" លោកបានឆ្លើយថា "ពេលដែលខ្មែរក្រហមចូលមកដល់ ខ្ញុំបានឃើញមានទិដ្ឋភាពច្របូកច្របល់ និងឃើញមានព្រឹត្តិការណ៍មួយចំនួនដូចខាងក្រោម ពួកខ្មែរក្រហមបានជម្លៀសបានជម្លៀសប្រជាជនពីខេត្តទៅតាមជនបទ"។

[០៩:៣៨:១៤]

ដូច្នេះសំណួរទី១ ដែលខ្ញុំចង់សួរលោកគឺថា តើបន្ទាប់ពីការប្រជុំនៅស្រុកបាកានហ្នឹង គឺប្រហែលប៉ុន្មានថ្ងៃក្រោយការប្រជុំហ្នឹងដែលឃើញគេជម្លៀសប្រជាជនចេញពីទីរួមខេត្តពោធិ៍សាត់នោះ?

**ឆ៖** រយៈពេលនេះ គឺខ្ញុំចេញពីស្វាយ -- ចេញពីបាកានមក ១យប់មកដល់ស្វាយអាត់ ចេញពីស្វាយអាត់ហ្នឹងហើយ ជាព្រឹត្តិការណ៍ដែលខ្ញុំឃើញៗប្រជាពលរដ្ឋយើងស្គាល់ហើយនៅក្នុងខេត្តពោធិ៍សាត់បាទមានសភាពការស្គាល់ជ្រងំទៅហើយ ហើយក៏មានមួយៗខ្ញុំឃើញជួបដូចខ្ញុំបានសរសេរនៅក្នុងឆ្លើយបំភ្លឺដែរ ថាព្រឹត្តិការណ៍ហ្នឹងឃើញនៅច្របូកច្របល់នៅឡើយទេ មួយៗពីបញ្ហាហ្នឹងបាទ។ គឺពេលនោះយើងសន្និដ្ឋានមិនត្រូវទេ ភ័យផង អរផង ដែលយើងឃើញទិដ្ឋភាពជាក់ស្តែង គឺមានការជម្លៀសរួច

ហើយស្រេចបាត់ទៅហើយបាទ។ រយៈពេលភ្លាមៗហ្នឹងឯង មិនឆ្ងាយ មិនជាយូរទេ។ ដូច្នេះខុសគ្នា១ថ្ងៃ ឬ២ថ្ងៃប៉ុណ្ណោះឯង ដែលខ្ញុំមកគឺ១យប់ទេ ចេញពីបាកានមកដល់ពោធិ៍សាត់គឺមានការស្ងាត់ជ្រងំហើយ។ ហើយកាន់កាប់ដោយទ័ពខ្មែរក្រហមហើយ។

[០៩:៣៩:៤៤]

**ស៖** នៅពេលដែលលោកនិយាយថា ទីរួមខេត្តស្ងាត់ តើលោកចង់មានន័យថាប្រជាជន គាត់ចេញពីទីរួមខេត្តរួចរាល់អស់ហើយនៅពេលនុ៎ង ឬមួយក៏យ៉ាងដូចម្ដេច?

**ឆ៖** ខ្ញុំសន្និដ្ឋានថាចេញបាត់ទៅហើយ ព្រោះព្រឹត្តិការណ៍នេះប្រហាក់ប្រហែលគ្នាក្នុងការមិនឲ្យនៅក្នុងក្រុងក្រែងមានការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក -- ពីអាមេរិក -- ពីទ័ពអាមេរិក។

**ស៖** តើប្រជាជនហ្នឹងគាត់ទៅណា គឺប្រជាជនដែលគាត់ចេញពីទីរួមខេត្តពោធិ៍សាត់ហ្នឹងគាត់ទៅណាដែរ?

**ឆ៖** ខ្ញុំពុំបានដឹងថាទៅខាងណាទេ ជាច្រើនមុខសញ្ញា មិនដឹងទៅខាងណាទេ គ្រាន់តែនៅពេលដែលខ្ញុំទៅដល់ខេត្តពោធិ៍សាត់គឺស្ងាត់អស់ហើយ។ ដូច្នេះទឹកដីនៃទីរួមខេត្តពេលនោះ មិនមែនជាធំប៉ុន្មានទេតូចដែលទេ គឺធ្វើម៉េចឲ្យចេញពីក្រុងតែប៉ុននុ៎ងឯង។

[០៩:៤១:១០]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចង់និយាយអំពីការប្រជុំមួយទៀតដែលលោកបាននិយាយនៅក្នុងចម្លើយរបស់លោកផងដែរ គឺការប្រជុំដែលធ្វើនៅសាលាខេត្តពោធិ៍សាត់នៅថ្ងៃ២៤, ២៥ មេសា ឆ្នាំ៧៥។ នៅក្នុងចម្លើយរបស់លោកគឺត្រង់ឯកសារមានលេខ 00242125 ដល់ 26, ភាសាខ្មែរត្រង់លេខ 00196811, និងភាសាបារាំងនៅត្រង់ឯកសារលេខ 00274131 គឺ 31 និង 32។ គឺគេសួរលោកដូចតទៅនេះ៖ "តើក្រោយពីខ្មែរក្រហមចូលកាន់កាប់ខេត្តទាំងស្រុងនៅថ្ងៃ១៧ មេសា ១៩៧៥នោះ តើពួកខ្មែរក្រហមបានធ្វើអ្វីខ្លះចំពោះទាហាន និងមន្ត្រីរដ្ឋការសម័យ លន់ នល់? ឆ្លើយ៖ ពេលនោះគណៈតំបន់ឈ្មោះ សុត បានស្នើឲ្យចៅហ្វាយខេត្តពោធិ៍សាត់សម័យ លន់ នល់ គឺលោកឧត្តមសេនីយ៍ ព្រំ លីហ្សួន ទាហាន មន្ត្រីរដ្ឋការសម័យ លន់ នល់ និងសិស្ស ឲ្យមកជួបនៅសាលាខេត្ត ដែលមនុស្សប្រហែលជា៥០០នាក់បានចូលរួមប្រជុំជិត២ម៉ោង នៅថ្ងៃទី២៤ ឬ ២៥ ខែមេសា ឆ្នាំ១៩៧៥។ ខ្លឹមសារប្រជុំគឺដើម្បីទៅទទួលអង្គការនៅទួលពោធិ៍ជ្រៃ។ ក្នុងរយៈពេលប្រជុំមានកងទាហានខ្មែរក្រហមដែលការពារពីខាងក្រៅ។ មេខ្មែរក្រហមក៏មកចូលរួមប្រជុំដែរ ដែលមានឈ្មោះ តាសុត"។

សំណួរទី១ ដែលខ្ញុំចង់សួរលោកគឺ តើ តាសុត ដែលជាលេខាតំបន់នុំង តើគាត់ធ្វើយ៉ាងណាដើម្បីអាចទាក់ទងជាមួយលោកឧត្តមសេនីយ៍ ព្រំ លីហួន ដើម្បីកោះហៅទាហាន និងមន្ត្រីរាជការព្រមទាំងសិស្សហ្នឹងឲ្យមកប្រជុំ? តើគាត់ធ្វើយ៉ាងណាដើម្បីទាក់ទងជាមួយលោកឧត្តមសេនីយ៍ ព្រំ លីហួន បាន?

[០៩:៤៣:៣៩]

**ឆ៖** ព្រឹត្តិការណ៍នេះ ខ្ញុំឃើញដែលខ្ញុំបានចូលរួមនោះគឺដំណើរការបាត់ទៅហើយ ប៉ុន្តែឬការទំនាក់ទំនងយ៉ាងណាៗនោះ ខ្ញុំអត់ដឹងទេ ប៉ុន្តែថាបានចូលរួម។ នៅពេលដែលខ្ញុំបានចូលរួម គឺខ្ញុំបានបញ្ជាក់នៅក្នុងការឆ្លើយនៅក្នុងកំណត់ហេតុហើយ។ នីតិវិធី និងការទំនាក់ទំនងគ្នាយ៉ាងម៉េចគឺ ខ្ញុំមិនបានដឹង។

**សះ** ខ្ញុំអាចយល់បានអំពីចម្លើយរបស់លោក។ ប៉ុន្តែតើលោកដឹងអំពីការប្រជុំហ្នឹងដោយរបៀបណា? តើលោកចាំទេ ថាលោកដឹងដោយរបៀបណា?

**ឆ៖** ខាងភាគីខាងខ្ញុំ ភាគីខាង លន់ នល់ គឺគេមានខ្សែរយៈគេតៗគ្នាមក នៅស្ដាប់គ្នានៅឡើយទេ គេបានប្រកូកប្រកាសគ្នាហៅឲ្យមកចូលរួមប្រជុំនៅក្នុងសាលាខេត្ត។ ដូច្នេះ ខ្ញុំក៏តាមគេតាមឯងដែរ ប៉ុន្តែភាគីគេកាលណាទំនាក់ទំនងគ្នាយ៉ាងម៉េច ខ្ញុំពុំបានដឹងដែរ។

**សះ** ខ្ញុំយល់ ខ្ញុំយល់អំពីការទំនាក់ទំនង គឺការទំនាក់ទំនងរវាងទាហាន លន់ នល់។ តើលោកដឹងដែរឬទេថា ការទំនាក់ទំនង ឬក៏ខ្សែទំនាក់ទំនងហ្នឹងវាមាននៅទូទាំងខេត្តពោធិ៍សាត់តែម្ដង ឬក៏វាមានត្រឹមតែតំបន់ ឬក៏កន្លែងមួយចំនួនទេ?

**ឆ៖** ការទំនាក់ទំនងនេះ គឺនិយាយរួមផ្នែកខាងរដ្ឋបាល ផ្នែកខាងរដ្ឋបាលសម័យ លន់ នល់ គឺគេនៅមានដំណើរការនៅឡើយទេ។ ស្រុកឃុំអីហ្នឹង គេនៅស្ដាប់គ្នានៅឡើយទេ គឺដូច្នេះការប្រមូលរបស់ផងគេហ្នឹង គឺមានខ្សែរយៈគ្រប់គ្រាន់ក្នុងការប្រមូល ដើម្បីមកជួបជុំគ្នា ប្រជុំនៅសាលាខេត្ត។

[០៩:៤៥:៥៥]

**សះ** ទាក់ទងទៅនឹងអ្វីដែលគេបានប្រាប់ទៅដល់ទាហាន លន់ នល់ នៅក្នុងការប្រជុំនោះ តើលោកដឹងថា ការទំនាក់ទំនងហ្នឹងគឺគេផ្ដល់ទៅទាហាន លន់ នល់ នៅទូទាំងខេត្តពោធិ៍សាត់តែម្ដង ឬមួយក៏គេផ្ដល់ព័ត៌មានតែទៅទាហាន លន់ នល់ នៅក្នុងមួយតំបន់ ឬក៏នៅក្នុងកន្លែងមួយចំនួនណាទេ ឬមួយក៏គេកំណត់ត្រឹមតែមួយកន្លែង? តើគេផ្ដល់ព័ត៌មានជាទូទៅ ឬមួយក៏គេផ្ដល់ត្រឹមតែមួយផ្នែក ឬក៏

មួយតំបន់ ឬក៏មួយចំណុចណាមួយទេ ចំពោះទាហាន លន់ នល់?

**ឆ៖** ចំពោះបញ្ហានេះ គឺគេផ្តល់ទូទាំងខេត្ត មិនមែនកំណត់តែតំបន់ខេត្តតូចមួយនោះទេ គឺទូទាំងខេត្ត ខ្សែរយៈទូទាំងខេត្តទាំងអស់។

**ស៖** សូមអរគុណលោកសាក្សី។ លោកបាននិយាយថា មានមនុស្សប្រហែលជា៥០០នាក់ បានចូលរួម ហើយលោកបានបញ្ជាក់ផងដែរថា អ្នកខ្លះជាទាហាន មន្ត្រីរដ្ឋការ និងជាសិស្សរបស់របប លន់ នល់។ តើលោកអាចប្រាប់បានទេថា ក្នុងចំណោមមនុស្ស៥០០នាក់ នុ៎ង តើមានទាហាន លន់ នល់ ប្រហែលជាប៉ុន្មាននាក់ដែរ? គឺថាប្រហែលត្រឹមតែជាចំនួនប្រហែលទេ។

[០៩:៤៨:៣១]

**ឆ៖** ភាគីច្រើន គឺរដ្ឋការខាង លន់ នល់ ទាហាន លន់ នល់ ច្រើនជាងគេ ភាគីច្រើន ព្រោះសូមបញ្ជាក់ជូនថា លោក ព្រំ លីហួន នេះគាត់ជាចៅហ្វាយខេត្ត តែគាត់ជាទាហានដែរ។ បាទ ជំនាន់នុ៎ងគេជ្រើសរើសផ្នែកខាង លន់ នល់ ហ្នឹង គឺទាហានដែរ។ ដូច្នេះគេនៅស្តាប់មេស្តាប់កើយ អ៊ីចឹងទេអ្នកបម្រើការងារ លន់ នល់ ទៅតាមឋានន្តរសក្តិទាំងអស់ គឺជួបជុំគ្នានៅក្នុងខេត្តពោធិ៍សាត់ ភាគីច្រើនគឺទាហាន លន់ នល់។ ហើយមួយចំនួនទៀតមានសិស្ស មានមន្ត្រីរាជការ គឺគ្រូបង្រៀនភាគច្រើន។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់នៅក្នុងចម្លើយរបស់លោក លោកនិយាយថា មានទាហាន មន្ត្រីរដ្ឋការ និងសិស្សចូលរួម។ ហើយឥឡូវនេះ លោកបានឆ្លើយថា ភាគីច្រើននៃអ្នកចូលរួមហ្នឹង គឺជាមន្ត្រីរដ្ឋការដែលនៅក្រោមបង្គាប់របស់លោកឧត្តមសេនីយ៍ ព្រំ លីហួន។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរលោក គឺថា នៅពេលដែលលោកនិយាយថា ភាគីច្រើន គឺមន្ត្រីរដ្ឋការសម័យ លន់ នល់ ហ្នឹង តើលោកចង់និយាយសំដៅទៅលើទាហាន លន់ នល់ ឬមួយក៏មន្ត្រីប្រភេទផ្សេងទៀត ក្រៅពីទាហានរបស់ លន់ នល់ ហ្នឹង? តើលោកចង់និយាយមួយណាដែរ?

[០៩:៤៩:០៩]

**ឆ៖** សមាសភាពរួមៗនេះ គឺចង់និយាយទាំងអស់ គឺស៊ីវិល ទាំងយោធា។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់បន្ថែមទៀត តើក្នុងចំណោម៥០០នាក់នោះ តើលោកអាចប៉ាន់ស្មានថា តើទាហានមានប្រហែលប៉ុន្មាននាក់ដែរក្នុងចំណោម៥០០នាក់នោះ? គឺខ្ញុំចង់និយាយពីទាហាន លន់ នល់។

**ឆ៖** តាមខ្ញុំស្មានទាហាន លន់ នល់ ប្រហែលជាជាង ២០០។

**ស៖** លោកបាននិយាយថា លោកធ្វើការនៅសាលាខេត្ត គឺនៅក្នុងផ្នែកយោធារបស់ខេត្តពោធិ៍-សាត់។ តើលោកស្គាល់ទាហានប្រហែលជា២០០នាក់ដូចដែលលោកនិយាយហ្នឹង ថាតើលោកស្គាល់ទាហានខ្លះដែរឬទេ? ទាហានណាខ្លះទេ ក្នុងចំណោមទាហានប្រហែល២០០នាក់នោះ?

**ឆ៖** ស្គាល់ច្រើនដែរ។

**ស៖** តើទាហានដែលចូលរួមហ្នឹង គាត់មានពាក់ឯកសណ្ឋានទាហាន ឬមួយក៏ពាក់ស៊ីវិលទេ?

**ឆ៖** នៅពេលដែល១៧មេសា ទម្លាក់អាវុធ គឺយើងមិនមានពាក់ខោអាវយោធាទៀតទេ។

[០៩:៥១:២១]

**ស៖** តើលោកអាចនិយាយថា ក្នុងចំណោមប្រហែលជា២០០នាក់ដែលចូលរួមហ្នឹង តើលោកស្គាល់ប្រហែលជាប៉ុន្មាននាក់ដែរ ហើយប៉ុន្មាននាក់ទៀត តើប៉ុន្មាននាក់ដែលលោកស្គាល់ច្បាស់ ហើយប៉ុន្មាននាក់ទៀតដែលគ្រាន់តែជាមនុស្សធ្លាប់ស្គាល់គ្នា? តើលោកអាចនិយាយ ឬប៉ាន់ប្រមាណបានទេ?

**ឆ៖** ខ្ញុំនៅចាំបានអំពីមេទ័ពធំៗដែលជួបជុំគ្នានៅគ្នានោះ គឺមានបណ្តាស័ក្តិធំៗ មានឧត្តមសេនីយ៍មានបន្តបន្ទាប់មក តាមមានបណ្តាស័ក្តិរង្គការ លន់ នល់ ហ្នឹងជាច្រើនដែលខ្ញុំស្គាល់។ ប្រហែលជាង១០នាក់ ឬក៏២០នាក់។

**ស៖** សូមអរគុណលោក។ ដើម្បីឱ្យច្បាស់ទាំងអស់គ្នា គឺទាហានដែលចូលរួមនៅក្នុងការប្រជុំហ្នឹង តើទាហានហ្នឹងគាត់មកពីអង្គភាពយោធាខុសៗគ្នា ឬមួយក៏ពួកគាត់មកពីអង្គភាពតែមួយ ឬក៏ត្រឹមតែអង្គភាពពីរបីក្បែរៗគ្នាហ្នឹង តើលោកអាចប្រាប់បានទេ?

**ឆ៖** ទាហានដែលមកជួបជុំគ្នានេះ គឺមានអង្គភាពផ្សេងៗគ្នានៅក្នុងទូទាំងខេត្តនេះ ពេលហ្នឹងគឺមកផ្តុំគ្នាអស់ មកទាំងអស់ មកច្រើនកន្លែង។

[០៩:៥៣:០៨]

**ស៖** នៅពេលដែលលោកនិយាយថាទូទាំងប្រទេសហ្នឹង តើលោកចង់និយាយទូទាំងខេត្ត ឬមួយក៏ត្រឹមតែក្នុងខេត្ត ឬក៏នៅក្រៅខេត្តដែរនៅពេលដែលលោកនិយាយថាទូទាំងប្រទេសហ្នឹង ឬក៏លោកនិយាយថាប្រទេសហ្នឹង?

**ឆ៖** ខ្ញុំចង់និយាយតែក្នុងខេត្តពោធិ៍សាត់។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំច្បាស់ហើយពីចម្លើយរបស់លោក។ ក្នុងចំណោមមនុស្ស៥០០នាក់ ថាតើមានស្ត្រីចូលរួមដែរឬទេ?

**ឆ៖** ពេលដែលខ្ញុំបានឃើញមិនជា មិនមានស្ត្រីចូលរួមទេ ភាគច្រើនគឺបុរស។

**ស៖** លោកបាននិយាយថាទាហានខ្មែរក្រហមនៅការពារពីខាងក្រៅ។ តើលោកអាចប្រាប់បានទេថាមានទាហានខ្មែរក្រហមការពារពីខាងក្រៅហ្នឹងប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** តាមខ្ញុំស្មានប្រហែលជា៥០ ទៅ៦០នាក់។

**ស៖** ហើយលោកក៏បាននិយាយផងដែរថា មានប្រធានខ្មែរក្រហមចូលរួមផងដែរ ក្នុងហ្នឹងគឺតាសុត ដែលជាគណៈតំបន់។ តើលោកធ្វើយ៉ាងម៉េចដឹងថាមានមេៗខ្មែរក្រហមផ្សេងទៀត ក៏មកចូល រួមដែរក្រៅពី តាសុត នោះ?

[០៩:៥៥:១៣]

**ឆ៖** ដោយមានសម្លៀកបំពាក់ខ្មៅ និងប្រដាប់អាវុធយើងអាចសម្គាល់បានថាគេជាផ្នែកយោធាខ្មែរក្រហម។ ព្រោះខាងយើងពុំមានអាវុធទេ។

**ស៖** តើមានមេៗខ្មែរក្រហមប្រហែលជាប៉ុន្មាននាក់ដែលបានចូលរួមនោះ? គឺលោកនៅក្នុងចម្លើយរបស់លោក លោកប្រើត្រឹមតែពាក្យថាមេៗខ្មែរក្រហមក៏មក តើមានប្រហែលប៉ុន្មាននាក់ដែរដែលមកនោះ?

**ឆ៖** នៅព្រឹត្តិការណ៍នោះគឺយើងឃើញប្រហែលជាប្រាំទៅប្រាំពីរនាក់ដែលជាមេធំៗ។ ក្នុងនោះខ្ញុំបានឮគេប្រាប់ថាឈ្មោះ តាសុត មួយទេ ដែលជាគណៈតំបន់។

**ស៖** ហើយសាលាខេត្តដែលលោកបាននិយាយនោះ តើសាលាខេត្តហ្នឹងនៅរហូតមកដល់ឥឡូវឬមួយក៏គេរុះរើ ឬក៏វាទៅណាបាត់អស់ហើយ?

**ឆ៖** សណ្ឋាន និងរូបរាងនៅទាំងអស់។ ទីតាំងគឺនៅទាំងអស់ អត់ទាន់ផ្លាស់ប្តូរទៅណាទេ។

**ស៖** តើលោកអាចរៀបរាប់ពីអគារសាលាខេត្តហ្នឹងបានទេ ថាតើវាមានប៉ុន្មានជាន់? មាន មួយជាន់ ពីរជាន់ ហើយមានរបងព័ទ្ធជុំវិញឬមួយក៏អត់ តើលោកអាចរៀបរាប់ពីលក្ខណៈរបស់សាលាខេត្តហ្នឹងបានទេ?

[០៩:៥៧:១០]

**ឆ៖** នៅសម័យដែល លន់ នល់ ឬក៏ខ្មែរក្រហម សម័យដែលប្រជុំនៅព្រឹត្តិការណ៍នោះគឺសាលាខេត្តនៅតូចនៅឡើយទេ តែបច្ចុប្បន្ននេះគេពង្រីកភ្ជាប់ជាមួយនឹងអង្គភាព គឺថាអង្គភាពទ័ព*សីហ្សាម-បេសេ (តាមសូរស័ព្ទ)* ពីដើម ពង្រីកធំហើយ ប៉ុន្តែប្រាក់អូតែលនៅដដែលទេ។ ប្រាក់អូតែលមួយនៅ

ដដែលទេ ឯសេនាធិការដែលខ្ញុំធ្លាប់នៅគេរើហើយ។ ហើយមួយជ្រុងនោះគេបានដាក់នៅកាត់មកខាងលិចខាងក្រោយសាលាខេត្តនោះ ខាងក្រោយហ្គ្រង់អូតែលនោះ គឺគេដាក់សូរិយោដី។ អ៊ីចឹងប៉ុន្តែទីតាំងទាំងអស់នេះនៅចំណាំបានទេ មិនទាន់បាត់បង់ទៅណាទេ។

**ស៖** សូមអរគុណលោក។ លោកបាននិយាយថាមានអ្នកចូលរួមប្រហែលជា៥០០នាក់។ តើមនុស្សដែលចូលរួម ៥០០នាក់ហ្នឹង អាចអង្គុយនៅក្នុងសាលាខេត្តបានទាំង -- បានពេញ ឬមួយក៏មានអ្នកដែលឈរខាងក្រៅ ឬក៏នៅខាងក្រៅ ហៀរមកខាងក្រៅអីដែរឬទេ?

**ឆ៖** ៥០០នាក់នេះគឺមិនចូលពេញទាំងអស់ទេ មានខាងក្រៅ នៅខាងក្រៅខ្លះ។ ប៉ុន្តែខាងក្រៅៗបំផុតនោះគឺយាមកាមដោយខ្មែរក្រហម។

**ស៖** តើការប្រជុំហ្នឹងមានរយៈពេលប្រហែលជាប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃអីដែរ មុនពេលដែលអ្នកដែលចូលរួមហ្នឹងបានចាកចេញទៅវិញ?

[០៩:៥៩:០៨]

**ឆ៖** នៅពេលដែលគេប្រជុំនោះប្រហែលជា ២ទៅ៣ម៉ោង គេបានឯកភាពគ្នាក្នុងការឲ្យបងប្អូនទាំងអស់ រដ្ឋការស៊ីវិលទាំងអស់ ស្អែកឡើងធ្វើការជួបជុំគ្នាៗដើម្បីបញ្ជូនៗបន្តបន្ទាប់ទៅជួបអង្គការគឺខុសគ្នា១ថ្ងៃ។ គេណាត់គ្នា ស្អែកឡើងគឺឡានទទួលចេញពីខេត្តហ្នឹងទៅដើម្បីទៅទួលពោធិ៍ជ្រៃហ្នឹងឯង។

**ស៖** តើលោកអាចរៀបរាប់អំពីខ្លឹមសារនៃការប្រជុំហ្នឹងដែរឬទេ? ដោយសារតែលោកថាការប្រជុំហ្នឹងមានរយៈពេលប្រហែល២ទៅ៣ម៉ោង។ ហើយលោកបានប្រាប់អ្នកស៊ើបអង្កេតថា ខ្លឹមសារនៃប្រជុំហ្នឹង គឺដើម្បីឲ្យទៅទទួលអង្គការនៅទួលពោធិ៍ជ្រៃ។ តើគេនិយាយអ្វីខ្លះនៅក្នុងរយៈពេល២ទៅ៣ម៉ោងក្នុងការប្រជុំនោះ?

**ឆ៖** ក្នុងការប្រជុំនោះ គេបំពាក់បំប៉ន់និយាយអំពីអ្វីដែលជានយោបាយដែលបានបង្រួបបង្រួមគ្នាបានជួបគ្នាខ្មែរនិងខ្មែរហ្នឹង គេនិយាយអ៊ីចឹង។ ហើយនិងពីការកសាងប្រទេស ហើយចុងក្រោយបំផុតក៏គេបាននិយាយអំពីថាធ្វើម៉េចឲ្យយើង ថាស្មារតីយើងទុកចិត្តៗក្នុងការដែលទៅទទួលហ្នឹង។ ហ្នឹងគឺជាវិធីសាស្ត្ររបស់ពួកគេ ដែលគេធ្វើឲ្យយើងទុកចិត្ត។ ទៅទទួលយ៉ាងណាៗនោះ គឺគេណាត់យើង។ និយាយរួមគឺយើងពុំបានដឹងអំពីអ្វីដែលជាព្រឹត្តិការណ៍ខាងមុខនោះទេ គឺពេលនោះ ហាក់ដូចជា មានការឯកភាពគ្នាក្នុងការទៅទទួលនោះឯង។

[១០:០១:២៣]

**ស៖** តើអ្នកណាបានចូលរួមនៅក្នុង ចូលជាមួយការប្រជុំហ្នឹងដែរ? តើលោកនិយាយថា គេចាំទទួលទៅទួលពោធិ៍ជ្រៃ ប៉ុន្តែខ្ញុំចង់ដឹងថា តើទួលពោធិ៍ជ្រៃហ្នឹងមានចម្ងាយប្រហែលជាប៉ុន្មានគីឡូម៉ែត្រដែរពីសាលាខេត្តហ្នឹង?

**ឆ៖** ទួលពោធិ៍ជ្រៃប្រហែលជា២០គីឡូ ចាក់ទៅក្រោមទៅស្រុកកណ្តៀង ចេញពីទីរួមខេត្ត។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានពិស្តារបន្តិចទេ ថាតើគេនឹងត្រូវមានហេតុការណ៍អីនៅទួលពោធិ៍ជ្រៃ តើលោកបានឮគេប្រាប់ថា ទៅទីនោះដូចម្តេចទេ?

**ឆ៖** នៅពេលដែលគេប្រមូលទៅទួលពោធិ៍ជ្រៃ គេប្រាប់ថាឲ្យទៅទទួលអង្គការហ្នឹង។ សូម្បីតែរូបខ្ញុំផ្ទាល់ក៏បានឯកភាពជាមួយគេទៅដែរ ប៉ុន្តែខ្ញុំកាក់ឡានពាក់កណ្តាលផ្លូវ នៅពេលដែលគេដាក់ចំនួនមនុស្សចេញទៅហើយ ដំណើរទៅខាងក្រោមចេញពីទីរួមខេត្តទៅទួលពោធិ៍ជ្រៃនោះឯង គឺខ្ញុំឡើងទៅតាមឡានគេ គេមិនឲ្យឡើងទេ ព្រោះអីចង្អៀតណែនណាន់តាន់តាប់ឲ្យខ្ញុំទៅតាមក្រោយ ពេលវគ្គក្រោយ។ ប៉ុន្តែដំណាក់កាលដែលទៅដល់ទួលពោធិ៍ជ្រៃ ខ្ញុំពុំបានឃើញទេ ប៉ុន្តែក្រោយ៣ថ្ងៃមក ខ្ញុំបានឮព័ត៌មានថាគេយកទៅសម្លាប់។

[១០:០៣:២២]

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរលោកសំណួរមួយចំនួនទៀត អំពីថាតើក្រោយពីហ្នឹងមក តើលោកដឹងថាគេសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃដោយរបៀបណា? យើងអាចនឹងនិយាយឲ្យយឺតបន្តិចដើម្បីឲ្យយើងយល់កាន់តែច្បាស់។ នៅពេលដែលលោកនៅក្នុងការប្រជុំនោះ គេប្រាប់លោកថា “គេអញ្ជើញឲ្យទៅជួបអង្គការនៅទួលពោធិ៍ជ្រៃ”។ តើកាលណោះ លោកដឹងទេថាតើអង្គការជាអ្នកណាទេ នៅពេលដែលលោកឮដំបូងនោះ ឮពេលនោះ?

**ឆ៖** បាទ អរគុណណាស់ពីបញ្ហានេះ។ ខ្ញុំនិយាយរួមរំឭកឡើងវិញនូវពាក្យ “អង្គការ” នេះ។ ផ្នែកខាងយើងដែលធ្វើការនៅខាងរដ្ឋការស៊ីវិល ឮសួរអង្គការហ្នឹង មិនដែលឮទេ ទើបឮពេលដែលខ្មែរក្រហមចូលមកកាន់កាប់។ គេប្រាប់ថាឲ្យជួបអង្គការ យើងចង់ស្គាល់ ចង់ឃើញណាស់ ដើម្បីគំនិតមួយចង់ថាពេលដែលខ្មែររួបរួមហើយ យើងចង់ជួបធ្វើម៉េចដើម្បីកសាងប្រទេសនោះ ចង់ទៅជួបណាស់អាហ្នឹងគេរៀនម៉េច អីម៉េច។ ហ្នឹងខ្ញុំជាទស្សនៈខ្ញុំតែម្តង ពុំដែលបានស្គាល់ទេ អង្គការហ្នឹង។

[១០:០៤:៤៩]

**ស៖** តើលោកគិតថា អង្គការជាមនុស្ស ឬក៏ជាក្រុមមនុស្ស កាលណោះ?

**ឆ៖** និយាយរួមគឺខ្ញុំមិនយល់អង្គការហ្នឹង បានចង់ឃើញ ចង់ដឹង។ បានជាមានចិត្តចង់ទៅនឹងគេ។

**ស៖** ក្នុងឋានៈលោកជាទាហាន លន់ នល់ ដែលជាអ្នកវៃប្រយុទ្ធជាមួយនឹងខ្មែរក្រហម ពួកកម្លាំងខ្មែរក្រហម តើលោកមានការភ័យខ្លាចទេនៅពេលនោះ នៅពេលដែលរួមប្រជុំនោះ? ឬក៏ថាតើលោកយល់ឃើញថា ជារឿងសុទិដ្ឋិនិយម យល់ត្រូវរហូតថា គឺនឹងមានសន្តិភាព នឹងមានការកែប្រែក្នុងសង្គម នៅពេលលោកចូលរួមប្រជុំនោះ តើលោកគិតដូចម្ដេច យល់ឃើញដូចម្ដេចនៅពេលដែលឮថាមានការអញ្ជើញឲ្យទៅចូលរួមប្រជុំ ឲ្យមានការផ្សះផ្សាគ្នាជាមួយអង្គការហ្នឹង? និយាយពីអារម្មណ៍ ការយល់ឃើញរបស់លោក។

[១០:០៦:០២]

**ឆ៖** ការជិនណាយនៃការធ្វើសង្គ្រាម ជាទស្សនៈរបស់ពួកខ្ញុំ ឮសូរតែសន្តិភាពហ្នឹងចង់បានមហាសាលហើយ។ ដូច្នេះព្រឹត្តិការណ៍ពេលនោះ ខ្ញុំនៅមានតាំងអារម្មណ៍ថា នឹងអាចឈានដល់ព្រឹត្តិការណ៍ដែលយើងកាត់ស្មានមិនបានទេ។ នៅតែសុទិដ្ឋិនិយមថា ខ្មែរនឹងខ្មែរ។

**ស៖** ហើយនៅក្នុងពេលប្រជុំប្រហែលជា២ម៉ោង ឬលើសពីហ្នឹង តើលោកបានសុន្ទនា ឬក៏និយាយជាមួយទាហាន លន់ នល់ ផ្សេងទៀតទេ? ហើយប្រសិនបើលោកបាននិយាយ តើលោកអាចជម្រាបខ្ញុំ និងតុលាការអំពីចំណាប់អារម្មណ៍ពីអ្វីដែលពួកគេហ្នឹងគិតដូចម្ដេចអំពីស្ថានភាពហ្នឹងដែរឬទេ? តើពួកអ្នកផ្សេងទៀត មានការភ័យខ្លាច ឬក៏មានសុទិដ្ឋិនិយមដូចលោកដែរឬទេ? ឬក៏លោកអាចបញ្ជាក់អ្វីបានលើសពីនេះដែរឬទេ?

**ឆ៖** ភាគច្រើនគឺមានទស្សនៈដូចខ្ញុំៗ បានជាហេតុធ្វើឲ្យគេប្រមូលគ្នាមកជួបជុំចង់ជួបអង្គការនោះឯង។

[១០:០៧:៣៤]

**ស៖** សូមអរគុណ។ ឥឡូវនេះ ដើម្បីឲ្យតុលាការយល់អំពីរឿងនេះឲ្យច្បាស់ ថាតើនៅទួលពោធិ៍ជ្រៃនោះ លោកៗដឹងថាទីតាំងនៅកន្លែងណាទេ នៅទួលពោធិ៍ជ្រៃហ្នឹង? តើមានអគារ ឬក៏មានទីកន្លែងអ្វីដែលលោកអាចកត់សម្គាល់បានថាជាទីតាំងទួលពោធិ៍ជ្រៃទេ មុនពេលប្រជុំនោះបាទ?

**ឆ៖** នៅព្រឹត្តិការណ៍ដែលពេលប្រជុំនោះ គឺខ្ញុំខ្លួនខ្ញុំផ្ទាល់មិនបានដឹងថាទួលពោធិ៍ជ្រៃហ្នឹងយ៉ាងម៉េចទេ។ អត់ដឹងទេ។

**ស៖** តើមានមូលដ្ឋានទាហាន លន់ នល់ នៅទីនោះទេ នៅទួលពោធិ៍ជ្រៃ?

**ឆ៖** តាមខ្ញុំដឹងក្រោយមកទៀត បានដឹងថាទីជិតៗទួលពោធិ៍ជ្រៃហ្នឹងមានទីតាំងទាហាន លន់ នល់។

**ស៖** តើមានទាហានប៉ុន្មាននាក់ដែលឈរជើងនៅកន្លែងនោះ? តើលោកបានដឹងទេ ដែលថាមានបន្ទាយរបស់ លន់ នល់ នោះ?

**ឆ៖** ប្រហែលជាបើនិយាយពីភាសាទ័ព គេថាក្រុម -- គ្រុប ប្រហែលជាបីគ្រុបហ្នឹង -- មួយ *ស៊ិចស្យុង* ហ្នឹង។ កាលហ្នឹងគេថា អាវ៉ង់ប៉ុស្តិ៍ៗ គេថាជួរមុខ ទីតាំងហ្នឹងសម្រាប់ជួរមុខ។

[១០:០៩:៣៨]

**ស៖** តើមានក្រុមដែលថាបីក្រុមនោះ តើមានមនុស្សប្រហែលប៉ុន្មាននាក់ តាមដែលលោកដឹង?

**ឆ៖** បីក្រុមប្រហែលជា៣០ៗទៅ៤០។

**ស៖** ខាងដើមនោះ លោកបាននិយាយថា មុនពេលខ្មែរក្រហមចូលមកកាន់កាប់ខេត្តពោធិ៍សាត់ គឺមានសមរភូមិនៅទូទាំងខេត្ត" ហើយមុនខែមេសា ថ្ងៃទី១៧ ឆ្នាំ១៩៧៥ នោះ តើលោកដឹងដែរឬទេថា តើនៅទួលពោធិ៍ជ្រៃនោះគឺថាមុនពេលដែលខ្មែរក្រហមកាន់កាប់អំណាចនោះ តើមានការប្រយុទ្ធគ្នានៅកន្លែងហ្នឹងដែរឬទេ? បាទ ប្រសិនជាលោកដឹង លោកប្រាប់ថាដឹង បើមិនដឹងទេលោកសូមលោកឆ្លើយបែបនោះ។

**ឆ៖** តាមខ្ញុំដឹងៗ ទីតាំងកន្លែងនេះជាសមរភូមិប្រយុទ្ធយ៉ាងក្តៅបំផុតរវាងភាគីខ្មែរក្រហម និងទាហាន លន់ នល់។

**ស៖** តើសមរភូមិតាមអ្វីដែលលោកដឹងហ្នឹងគឺថា តើសមរភូមិរវាងមនុស្សដែលឃោធា ទាហាន ៣០នាក់ហ្នឹងគឺថាជាសមរភូមិរវាងទាហាន លន់ នល់ ហើយនិងភាគីម្ខាងទៀត ឬយ៉ាងម៉េច?

**ឆ៖** កន្លែងទីតាំងរបស់ លន់ នល់ នេះគឺជាជាប់ហៅថា គឺថាចែកតំបន់ៗរវាង លន់ នល់ ហើយនិងខ្មែរក្រហម តំបន់កាន់កាប់។

**ស៖** តើលោកដឹងដែរឬទេថា តើមានទាហានប៉ុន្មាននាក់ដែរឈរជើង ហើយនិងប្រយុទ្ធនៅសមរភូមិនេះមុនពេលដែលខ្មែរក្រហមចូលកាន់កាប់ពោធិ៍សាត់នោះ?

[១០:១២:០៧]

**ឆ៖** ប្រហែលជាខ្ទង់៣ក្រុមហ្នឹងឯងៗ ដែលគេដាក់ប៉ុស្តិ៍អ៊ីស្វឡេ គេហៅថា អាវ៉ង់ប៉ុស្តិ៍ ជាការបញ្ឆោតនៅពេលដែលជួបព្រឹត្តិការណ៍ខ្មែរក្រហមមកប៉ះពាល់ហ្នឹងៗគេរៀបចំជាដំណឹង បើថាអាវ៉ង់ប៉ុស្តិ៍។

**ស៖** សូមអរគុណ។ ហើយនិយាយអំពីយោធាដែលថា ២០០នោះដែលលោកនិយាយថាចូលរួមនៅសាលាខេត្តនោះ តើលោកអាចនិយាយថា មាន៣០មកពីទួលពោធិ៍ជ្រៃបានចូលរួមនៅកន្លែងនោះដែរឬទេ?

**ផ៖** សូមសំណួរម្តងទៀត។

**ស៖** លោកបាននិយាយថាមានទាហាន៣០នាក់នៅទួលពោធិ៍ជ្រៃកាលណោះ។ តើលោកដឹងថាតើអ្នក៣០នាក់នោះបានមកចូលរួមនៅសាលាខេត្តដែលលោកបានចូលរួមនោះដែរឬទេ?

[១០:១៣:៣១]

**ផ៖** ពិតជាបានមកចូលរួម។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងមើលកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលយើងនិយាយអំពីពេលចប់ការប្រជុំនោះ សូមដកស្រង់ គឺអង់គ្លេសគឺ 00242126, ខ្មែរ 00196811 ដល់ 12, បារាំង 00274132។ លោកបាននិយាយថា៖ "លោកបន្តពីការប្រជុំនោះទៀត ហើយលោកនិយាយថា នៅពេលនោះគេឲ្យមេៗនៅខេត្តពោធិ៍សាត់ ចៅហ្វាយខេត្ត លន់ នល់ ទាហាន និងនិស្សិតទាំងអស់ឲ្យឡើងឡានដើម្បីទៅទទួលអង្គការ។ ឡានដែលដឹកពួកអ្នកទាំងនោះគឺឡានពណ៌ស ដែលផលិតនៅប្រទេសអូស្ត្រាលីចំនួន១៣ ទៅ១៥គ្រឿង។ មានគ្នាប្រហែល៥០០នាក់ដោយមានលោក ព្រំ លីហួន ផងឡើងឡានទៅទួលពោធិ៍ជ្រៃ។ ដោយឡានចង្អៀតពេក គេក៏ឲ្យខ្ញុំចុះសិន ដោយគេប្រាប់ថាចាំឡើងឡានក្រោយ។ អ្នកដែលមិនទាន់ទៅ គឺនៅមានច្រើនដែរ"។

ខ្ញុំចង់សួរសំណួរមួយចំនួនអំពីរឿងនេះ នៅលោកនិយាយថា គឺថាភ្លាមៗបន្ទាប់ពីការប្រជុំនោះ គឺថាទាហាន សិស្ស និងអតីតរដ្ឋការដែលចូលរួមប្រជុំនោះ គឺថាប្រជុំចប់ភ្លាមគេឲ្យឡើងឡាននោះឯង។ ប៉ុន្តែនៅខាងដើមនោះ លោកនិយាយថា ការប្រជុំនោះបានចប់នៅថ្ងៃបន្ទាប់ទើបគេឲ្យមនុស្សត្រឡប់នោះ -- មនុស្សទាំងនោះត្រឡប់ទៅនឹងសាលាខេត្តឲ្យឡើងឡាន។ តើលោកអាចគិតឲ្យបានច្បាស់លាស់ដោយសារថាយូរហើយ អ៊ីចឹងសួរលោកថា តើប្រជាជន -- ទាហានទាំងអស់នោះ គឺគេឲ្យឡើងឡានភ្លាមៗបន្ទាប់ពីប្រជុំចប់ ឬក៏១យប់ ព្រឹកស្អែកឡើងបានគេឲ្យមកឡើងឡាន? បាទ ប្រហែលជាលោកមិនអាចចាំច្បាស់ ប៉ុន្តែសូមលោកបំភ្លឺពីករណីនេះ ដើម្បីឲ្យអង្គជំនុំជម្រះអាចនឹងយល់បានច្បាស់បាទ។

[១០:១៦:៣៣]

**ផ៖** ព្រឹត្តិការណ៍នេះ បើតាមខ្ញុំដឹង ការប្រជុំគ្នាដែលទទួលអង្គការហាក់ដូចជាមានដំណើរការ

យូរមកហើយ ប្រហែលជាយូរមកហើយត្រង់ការទទួលអង្គការនោះ ប៉ុន្តែសភាពការណ៍ដែលឡើងឡាន ថ្ងៃនោះ គឺគេប្រជុំហើយ គឺទាហានក៏មកជួបជុំគ្នាអស់ហើយស្រេច ជួបជុំគ្នាអស់ហើយស្រេច គឺឡើងឡានភ្លាមៗក្រោយពេលប្រជុំហ្នឹងឯង ខ្ញុំនិយាយនេះបាទ។ អ៊ីចឹងទៅថ្ងៃដែលឡើងឡានហ្នឹងគឺមានការប្រតប់ប្រតាយគ្នាច្រើនណាស់ដែលអ្នកចង់ទៅហ្នឹង គឺច្រើនណាស់បាទ។ ហើយឡានមិនអាចទទួលបាន ឡាននោះវាចង្អៀតពេក។ អ៊ីចឹងទេការប្រជុំនេះ គឺប្រជុំភ្លាមគឺឡើងឡាន មកជួបជុំគ្នាច្រើន។ សូម្បីទៅតាមផ្លូវក៏មានអ្នកឈរចាំឡើងបន្តបន្ទាប់។

ដោយឡែក ដែលខ្ញុំថាកាក់ឡាននោះ គឺការប្រជុំហើយៗ ខ្ញុំចេញខាងក្រៅគេ ដើម្បីកាក់ខាងក្រៅនេះ មិនអាចចូលបានជាមួយគេទេ ព្រោះអីសភាពការណ៍ពេលហ្នឹងគឺភាគច្រើនណាស់ដែលឡើងឡានចង់ទៅជាមួយ។ អ៊ីចឹងទេ យើងប្រជែងគ្នាទៅ ហើយឡានដឹកមនុស្សទៅហ្នឹង គឺខ្លះរត់តាម ខ្លះអីអ៊ីចឹងទៅ ខ្ញុំនេះក៏គេប្រទាញដៃទម្លាក់មកវិញ។ អ៊ីចឹងគឺជាថ្ងៃព្រឹត្តិការណ៍ហ្នឹង គឺជាថ្ងៃដែលប្រជុំហើយ គឺឡើងឡានចេញបណ្ដោយ។ ប៉ុន្តែសភាពការណ៍ដែលខ្ញុំបញ្ជាក់ជូនមុននេះ គឺថាប្រហែលជាគេដឹងសភាពការណ៍ហើយ ខ្ញុំក៏បានដឹងដែរពីបញ្ហាដែលត្រូវទទួលអង្គការនោះបាទ។ សូមបញ្ជាក់ផងដែរ អ្នកដែលទៅហ្នឹងគឺត្រៀមបាយកញ្ចប់រៀងៗខ្លួន។ បាទ អរគុណ។

[១០:១៨:៣៣]

**ស៖** សូមអរគុណ ហើយខ្ញុំយល់ច្បាស់ហើយ លោកបាននិយាយថា គឺមានការប្រជុំពីរដងនៅសាលាខេត្តនោះ។ មួយគេបានពិភាក្សាពីបញ្ហាហ្នឹង ហើយនៅថ្ងៃបន្ទាប់គឺមានការប្រមូលផ្តុំប្រជុំមួយ គឺភ្លាមៗបន្ទាប់ពីមនុស្សប្រមូលផ្តុំហើយ ប្រជុំហើយ គឺគេបញ្ជូនឲ្យមនុស្សឡើងឡាន។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ។

**ស៖** តើលោកបានចូលរួមនៅក្នុងប្រជុំទាំងពីរហ្នឹង ឬក៏ការប្រជុំតែមួយដែលថា ប្រជុំចប់ភ្លាមគេឲ្យឡើងឡាន? តើអ៊ីចឹងទាំងពីរ ឬក៏ណាមួយ?

**ឆ៖** គឺខាងក្រោយគេបំផុតដែលខ្ញុំឡើងឡានហ្នឹង ជាមួយគេ។

**ស៖** ដើម្បីឲ្យច្បាស់ លោកបានចូលរួមប្រជុំតែមួយទេក្នុងចំណោមទាំងពីរហ្នឹង ឬក៏ប្រជុំទាំងពីរ? សូមលោកបញ្ជាក់ម្តងទៀត។

**ឆ៖** ការចូលរួមលើកមុនដែលថា គេប្រជុំនេះ គ្រាន់តែទទួលព័ត៌មានទេ ប៉ុន្តែការទទួលព័ត៌មាននេះវាមិនឆ្ងាយទេ ខ្ញុំមិនចូលរួមជាមួយលើកទី១ទេ ប៉ុន្តែចាំស្តាប់ព្រឹត្តិការណ៍ដែលគេធ្វើពីអ្វី ហ្នឹងតៗគ្នា

មក គេប្រាប់អ៊ីចឹងថាទៅទួលពោធិ៍ជ្រៃ។ អ៊ីចឹងទេបានជាថ្ងៃប្រជុំទី២នេះ គឺយើងត្រៀមខ្លួនស្រេចដែល បម្រុងមកជាមួយគេហ្នឹងឯង។ ប៉ុន្តែព្រឹត្តិការណ៍អ្វីដែលយើងដឹង គឺយើងដឹងទាំងអស់ពីបញ្ហាហ្នឹង។ នៅសភាពការណ៍នៅខេត្តហ្នឹង គឺមិនរំលងពីអ្វីដែលយើងតាមដាននោះទេ។

[១០:២០:៤០]

**ស៖** សូមអរគុណ។ តាមភស្តុតាងដែលលោកបានបញ្ជាក់ព្រឹកមិញនេះ គឺយើងឃើញថា លោកនិយាយថាមនុស្សភាគច្រើនជាទាហាន ជាអីហ្នឹង គឺថាគាត់ចង់ឡើងលើឡានហ្នឹង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ជាការពិត។

**ស៖** លោកបាននិយាយថាប្រហែលជាមានមនុស្ស៥០០នាក់នៅក្នុងការប្រជុំនោះ មុនពេលដែលគេឡើងទៅលើរថយន្តធំនោះ។ តើមានមនុស្សនៅសល់ប៉ុន្មាននាក់ ហើយមិនបានឡើងនៅក្នុងជើងទី១ហ្នឹង ដូចរូបលោកផងដែរ។ លោកអាចប្រមាណបានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសហព្រះរាជអាជ្ញាមិនអះអាងទៅតាមភស្តុតាងពីខាងដើមឲ្យត្រឹមត្រូវទេ សាក្សីគាត់និយាយថាប្រជុំដំបូងនោះមានមនុស្ស៥០០នាក់ ហើយគាត់មិនដឹងថាប្រជុំទី២មានមនុស្សប៉ុន្មានទេ។ អ៊ីចឹងយើងត្រូវឲ្យច្បាស់អំពីពីអ្វីកើតឡើងនៅប្រជុំទី១ និងការប្រជុំទី២។ ខ្ញុំយល់ថាសហព្រះរាជអាជ្ញាឲ្យព័ត៌មានទាំងពីរហ្នឹងច្រឡំគ្នា។ អ៊ីចឹង គឺថាឲ្យសួរសំណួរឲ្យដាក់លាក់ក្នុងប្រជុំនីមួយៗហ្នឹងជាជាងរួមគ្នាទាំងពីរ។

[១០:២២:១៤]

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំឆ្លើយតបដោយសង្ខេប។ សាក្សីបាននិយាយថាមនុស្ស៥០០នាក់បានចូលរួមប្រជុំទី១ ហើយប្រជុំទី២ ពួកគេហ្នឹងក៏បានត្រឡប់មកវិញ។ អ៊ីចឹងហើយខ្ញុំគិតថាសាក្សីបានសំដៅទៅរកមនុស្សទាំង៥០០នាក់ហ្នឹង។ អ៊ីចឹងដើម្បីឲ្យច្បាស់លាស់ ខ្ញុំនឹងសួរគាត់ឲ្យច្បាស់លាស់ថាតើប្រជុំទី២មានមនុស្សប៉ុន្មាននាក់ចូលរួម។ ហើយខ្ញុំគិតថាគាត់នឹងឆ្លើយប្រហាក់ប្រហែល ឬក៏ដូចគ្នា។

**សួរដោយលោក វិល្លៀម ស្មីត៖**

**ស៖** លោកសាក្សី លោកបានស្តាប់ពីហ្នឹងហើយ គឺថាការប្រជុំទី១ វាមានមនុស្ស៥០០នាក់ដែលថាប្រហែលជា២០០នាក់ក្នុងចំណោមនោះ គឺជាទាហានៗ លន់ នល់។ ហើយលោកបានស្គាល់អ្នកទាំងនោះខ្លះផង។ ហើយនៅក្នុងការប្រជុំទី២ តើលោកអាចប្រាប់តុលាការបានទេថា តើមានមនុស្សប៉ុន្មាននាក់ដែលចូលរួម ឬក៏ទៅប្រមូលផ្តុំគ្នានៅក្នុងការប្រជុំទី២នោះ?

[១០:២៣:២៣]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ចំនួនការប្រជុំទី២ មិនលើសគ្នាពីប្រជុំទី១ទេ ប្រហាក់ប្រហែល។

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ លោកនិយាយថាឡាននោះចង្អៀតពេកគេឲ្យខ្ញុំចុះសិនរង់ចាំឡានលើកក្រោយ ហើយមានចំនួនច្រើនដែលឡើងឡានទៅមិនទាន់។ តើលោកអាចប៉ាន់ប្រមាណនោះថាមានមនុស្សប៉ុន្មាននាក់ដែលមិនឡើងឡានទាន់ជើងទី១ ដូចរូបលោកដែរនោះ?

**ឆ៖** ខ្ញុំពុំអានប៉ាន់ប្រមាណត្រឹមត្រូវទេ គ្រាន់តែដឹងថាមានភាគខ្លះ មានភាគខ្លះដូចខ្ញុំដែរ។ ប៉ុន្មានៗខ្ញុំមិនអាចសន្និដ្ឋានបានដែរ ព្រោះសភាពការណ៍នោះវាច្របូកច្របល់ដែរ បញ្ហាប្រទាញប្រទែង។

**ស៖** លោកនិយាយទៅអ្នកស៊ើបសង្កេតថា គឺថាមានឡានពី១៣ ទៅ១៥គ្រឿង អ៊ីចឹងថាតើលោកឃើញថាឡានមួយៗដឹកមនុស្សបានប៉ុន្មាននាក់ នៅក្នុងជើងទី១ ដែលឡានចេញទៅនោះ?

**ឆ៖** ឡានទីមួយតាមខ្ញុំឃើញមិនអាចប៉ាន់ស្មានទេគឺណែនតែម្តង ណែនរហូតដល់ចង្អៀតគ្នា ខ្លះប្រទាញប្រតោងបានតែសកម្មភាពបេះដៃបេះអីចេញ គឺណែន។

**ស៖** បើសិនជាលោកមិនអាចបញ្ជាក់ទេ ក៏ហីទៅចុះ។ ប៉ុន្តែបើសិនជាលោកអាចស្មានបានថាតើដែលថាមនុស្សឡើងណែនឡានមួយៗនោះប្រហែលជាប៉ុន្មាននាក់តាមដែលលោកស្មាន ឃើញនោះ?

[១០:២៥:៤៣]

**ឆ៖** ត្រង់នេះលោកអាចគណនាបានគឺទ្រុងឡាន ឡានរបៀបឡានអូស្ត្រាលីអំណោយរបស់អូស្ត្រាលីអាទ្រុង មានទ្រុងសំណាញ់នោះ តើអាចប៉ុន្មានគឺលោកអាចដឹងដែរ ខ្ញុំមិនបាច់បញ្ជាក់ថាប៉ុន្មាននោះទេយើងអាចប៉ាន់ស្មានទាំងអស់គ្នា គឺឡានអំណោយរបស់អូស្ត្រាលីពណ៌ស សំណាញ់សងខាងធំ ដែរមិនតូចទេ។

**ស៖** តើលោកអាចប៉ាន់ប្រមាណថាមានមនុស្សប៉ុន្មាននាក់ដែលឡើងទៅឡានទីមួយៗ គ្រាន់តែ

ស្មានតាមការយល់ដឹងរបស់ខ្លួនជាចំនួន? សូមឲ្យលោកបញ្ជាក់ប៉ាន់ប្រមាណជាចំនួនមនុស្សក្នុងឡាននីមួយៗ?

**ឆ៖** ពី៥០ទៅ៦០ អាច។

**ស៖** ហេតុអ្វីបានលោកនៅចាំច្បាស់ថារថយន្តធំហ្នឹងជារថយន្តធ្វើនៅប្រទេសអូស្ត្រាលី ម៉េចក៏លោកចាំច្បាស់?

**ឆ៖** ខ្ញុំចាំច្បាស់ដោយសារអំណោយហ្នឹង គឺអំណោយហ្នឹង គឺអំណោយផ្នែកខាងយោធាគឺអំណោយអូស្ត្រាលី ឡានហ្នឹងឯង។

[១០:២៧:៤០]

**ស៖** សូមអរគុណ។ និយាយពីទិសដៅ តើលោកបានឃើញរថយន្តធំនោះចាកចេញពីសាលាខេត្ត តើគេចាកចេញមួយម្តងៗ ឬក៏គេចាកចេញជាក្បួនម្តងមួយជួរទៅ ហើយគេឆ្ពោះទៅទិសដៅត្រង់ណាដែលគេបរចេញទៅនោះ?

**ឆ៖** ចំពោះរថយន្តដែលគេបរចេញទៅពីសាលាខេត្តនោះ គឺគេតម្រៀបគ្នាបន្តបន្ទាប់គ្នាដោយមានភាពប៉ោកប្រៀវផង។ ចេញពីសាលាខេត្តទៅតាមដងស្ទឹងពោធិ៍សាត់ចាក់ទៅខាងក្រោមឆ្ពោះទៅទួលពោធិ៍ជ្រៃ។ គឺដង្ហែគ្នាមិនមែនទៅម្តងមួយៗទេ ចេញពីពោធិ៍សាត់គឺជាប់ៗគ្នា។

**ស៖** លោកនិយាយថាលោកមិនអាចឡើងឡានបានទេដោយសារចង្អៀតពេក។ លោកបានបញ្ជាក់ពីព្រឹកមិញនេះថា លោកបានព្យាយាមឡើងប៉ុន្តែគេច្រានចេញវិញ។ តើលោកអាចពន្យល់តុលាការបានទេ ថាតើលោកបានឡើងឡានក្នុងចំណោមជើងទី១នោះគឺថាបានព្យាយាមឡើងឡានទៅមួយ ហើយកាលណាឡើងមិនបានគឺនៅចាំសិន ឬក៏លោកធ្វើដូចម្តេច?

[១០:២៩:២៩]

**ឆ៖** សូមជម្រាបថានៅព្រឹត្តិការណ៍ពេលនោះគឺប្រហែលជាខ្ញុំឡានទី៧ ឬក៏ទី៨ ដែលខ្ញុំសុំគេឡើងឡាន ប៉ុន្តែគេច្រានមកវិញ។ បន្តបន្ទាប់នៅតែឡានក្រោយទៀត ឡានក្រោយក៏គេមិនឲ្យ រហូតដល់ចុងបញ្ចប់ គឺមិនមែនប៉ងតែឡានមួយទេ ឡានណាក៏ចង់ទៅដែរឲ្យតែបាន គឺគេមិនឲ្យទៅ គឺពេញណែនទាំងអស់។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មម

សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះដប់នាទី រួមទាំងមេធាវីប្រឹក្សាផង។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣០នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ នៅពេលដែលយើង -- មុននឹងយើងសម្រាក គឺលោកនិយាយថាមានប្រហែលជាឡានប្រាំពីរ ឬក៏ឡានទី៨ ដែលលោកចង់ឡើងជិះ ប៉ុន្តែគេមិនឲ្យលោកឡើងជិះ ហើយគេរុញលោកចុះ។ ហើយគេប្រាប់លោកថាចាំឡានក្រោយសឹមឡើង ហើយលោកនិយាយថាលោកមិនចង់ជិះតែមួយ គឺថាឲ្យតែមានជិះគឺលោកឡើងជិះហើយ ប៉ុន្តែគេអត់ឲ្យលោកឡើងជិះ។ តើលោកមានចាំដល់ពេលក្បួនឡានចុងក្រោយ ឬមួយក៏លោក -- ថាតើលោកចាំឡានក្បួនឡានចុងក្រោយ ឬមួយក៏លោកដើរទៅកន្លែងផ្សេងឈប់ចាំឡាន ក្បួនក្រោយ?

[១០:៥៣:២២]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** កាលណោះ គឺយើងខ្ញុំចាំរហូតដល់អស់ឡាន នៅតែមិនបានឡើងទៅ។

**ស៖** បន្ទាប់ពីឡានចុងក្រោយគេទៅហួសទៅ លោកអត់ឡើងជិះបាន ប៉ុន្តែខ្ញុំចង់សួរថាតើលោកធ្វើអី បន្ទាប់ពីឡានចុងក្រោយទៅផុតទៅ លោកទៅណា? ឬក៏លោកធ្វើអី?

**ឆ៖** ខ្ញុំបានត្រឡប់មកភូមិកំណើតវិញ ចូលមកភូមិកំណើតវិញ កាត់តាមភូមិ តាមផ្ទះមកក្រុមគ្រួសារវិញ។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបាននិយាយថា គេឲ្យលោកចាំ គឺរង់ចាំក្បួនក្រោយ។ ហើយលោកបាននិយាយថា លោក ហើយនិងទាហានដទៃទៀតហ្នឹង គឺចង់ទៅទួលពោធិ៍ជ្រៃ ដើម្បីទៅជួបអង្គការ។ ដូច្នេះ ខ្ញុំចង់សួរថាហេតុអ្វីក៏លោកមិនរង់ចាំក្បួនទី២ ដូចដែលគេប្រាប់លោកឲ្យចាំនោះ? តើហេតុអីក៏លោកមិនចាំ លោកគិតទៅផ្ទះវិញធ្វើអី?

[១០:៥៤:៥០]

**ឆ៖** ពុំមានក្បួនទី២ទៀតទេ ទៅមួយជើងហ្នឹងគឺចប់។ អ្នកដែលថា គឺចេះតែថាទេ គឺមួយជើងហ្នឹងចប់។ អត់មានឃើញរហូតរង់ចាំ អត់មានឃើញទេ។

**ស៖** ខ្ញុំគិតថាការគិតអំពីចំនួនវាពិបាកមែន ប៉ុន្តែខ្ញុំចង់ដឹងថាក្នុងចំណោមមនុស្ស៥០០នាក់ ដែលគេរង់ចាំហ្នឹង ដែលរង់ចាំជាមួយគ្នាហ្នឹង ហើយអត់អាចឡើងជិះឡានហ្នឹងបាន តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែលនៅចាំជាមួយលោក ហើយអត់បានឡើងជិះនោះ?

**ឆ៖** ខ្ញុំនៅចាំថា មិនជាច្រើនទេៗ ប្រហែលជា៥០ទៅ៦០នាក់ បើតាមខ្ញុំស្មាន។

**ស៖** លោកនិយាយថា នៅសាលាខេត្ត គឺមានទាហានខ្មែរក្រហមប្រហែលជា៥០ទៅ៦០នាក់នៅជុំវិញនោះ។ តើពួកទាហានខ្មែរក្រហមនៅជាមួយអ្នកដែលអត់បានទៅក្នុងក្បួនឡានហ្នឹង ឬមួយក៏ពួកទាហានខ្មែរក្រហមហ្នឹងទៅជាមួយក្បួនឡានដែលបើកទៅនោះ? តើខ្មែរក្រហម ទាហានខ្មែរក្រហមហ្នឹងនៅកន្លែងណា?

**ឆ៖** តាមខ្ញុំសង្កេតឃើញនៅក្នុងឡាននីមួយៗ គឺការដឹកនាំទទួលខុសត្រូវដោយខ្មែរក្រហមហ្នឹងឯង ដែលគេស្គាល់ទួល -- ទៅទទួលអង្គការ។ អ៊ីចឹងគេក្នុងឡាននីមួយៗមានខ្មែរក្រហមនុ៎ង ដឹកនាំទៅ។

[១០:៥៦:៥៨]

**ស៖** ចំពោះក្រុមនុស្សដែលនៅខាងក្រោយហ្នឹង គេមានយាមកាមក្រុមពួកលោក ដែលអត់បានទៅជាមួយគេហ្នឹងទេ?

**ឆ៖** ក្រុមដែលមិនបានទៅ គឺពុំមានឃើញមានអ្នកយាមកាមទេ។

**ស៖** តើលោករង់ចាំប្រហែលជាប៉ុន្មានម៉ោង ឬក៏ប៉ុន្មានថ្ងៃដែរ មុនពេលដែលលោកសម្រេចថាត្រឡប់ទៅផ្ទះវិញនោះ?

**ឆ៖** ភ្លាមៗនោះខ្ញុំរង់ចាំប្រហែលជា២ម៉ោងពុំមានឃើញអ្វីដែលជាព្រឹត្តិការណ៍ ឬក៏មានឡានក្រោយទៀត អត់ទេ។ មិនឃើញការត្រឡប់មកវិញទេ អត់។ យូរដែរ ព្រោះផ្លូវដែលត្រូវទៅហ្នឹង គឺមិនឆ្ងាយពីភូមិខ្ញុំប៉ុន្មានដែរ។ រង់ចាំរហូត គឺអត់ឃើញ។

**ស៖** នៅពេលដែលលោកចេញពីសាលាខេត្ត តើមនុស្សប្រហែលជា ៥០ទៅ៦០នាក់ដែលនៅជាមួយលោកហ្នឹង តើគេបន្តនៅចាំនៅសាលាខេត្ត ឬមួយក៏គេចេញទៅផ្ទះមុនលោក ឬក៏ដំណាលលោកដែរនោះ?

[១០:៥៨:២២]

**ឆ៖** សភាពកាលនោះ គឺធ្វើដូចៗគ្នា ខ្ញុំក៏ចេញគេក៏ចេញដែរ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ តើពួកលោកទាំងអស់គ្នាប៉ុន្មាននាក់ដែលនៅសល់ហ្នឹង គឺថាចេញក្នុងពេលជាមួយគ្នា ឬក៏ចេញក្នុងពេលមុនក្រោយ ខុសៗគ្នា?

**ឆ៖** អ្នកដែលនៅសល់គឺចេញប្រហាក់ប្រហែលគ្នា ចេញនៅពេលជាមួយគ្នា បែកទៅផ្ទះរៀងៗខ្លួន។

**ស៖** នៅក្នុងចម្លើយរបស់លោក គឺលោកប្រាប់អ្នកស៊ើបអង្កេតរបស់សាលាក្តី អ.វ.ត.ក គឺអង់គ្លេសមាន 00242126, ខ្មែរមានលេខ 00196812, និងភាសាបារាំងគឺមានលេខ 00274132។ គឺលោកបានបញ្ជាក់ថា “៣ថ្ងៃក្រោមមក ខ្ញុំដឹងថាខ្មែរក្រហមយកពួកគេទៅសម្លាប់នៅទួលពោធិ៍ជ្រៃ។ ខ្ញុំដឹងរឿងនេះពីព្រោះមានទាហានពីរនាក់ឈ្មោះ ផាត និង ដោ ដែលបានរត់រួច ហើយបន្លំខ្លួនមករស់នៅតាមភូមិបានប្រាប់ខ្ញុំ។ ពីរសប្តាហ៍ក្រោយ អ្នកទាំងពីរត្រូវបានពួកទាហានខ្មែរក្រហមតាមចាប់យកទៅសម្លាប់ចោល”។

ក្នុងចន្លោះពេលដែលលោកចាកចេញពីសាលាខេត្ត ដោយសារតែឡាន អត់មានឡានមកដឹកបន្តទៀតនោះ ហើយនិងពេលដែលលោកបានដឹងថា ដឹងព័ត៌មានពី ផាត ហើយនិង ដោ ហ្នឹង ថាមនុស្សទាំងអស់ហ្នឹងត្រូវបានគេយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃនោះ។ តើថាមុនពេលដែលលោកជួបហ្នឹង តើលោកគិតថាមានអ្វីកើតឡើងចំពោះទាហាន និងមនុស្សប៉ុន្មានរយនាក់ដែលទៅហ្នឹង?

[១១:០០:៣១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាគាត់អាចសួរសាក្សីអំពីអ្វីដែលកើតឡើងនៅពេលជាក់លាក់ណាមួយ ប៉ុន្តែក្នុងពេលជាមួយគ្នាហ្នឹង វាហាក់ដូចជាការស្នើសុំ ឬក៏ជាការឲ្យសាក្សីទាយស្មាន ព្រោះថាគាត់សួរថា សាក្សីអាចគិតថាមានអ្វីអាចកើតឡើង។ ដូច្នេះ ខ្ញុំគិតថាការសួរអំពីទស្សនៈរបស់សាក្សី សួរអំពីការគិតរបស់សាក្សីបែបនេះ វាហាក់ដូចជាការឲ្យសាក្សីទាយស្មាន។ ដូច្នេះ ខ្ញុំសូមស្នើថាអាចថាអង្គជំនុំជម្រះមេត្តាបង្គាប់ដល់សាក្សីឲ្យផ្តល់ចម្លើយតែអ្វីដែលគាត់បានឃើញ បានដឹង បានឮនៅពេលនេះ ប៉ុន្តែមិនឲ្យគាត់និយាយអំពីអ្វីដែលគាត់គិតថាអាចនឹងកើតឡើងនៅពេលនោះ។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំអាចបញ្ជាក់ទៅលើបញ្ហានេះបាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** តើលោកដឹងដែរ ឬទេថាមានអ្វីកើតឡើងចំពោះមនុស្សដែលឡើងជិះឡានមុនពេលដែលគេប្រាប់លោក គឺមុនពេលដែល ផាត ហើយនិង ដោ ប្រាប់លោកថាទាហានទាំងអស់ហ្នឹងត្រូវបានគេយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃនោះ?

[១១:០២:០៣]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ក្រោយពេលឮដំណឹងនេះ ខ្ញុំ ចំពោះខ្ញុំៗអត់មានទឹកអ្វីថាដល់ប៉ុណ្ណឹងទេ មិនសឹងជឿផង។ ប៉ុន្តែជាក់ស្តែងដែលធ្វើឲ្យដឹង គឺក្រោយ៣ថ្ងៃមក ឮព័ត៌មានអ៊ីចឹងហើយ និងមានហ្សឹមី គេហៅថាហ្សឹមី យើងឈូសដីហ្នឹងទៅជាក់ស្តែងដើម្បីទៅកាយលប់សពហ្នឹង។ នេះបានកាន់តែមានព្រឹត្តិការណ៍ហ្នឹង ខ្លួនឯងចេះតែច្បាស់ទៅៗ។ ហើយជាក់ស្តែងបំផុត គឺព័ត៌មាន ផាត ហើយនិង ដោ ហ្នឹងដែលផ្តល់ឲ្យយើងថាគេសម្លាប់អស់ហើយ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ត្រឡប់ក្រោយបន្តិច គឺទាក់ទងទៅនឹងឈ្មោះ ផាត ហើយនិង ដោ។ តើពួកទាហានទាំងពីរនាក់ហ្នឹងជាទាហានខ្មែរក្រហម ឬក៏ជាទាហាន លន់ នល់?

**ឆ៖** ជាជនរងគ្រោះគឺជាទាហានលន់នល់ ដែលសល់ពីការសម្លាប់ជាក់ស្តែងនៅទួលពោធិ៍ជ្រៃ។

**សៈ** តើលោកចាំទេ តើគេនិយាយយ៉ាងម៉េចប្រាប់លោក គឺពាក្យសម្ដីដែលគេនិយាយប្រាប់លោកហ្នឹង លោកចាំទេ? ហើយសូមលោកបញ្ជាក់ផង បើសិនជាលោកចាំ?

**ផៈ** គេបានបញ្ជាក់ប្រាប់អំពីវិធីសាស្ត្រដែលគេនាំទៅ ដោយទៅដល់ -- មិនទៅដល់កន្លែងទួលពោធិ៍ជ្រៃទេ ប្រហែលជានៅប្រហែល៥០០ ទៅ៧០០ម៉ែត្រ ឬក៏អាច១គីឡូ ខ្សែត្រៀមមុខ គឺត្រូវចុះពីលើឡានៗ ដើរចូលទៅជួបអង្គការ។ ប៉ុន្តែចូលទៅខ្សែទី២ ឬខ្សែទី៣។ ចូលខ្សែទី២គឺគេចងហើយ គេចង ចូលខ្សែទី៣ គឺចូលដល់រណ្ដៅដែលគេត្រូវបាញ់សម្លាប់។ តាមព័ត៌មានរបស់ ផាត និង ដោ បានបញ្ជាក់ប្រាប់ខ្ញុំឲ្យប្រុងប្រយ័ត្នខ្លួនទៀតផង។ ប៉ុន្តែក្រោយមកទៀត ប្រហែលជា២អាទិត្យមកដូចក្នុងសេចក្ដីកំណត់ហេតុ ដែលបញ្ជាក់ប្រាប់ គឺបាត់ខ្លួនពីរនាក់ហ្នឹងតែម្ដង។

[១១:០៤:៥៦]

**សៈ** ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ទៀត តើទាហានទាំងពីរនាក់ហ្នឹងប្រាប់លោកថាគេបានឃើញការសម្លាប់មនុស្សហ្នឹង ឬក៏អត់ទេ? តើគេមានប្រាប់លោកថាឃើញ ឬក៏អត់ទេ?

**ផៈ** អ្នកទាំងពីរគឺជាជនរងគ្រោះដែលត្រូវរួចពីកន្លែងសម្លាប់ជាក់ស្ដែង។ ដូច្នេះហើយគេមិនឲ្យអ្នកទាំងពីរហ្នឹងរស់តទៅទៀតទេ គេទៅតាមសម្លាប់ -- ដែលខ្ញុំរាយការណ៍ជូន -- ១៥ថ្ងៃមក។

**សៈ** តើលោកដឹងថា ផាត ហើយនិង ដោ ហ្នឹង តើលោកស្គាល់ពួកគាត់ពីមុនទេ គឺថាមុនពេលដែលគាត់មកប្រាប់ពីរឿងការសម្លាប់នៅទួលពោធិ៍ជ្រៃហ្នឹង? តើលោកស្គាល់ ផាត ហើយនិង ដោ ហ្នឹងពីមុនមកទេ?

**ផៈ** ស្គាល់គ្នាតាំងពីតូចៗមក។

**សៈ** លោកនិយាយថា ប្រហែលជាពីរអាទិត្យក្រោយមកពួកខ្មែរក្រហមបានតាមចាប់យកទៅសម្លាប់ចោល នៅក្នុងចម្លើយរបស់លោកប្រាប់។ ប៉ុន្តែ ខ្ញុំចង់សួរថាហេតុអីបានលោកដឹងថាពួកខ្មែរក្រហមមកចាប់យកទៅសម្លាប់ចោល?

[១១:០៦:៣៦]

**ផៈ** ព្រឹត្តិការណ៍គឺបានដឹងអំពីប្រជាពលរដ្ឋនៅក្នុងភូមិហ្នឹងឯង បានប្រាប់បន្តទៀត។ ថាគេទាំងពីរនាក់នោះគេបានចាប់យកទៅហើយ សម្លាប់ហើយ ចាប់ពីពេលនោះមក ខ្ញុំពុំដែលបានជួបជនពីរនាក់នេះទៀតទេ មកទល់សព្វថ្ងៃ។

**សៈ** នៅក្នុងចម្លើយរបស់លោកប្រាប់ដល់អ្នកស៊ើបអង្កេតនៃ អ.វ.ត.ក គឺលោកបានបញ្ជាក់ថា

គឺលោកនិយាយអំពីចំនួនមនុស្សដែលត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃ គឺភាសាអង់គ្លេសមានលេខ 00242128, ខ្មែរមានលេខ 00196814 និងភាសាបារាំងមានលេខ 00244134។ សំណួរបានសួរដូចតទៅ "តើលោកដឹងទេថាមានជនរងគ្រោះចំនួនប៉ុន្មាននាក់ដែលត្រូវបានទាហានខ្មែរក្រហមយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ? លោកបានឆ្លើយថា៖ ខ្ញុំបានធ្វើរបាយការណ៍នៅក្នុងសន្និបាតអប់រំនៅភ្នំពេញដែលខ្ញុំបានចូលរួមនោះថាមានជនរងគ្រោះប្រហែល ២០០០នាក់បានយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ។ ខ្ញុំប៉ាន់ប្រមាណតួលេខនេះតាមរយៈឈ្មោះ សេង ឈន អតីតមេឃុំស្វាយលួង ស្រុកកណ្ដៀង ដែលក្នុងសម័យខ្មែរក្រហមគាត់រស់នៅទីនោះ។ រួមផ្សំទៅនឹងព័ត៌មានដែលខ្ញុំបានដឹងផ្ទាល់នៅសម័យខ្មែរក្រហម ពេលដែលគេហៅថៅហ្វាយខេត្ត ទាហានសម័យ លន់ នល់ សិស្ស មន្ត្រីរដ្ឋការ ទៅទទួលអង្គការនៅទួលពោធិ៍ជ្រៃនោះ"។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា តើតួលេខ ២០០០នាក់ហ្នឹងគឺ ថាលោកទទួលបានពីលោក សេង ឈន នៅក្នុងឆ្នាំ៨០ ឬមួយមុនឆ្នាំហ្នឹង? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១១:០៩:០៣]

**ឆ៖** ត្រឹមត្រូវ។

**ស៖** ដូច្នេះខ្ញុំចង់សួរបន្ថែមបន្តិចទៀតអំពីតួលេខហ្នឹង គឺឯកសារ D125/49។ ដូច្នេះខ្ញុំគិតថាឯកសារនេះនឹងជួយដល់អង្គជំនុំជម្រះដើម្បីពិចារណាសម្រេចទៅលើបញ្ហានេះ។ លោកសាក្សី! ដើម្បីបញ្ចប់ពាក់ព័ន្ធទៅនឹងបញ្ហាទួលពោធិ៍ជ្រៃហ្នឹង លោកនិយាយថាមានឡានប្រហែលជា ១៣ ទៅ ១៥ គឺឡានពណ៌សហ្នឹងបានចាកចេញនៅក្នុងក្បួនទី១ ចេញពីសាលាខេត្ត ហើយលោកជឿថាមនុស្សប្រហែលជា ៥០ ទៅ ៦០ នាក់នៅក្នុងឡានមួយៗ តើវាជាការត្រឹមត្រូវដែរទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ហើយលោកក៏បានផ្ដល់ភស្តុតាងផងដែរថា លោកជឿថាអត់មានក្បួនទី២ មកដឹកមនុស្សចេញពីសាលាខេត្តទេ គឺមានតែក្បួនទី១ទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១១:១១:៤៩]

**ស៖** ហើយលោកបានផ្ដល់ចម្លើយថា មានមនុស្សប្រហែលជា៥០ទៅ៦០នាក់ ដែលនៅជាមួយលោកដែលអត់បានឡើងជិះក្បួនឡាន គឺថាប្រហែលជា៥០ទៅ៦០នាក់ ក្នុងចំណោមមនុស្ស ៥០០នាក់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំលើកទី២នោះ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកក៏បានបញ្ជាក់ផងដែរថា មានមនុស្សមួយចំនួនដែលលោកស្គាល់នៅក្នុងការប្រជុំនៅថ្ងៃនោះ ហើយលោកបានបញ្ជាក់ថាលោកស្គាល់ពួកគាត់ភាគច្រើន ហើយលោកនិយាយថាក្នុងចំណោម២០០នាក់ហ្នឹង។ ខ្ញុំចង់ដឹងថាក្នុងចំណោម២០០នាក់ហ្នឹងមានមនុស្សដែលលោកស្គាល់ច្បាស់ប៉ុនណាៗ? ហើយលោកនិយាយថា លោកស្គាល់មន្ត្រីរដ្ឋការ ទាហាន រួមទាំងឧត្តមសេនីយ៍ ទាំងមន្ត្រីថ្នាក់បន្តបន្ទាប់ទៀត ហើយខ្ញុំដឹង -- ហើយខ្ញុំស្គាល់ពួកគាត់ច្បាស់ប្រហែលជា១០ទៅ២០នាក់។ ចំនួនមនុស្សដែលលោកស្គាល់ច្បាស់ហ្នឹង គឺមនុស្សដែលលោកស្គាល់១០-២០នាក់ ច្បាស់ហ្នឹង តើពួកគាត់ហ្នឹងជាអ្នកនៅក្នុងខេត្តពោធិ៍សាត់ ឬមួយក៏មកពីខាងក្រៅ?

[១១:១២:១០]

**ឆ៖** អ្នកនៅក្នុងពោធិ៍សាត់ អ្នកធ្វើការនៅពោធិ៍សាត់។

**ស៖** ចាប់តាំងពីពេលនោះមករហូតមកដល់ឥឡូវហ្នឹង តើលោកធ្លាប់ឮអំពីវាសនារបស់ពួកគាត់ ធ្លាប់ឮថាពួកគាត់ទាំងអស់ហ្នឹងមាននៅរស់ដែរឬទេ? តើលោកធ្លាប់ឮថាពួកគាត់ហ្នឹងនៅរស់ដែរឬទេ?

**ឆ៖** មកទល់បច្ចុប្បន្នហ្នឹង គឺគ្មានទាល់តែសោះ បាត់សូន្យឈឹង។

**ស៖** សូមអរគុណលោកសាក្សី។

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតលើកយកឯកសារD125/217 គឺជារូបថតមកពីឯកសារ D125/217 ហើយខ្ញុំចង់សាកសួរសាក្សីអំពីរូបថតហ្នឹង ហើយខ្ញុំនឹងសួរសាក្សីថាតើគាត់ស្គាល់រូបថតហ្នឹងដែរឬទេ? ហើយរូបថតហ្នឹងត្រូវបានដកស្រង់ចេញពីឯកសារ D125/217 គឺមានលេខ ERN នៅត្រង់ទំព័រដែលខ្ញុំចង់ដកស្រង់ហ្នឹង គឺថាមានលេខ គឺលេខ 002943216, ភាសាខ្មែរគឺ 00377214, បារាំងមានលេខ 00377323។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញដល់សាក្សី ដើម្បីឲ្យគាត់បានពិនិត្យមើលឃើញ។ សូមលោកប្រធានអនុញ្ញាត។

លោកសាក្សី តើលោកឃើញរូបថតនៅលើអេក្រង់កុំព្យូទ័រនៅចំពោះមុខលោកទេ?

**ឆ៖** បាទ បានឃើញហើយ។

**ស៖** តើលោកស្គាល់អគារនៅក្នុងរូបថតនេះទេ?

**ឆ៖** នេះ គឺជាពីដើមគេហៅថា ហ្គ្រង់អូតែលរបស់សាលាខេត្ត គឺពីដើម គឺមានផ្ទះសម្រាប់អ្នកអភិបាលខេត្តហ្នឹងគេធ្វើការ គឺមាននៅ សម្រាប់ទទួលនៅកន្លែងហ្នឹង ហ្គ្រង់អូតែល ហៅ ហ្គ្រង់អូតែល។

**ស៖** តើរូបថតអគារហ្នឹង គឺជាអគារនៅក្នុងសាលាខេត្តដែលគេធ្វើការប្រជុំនៅពេលនុ៎ង តើមែនដែរឬទេ?

**ឆ៖** មិនមែនកន្លែងហ្នឹងទេ។ អគារនេះគឺសម្រាប់ទទួលអភិបាល គឺជាផ្ទះរបស់សាលាខេត្ត គឺផ្ទះរបស់លោក -- ស្នាក់នៅរបស់ ព្រំ លីហួន។ មិនប្រជុំហ្នឹងទេ គឺមកប្រជុំសាលាខេត្តមួយទៀត កន្លែងរដ្ឋបាល។

[១១:១៥:៣៥]

**ស៖** តើកន្លែងប្រជុំហ្នឹងនៅម្តុំណាដែរ? ខ្ញុំដឹងថានៅក្បែរ ប៉ុន្តែនៅម្តុំណាដែរធៀបនឹងសណ្ឋាគារនេះ?

**ឆ៖** បើយើងចូលពីផ្លូវធំ ចូលពីផ្លូវធំទៅ ងាកខាងប្រជុំ គឺខាងឆ្វេងៗដៃនៃហ្គ្រង់អូតែល។

**ស៖** តើមានចម្ងាយប្រហែលជាប៉ុន្មានម៉ែត្រដែរពីសណ្ឋាគារហ្គ្រង់អូតែលហ្នឹង?

**ឆ៖** ប្រហែលជា១៥ ទៅ២០ គឺ៣០ម៉ែត្រ។

**ស៖** ដូច្នេះ ខ្ញុំលែងត្រូវការប្រើប្រាស់រូបថតនេះហើយ។ សូមអនុញ្ញាតដកចេញ។ សូមអភ័យទោសដែលខ្ញុំត្រូវកាត់។ គាត់បានបង្ហាញឯកសារមានលេខ 0029431516--

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកត់លេខហ្នឹងអត់ទាន់ច្បាស់ទេ ដូច្នេះសូមឲ្យព្រះរាជអាជ្ញាគាត់បញ្ជាក់លេខ ERN មួយសាទៀត។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

គឺ00294316។

**ស៖** លោកសាក្សី ការប្រជុំដែលលោកបានចូលរួមនៅថ្ងៃនោះ ដូចដែលលោកបានបញ្ជាក់រួចទៅហើយ គឺថាអគារដែលគេប្រជុំហ្នឹង គឺវានៅមានរហូតមកដល់ឥឡូវហ្នឹង។ តើមែនដែរឬទេ?

[១១:១៧:២០]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** អគារប្រជុំរបស់សាលាខេត្តដែលនៅមានរហូតមកដល់ឥឡូវហ្នឹង តើគេជួសជុលកែសម្រួល ឬមួយក៏អីអ៊ីចឹងដូចម្តេចដែរចាប់តាំងពីឆ្នាំ៧៥មក តើមានការកែកុន ឬក៏មានការសង់ថ្មីអ្វីបន្ថែមទេ?

**ឆ៖** រូបភាពនៅដដែល ប៉ុន្តែគ្រាន់តែដំបូលប៉ះប៉ូវបន្តិចបន្តួច ដូចហ្គ្រង់អូតែលដែរ។

**ស៖** តើអគារប្រជុំហ្នឹងគឺវាមើលទៅប្រហាក់ប្រហែលជាមួយនឹងសណ្ឋាគារហ្វ្រេគ់អូតែលហ្នឹងដែរឬទេ?

**ឆ៖** ហ្វ្រេគ់អូតែលពីរជាន់ តែសាលប្រជុំ កន្លែងប្រជុំ កន្លែងធ្វើការរដ្ឋបាលតែមួយជាន់ទេ។

**ស៖** ដើម្បីឱ្យច្បាស់ថាតើអគារដែលលោកនិយាយនៅសាលាខេត្តហ្នឹង តើអគារសាលាខេត្តហ្នឹងនៅក្នុងឆ្នាំ៧៥ហ្នឹងមានរបងព័ទ្ធជុំវិញដែរឬទេ?

**ឆ៖** មានរបងព័ទ្ធជុំវិញ។

**ស៖** ឡានដែលលោកនិយាយហ្នឹង គឺឡានដែលដឹកមនុស្សទៅទួលពោធិ៍ជ្រៃហ្នឹង តើឡានហ្នឹងវានៅក្នុងរបង ឬមួយក៏វានៅខាងក្រៅរបងអគារនៅតាមផ្លូវទេ?

**ឆ៖** ឡានគេចតនៅខាងផ្លូវហូរហែទៅតាមខាងក្រៅរបង ជាប់ផ្ទាល់ហ្នឹងឯង។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរបន្ថែមតទៅទៀតទេ សូមអរគុណ។

[១១:១៩:៤០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោកស្រីចៅក្រមនៃអង្គសវនាការ។ មេធាវីដែលទទួលសិទ្ធិគឺលោកស្រីមេធាវី ជេត វណ្ណលី ហើយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងអាចមានសំណួរបន្ថែមមួយចំនួន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពដល់អង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

**ស៖** សួស្តីលោកសាក្សី។ ពីម្សិលមិញហើយនិងមួយព្រឹកនេះគឺថាលោកបានឆ្លើយបំភ្លឺនឹងចំណុចមួយចំនួននៅចំពោះមុខតុលាការ។ ដើម្បីស្វែងរកយុត្តិធម៌ក្នុងរឿងក្តីនេះខ្ញុំសូមបញ្ជាក់ -- ចង់ឲ្យលោកបញ្ជាក់នូវចំណុចមួយចំនួនបន្ថែមទៀតដែលទាក់ទាមនឹងការហេតុការណ៍ដែលកើតឡើងនៅក្នុងខេត្តពោធិ៍សាត់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើខេត្តពោធិ៍សាត់ត្រូវរំដោះនៅថ្ងៃទីប៉ុន្មានលោក?

**ឆ៖** ព្រឹត្តិការណ៍ពាក្យរំដោះហ្នឹងវាមានពីរ។ ព្រឹត្តិការណ៍តើរំដោះយ៉ាងម៉េចដែរសូមបញ្ជាក់ម្តងទៀត? ព្រឹត្តិការណ៍មុន៧៥ ឬមួយយ៉ាងម៉េច?

[១១:២១:៣៨]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើខេត្តពោធិ៍សាត់ត្រូវគ្រប់គ្រងដោយពួកខ្មែរក្រហមនៅថ្ងៃទីប៉ុន្មានចាស?

**ឆ៖** ខេត្តពោធិ៍សាត់គឺការគ្រប់គ្រងរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ មេសា ១៩៧៥។

**ស៖** អ៊ីចឹងទីក្រុងពោធិ៍សាត់រំដោះបានដូចនៅទីក្រុងភ្នំពេញដែរលោក?

**ឆ៖** ពេលវេលាតែមួយ។

**ស៖** សូមអរគុណលោក។ ខ្ញុំនៅមានចំណុចមួយដែលនៅតែមិនច្បាស់ លោកបានបញ្ជាក់នៅមុខសហព្រះរាជអាជ្ញាថានៅពេលដែលកងទ័ពនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់កាប់ខេត្តពោធិ៍សាត់ គេបានប្រមូលទាហានលន់នល់ អ្នករដ្ឋការ មន្ត្រីរាជការ និងសិស្សទៅប្រជុំនៅសាលាខេត្ត។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមពីចំណុចនេះថាតើការប្រជុំនៅសាលាខេត្តហ្នឹងមានប៉ុន្មានដងលោក?

[១១:២២:៥៦]

**ឆ៖** ការប្រជុំប៉ុន្មានដងៗខ្ញុំពុំបានចាំច្បាស់ទេ ប៉ុន្តែព្រឹត្តិការណ៍ដែលខ្ញុំត្រឡប់មកពីសមរភូមិនៅស្វាយដូនកែវ ជាថ្ងៃដែលខ្ញុំមកចូលរួម គឺខ្ញុំដឹងថាមានការប្រជុំច្រើនលើកមកហើយអំពីព្រឹត្តិការណ៍ដែលគេចាប់ដៃគ្នា គេទំនាក់ទំនងគ្នាយ៉ាងម៉េចៗគឺគេវាស៊ាំទៅហើយ បានជាធ្វើឲ្យខាងយើងក៏ទុកចិត្ត គេក៏ទុកចិត្តរហូតដល់ទទួលបានជោគជ័យប្រមូលបានរាប់រយនាក់នោះ។ បាទ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** អរគុណលោក។ តើលោកអាចចាំបានទេនៅថ្ងៃណាដែលគេថ្ងៃប្រជុំចុងក្រោយ ដែលត្រូវដឹកទាហាន មន្ត្រីរាជការហ្នឹងទៅកាន់ទួលពោធិជ្រៃ? លោកមានចាំទេ ប្រហែលជាថ្ងៃប៉ុន្មាន? រំដោះ ភ្លាម ឬក៏ក្រោយរំដោះប៉ុន្មានថ្ងៃ?

**ឆ៖** មិនមែនជាភ្លាមៗប្រហែលជាក្រោយមប្រហែលមួយអាទិត្យ ឬពីរអាទិត្យ ឬក៏ក្នុងរបាយ-

ការណ៍ ឬក៏ក្នុងកំណត់ហេតុនេះខ្ញុំដូចជាបានបញ្ជាក់ហើយប្រហាក់ប្រហែលជាខ្ទង់ប៉ុន្មាន សូមមើលម្តងទៀត។ ថ្ងៃដែលគេយកទៅទួលពោធិ៍ជ្រៃខ្ញុំដូចជាបានកត់កាលបរិច្ឆេទ ខ្ញុំមិនចាំសូមទោស នៅក្នុងកំណត់ហេតុមានដែរឬទេ? ប៉ុន្តែមិនមានភ្លាមៗទេ ១៧ មេសាភ្លាម មិនមែនភ្លាមៗទេ ក្រោយ១៧ មេសាប្រហែលជាខ្ទង់មួយអាទិត្យឬ ពីរអាទិត្យ។

**ស៖** អរគុណលោក។ តើលោកនៅចាំបានទេ ថាតើលោកជាទាហាននៅក្នុងខេត្តពោធិ៍សាត់ ហើយលោកជាអ្នកស្រុកពោធិ៍សាត់ទៀត។ ដូច្នេះតើលោកនៅចាំបានទេ ថាតើមេទាហានណាខ្លះដែលចូលរួមក្នុងការដែលឡើងឡានទៅទួលពោធិ៍ជ្រៃជាមួយលោក ព្រំ លីហួន អ្នកដែលមានស័ក្តិធំៗ លោកមានចាំឈ្មោះខ្លះៗទេចាស?

[១១:២៥:០០]

**ឆ៖** មាននៅចាំខ្លះ។ មិនខ្លះទេ ច្រើនដែរ។

**ស៖** សូមទោស លោកអាចរៀបរាប់បានខ្លះៗទេ លោក? មេធំៗចាស។

**ឆ៖** បាទ បញ្ហានេះគឺតាមខ្ញុំគឺ មេទាហានជាន់ខ្ពស់។ ជាពិសេស ខ្ញុំចាំឈ្មោះ មានលោក កុងស៊ីញ៉េ ប៉ូលឡេទិច ស័ក្តិ៤កន្លះ ហៅថាកាន់កាប់ខាងផ្នែកនយោបាយ។ លោក នាង ឈុំ ស័ក្តិ៤កន្លះទៅស័ក្តិ៥។ ឆោម ឈុំ គឺអង្គរក្ស ដេប៉ង់វីល គេហៅថាការការពារនៅក្នុងសាលាខេត្ត ស័ក្តិ៣។ សូម្បីតែបងខ្ញុំមួយទៀត ឆុង វ៉ាន់ កុំម៉ង់ដង់ស្វាយដូនកែវ។ ជាពិសេសលោកបណ្តារស័ក្តិធំៗតាមការិយាល័យនៃគណៈសេនាធិការ មានលោក ហួត វ៉ន, មានលោក ឈិន តាក់។ ប្រហែលជា ម៉ី ស៊ីចួន ដែរជាប្អូនរបស់លោក ម៉ី ស៊ីចន ដែលប្រកាសនៅតាមវិទ្យុជាតិ។ គាត់កាន់អេតា-ម៉ាហ្សំរ នៅខេត្តពោធិ៍សាត់ដែរ គឺបានប្រមូលគ្នាទៅភាគច្រើនណាស់ សូម្បីតែប្រធានការិយាល័យស័ក្តិ៣ ម៉ែន ផេន សព្វថ្ងៃមានបងប្អូនគេជាច្រើន ដែលរង់ចាំមកបច្ចុប្បន្ននេះ មានដឹងតាមរយៈយើងបើកសវនាការថ្ងៃនេះ បានទទួលស្គាល់ខ្ញុំបានដឹងច្បាស់ពីបញ្ហាហ្នឹង គឺមានច្រើន។ ជាពិសេសគឺនាយទាហានកុំម៉ង់ដង់ដែលខ្ញុំចាំឈ្មោះរៀបរាប់បានខ្លះៗនេះ បាទគឺមានច្រើន។

[១១:២៧:០០]

**ស៖** អរគុណលោក។ ចុះលោកមានស្គាល់លោក ប៊ុល ហើយនិងលោក រុន ទេលោក?

**ឆ៖** លោក ប៊ុល ខ្ញុំឮឈ្មោះ។ លោក ប៊ុល ប្រហែលជាស័ក្តិអាសឺដង់ ឬក៏ស័ក្តិ១។

**ស៖** នៅពេលប្រតិបត្តិការនៅទួលពោធិ៍ជ្រៃ លោកមានដឹងថាតើវាសនានៃលោក ប៊ុល ហើយ

និងលោក រុន ទេ នៅទៅវាសនាគាត់ទៅជាយ៉ាងណាទេ ចាស?

**ឆ៖** ពុំដែលបានជួប អត់ដែលបានជួប មិនដឹងបានឮវាសនាគាត់យ៉ាងម៉េចទេ។ អត់បានទាក់ទងសោះ អត់បានជួបសោះ។

**ស៖** អរគុណលោក។ នៅក្នុងកំណត់ស្តួរចម្លើយនៅមុខសហចៅក្រមស៊ើបអង្កេត ដែលមានលេខ D125/48។ ERN ជាភាសាខ្មែរលេខ 00196810 និងERN ជាភាសាអង់គ្លេសលេខ 00224 2125 និងERN ជាភាសាបារាំងលេខ 00274130។ លោកបានបញ្ជាក់ថា "មានព្រឹត្តិការណ៍បោសសម្អាត"។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើព្រឹត្តិការណ៍បោសសម្អាតហ្នឹងយ៉ាងម៉េចដែរចាស?

**ឆ៖** ព្រឹត្តិការណ៍បោសសម្អាតនេះ ចង់បញ្ជាក់ថា នៅតាមសហករណ៍ គឺតាមភូមិឃុំដែលយើងរៀបចំជាសហករណ៍ហើយ មានតាមរោងបាយជាផ្នែកៗហ្នឹង។ ហ្នឹងគឺគេចម្រាញ់ៗ។ និន្នាការ គេហៅថាជាប់និន្នាការ។ បើយើងនិយាយរួមសម័យនុ៎ងហ្នឹងគេហៅថា បែងចែកប្រជាពលរដ្ឋមូលដ្ឋាន និងមនុស្សថ្មី គេថា ១៨ និង១៧នោះ។

[១១:២៩:៣៣]

អ៊ីចឹងនិន្នាការ ជាប់និន្នាការហ្នឹង គឺជាប់ខាងសម័យលន់នល់នេះ គេហៅថា និន្នាការ។ អ៊ីចឹងព្រឹត្តិការណ៍នេះ មានការបោសសម្អាតអ្វីដែលសល់ពីទួលពោធិ៍ជ្រៃមក។ យ៉ាងរូបខ្ញុំក៏ដោយ ក៏គេហៅថានិន្នាការដែរ។ អ៊ីចឹងគេបោសសម្អាតពួកហ្នឹង។

**ស៖** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថាតើពាក្យ "កម្ទេច" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឃើញគេប្រើពាក្យ "កម្ទេច" ហើយនិងពាក្យ "បោសសម្អាត" ហ្នឹងវាខុសគ្នាម៉េចដែរលោក?

**ឆ៖** ពាក្យ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:៣០:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមជំទាស់សំណួរបែបនេះ។ សាក្សីត្រូវបានកោះអញ្ជើញឲ្យផ្តល់សេចក្តីពន្យល់អំពីប្រវត្តិឧក្រិដ្ឋ ឬហើយនិងសមាជិករបស់បក្សកុម្មុនីស្តកម្ពុជា។ ប៉ុន្តែគាត់នេះជាអតីតទាហានលន់នល់

ទេ។ ដូច្នេះការសួរអំពីអត្ថន័យនៃពាក្យ "កម្ទេច, បោសសម្អាត" នេះគឺថា ពីសាក្សីរូបនេះ គឺគ្រាន់តែជាសំណួរសុំឲ្យសាក្សីនេះនិយាយដោយស្មានតែប៉ុណ្ណោះទេ បើគាត់ឆ្លើយ។ ដូច្នេះខ្ញុំសូមជំទាស់។

**លោកស្រី ជេត វណ្ណលី៖**

ខ្ញុំសូមឆ្លើយលោកប្រធាន។ ខ្ញុំយល់ឃើញថា សាក្សីនេះជាទាហាននៅក្នុងរបប លន់ នល់ ប៉ុន្តែសាក្សីនេះគឺថាក្រោយឆ្នាំ១៩៧៥ គឺថាបានរស់នៅជាមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំយល់ថាគាត់ធ្លាប់បានដឹងឮ បានដឹងឮ ហើយគាត់បានដឹងច្រើននៅក្នុងបញ្ហាហ្នឹង ពីរឿងបញ្ហាការបោសសម្អាត និងបញ្ហាកម្ទេច ដែលជាគោលនយោបាយមួយក្នុងគោលនយោបាយទាំងប្រាំរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែពាក្យទាំងនេះលោកស្រីមិនទាន់បានព័ត៌មានពីប្រភពសាក្សីនេះនៅឡើយទេ រវាងការដឹងឮនូវពាក្យទាំងពីរនេះ។ ស្រាប់តែលោកស្រីយករឿងផ្សេងទៀត ដែលលោកស្រីបានដឹងយកមកសួរតែម្តង។ លោកស្រីអត់មានបង្កើតសំណួរដើម្បីសួរបញ្ជាក់លើទៅសាក្សីអំពីការដឹងនូវពាក្យពេចន៍នេះពីមុនមកទេ។ នេះជាបច្ចេកទេសក្នុងការតាំងសំណួរដែលមិនសមស្រប។

[១១:៣២:២២]

**លោកស្រី ជេត វណ្ណលី៖**

ខ្ញុំអាចសូមបន្តទៅទៀតបានទេលោកប្រធាន?

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកសាក្សីនៅក្នុងឯកសារ ដែលលោកឆ្លើយនៅចំពោះព្រះរាជអាជ្ញា អ៎! នៅមុខសហចៅក្រមស៊ើបអង្កេត ខ្ញុំចង់ឲ្យបញ្ជាក់ដែរថា តើលោកបានឃើញ បានដឹងនិងបានឮអ្វីខ្លះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** សូមសំណួរម្តងទៀត។

**ស៖** លោកសាក្សី តើលោកបានឃើញ បានដឹង បានឮអ្វីខ្លះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? ខ្ញុំសូមបន្ថែមទៀត តើលោកបានស្គាល់មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សណាខ្លះនៅក្នុងភូមិភាគពាយ័ព្យ?

[១១:៣៣:៤៥]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីគប្បីកំហិតនូវសំណួររបស់លោកស្រីឲ្យបានសមស្របទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ ដើម្បីជាប្រយោជន៍អង្គជំនុំជម្រះយកទៅពិនិត្យពិចារណា រៀបចំនូវសាលក្រមផ្នែកពាក់ព័ន្ធនេះ។ នៅក្នុងនោះគឺវិសាលភាពដែលមានចែងនូវអង្គហេតុដែលពាក់ព័ន្ធ បទល្មើសដែលពាក់ព័ន្ធ អង្គច្បាប់ដែលពាក់ព័ន្ធ ក៏ដូចជាកាលវេលានៃ -- ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១ គឺជម្លៀសទី១ និងទី២។ កាលបើលោកស្រីបើកទូលាយ រហូតដល់ពេញរបបកម្ពុជាប្រជាធិបតេយ្យនោះមិនសមស្របទេ។ បានន័យថាអង្គហេតុផ្សេងទៀតមិនពាក់ព័ន្ធទៅនឹងបញ្ហាដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការទេ។ សូមរៀបចំនូវសំណួរឲ្យបានសមស្រប ចៀសវាងការប្រើប្រាស់ពេលវេលាមិនមានប្រសិទ្ធភាព មិនមានប្រយោជន៍សម្រាប់ដល់អង្គជំនុំជម្រះ យកទៅពិចារណាក្នុងការសម្រេចសេចក្តីនៅក្នុងរឿងក្តីនេះ។

*(សម្រាករយៈពេលខ្លី)*

[១១:៣៥:៣៦]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកសាក្សី តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់បានចូលរួមប្រជុំការងាររៀនសូត្រប៉ុន្មានដង? នៅឯណាខ្លះ? ហើយអ្នកណាជាអ្នកដឹកនាំអង្គប្រជុំលោក?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ក្រោយព្រឹត្តិការណ៍ប្រមូលទៅទួលពោធិ៍ជ្រៃបន្ទាប់ៗគ្នានោះ គេបានបើកវគ្គរៀនសូត្រមួយដ៏ធំ គេហៅថា “មន្ទីរតំបន់” គឺនៅក្នុងស្រុកកណ្តៀង ដោយប្រមូលមានសិស្ស គ្រូបង្រៀន ដែលនៅសេសសល់ហ្នឹង រៀនចំនួន៣ថ្ងៃទេ។ ហើយការដឹកនាំប្រជុំ រៀនសូត្រនោះគឺគណៈតំបន់ឈ្មោះ សុត។

**ស៖** តើនៅតាមមូលដ្ឋានដែលលោករស់នៅក្នុងរបបខ្មែរក្រហមនេះ តើដែលមានប្រជុំការងារប្រចាំថ្ងៃទេលោក?

**ឆ៖** នេះគឺជាក្រិតក្រមរបស់គេដែលគេត្រូវប្រជុំប្រចាំថ្ងៃ ខាងកងចល័តខ្ញុំគឺរាល់ថ្ងៃ។ ក្រោយពីបានខ្ញុំរស់រានមានជីវិតហើយ ខ្ញុំធ្វើជាកងចល័ត គឺប្រជុំរៀងរាល់ថ្ងៃនៅពេលល្ងាច នៅពេលយប់ក្រោយពីធ្វើការ។

[១១:៣៧:៣០]

**ស៖** តើខ្លឹមសារនៃការប្រជុំនោះបែបម៉េចដែរលោក?

**ឆ៖** ខ្លឹមសារសំខាន់គឺ ការទិតៀន និងស្វ័យទិតៀន នៃការងាររបស់ក្រុមនីមួយៗ យើងធ្វើបានសម្រេចអ្វីខ្លះ អីខ្លះ នរណាខ្ជិលច្រអូសយ៉ាងម៉េចអីយ៉ាងម៉េច គឺកសាងទិតៀនគ្នា។ គេប្រើពាក្យទិតៀន និងស្វ័យទិតៀន។

**ស៖** ក្រៅពីការងារប្រជុំប្រចាំថ្ងៃដែលមានការទិតៀន និងស្វ័យទិតៀន តើលោកមានដែលចូលរួមប្រជុំនៅកន្លែងណាផ្សេងទៀតទេលោក? ដែលលើកឡើងពីគោលការណ៍ទស្សនៈបដិវត្តន៍ ឬមិនបដិវត្តន៍អីហ្នឹងចាស។ ដូចចម្លើយរបស់លោកដែលឆ្លើយនៅមុខសហចៅក្រមស៊ើបអង្កេត?

[១១:៣៨:៣២]

**ឆ៖** ឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យក្នុងសម័យនោះគឺយើងខ្ញុំបានរៀនតែម្តគត់ គឺរៀនរយៈពេល៣ថ្ងៃហ្នឹងឯងអំពីទស្សនៈបដិវត្តន៍ និងទស្សនៈមិនបដិវត្តន៍។ ដែលខទ្ទេសនាមដោយលោក សុតជាគណៈតំបន់ហ្នឹងឯង។

**ស៖** តើខ្លឹមសារពាក្យនេះយ៉ាងម៉េចដែរលោក លោកអាចពន្យល់បានដែរទេចាស បកស្រាយបានទេចាស?

**ឆ៖** ក្នុងនេះ គឺតាមគំនិតខ្ញុំដែលខ្ញុំយល់ចាប់បានឯកសារនៅពេលដែលខទ្ទេសនាមនេះ គឺចង់បង្ហាញពីបដិវត្តន៍ហ្នឹង គឺចង់និយាយថាអ្វីដែលឈរខាងខ្មែរក្រហម។ មិនបដិវត្តន៍ គឺឈរខាងសម័យលន់ នល់។ ពីរនេះ ទស្សនៈទាំងពីរនេះ មិនអាចចូលគ្នាបានទេ គឺទស្សនៈមួយខាងលោកសេរី ទស្សនៈរបស់ខាងកុម្មុយនីស្ត។ ពីរនេះបដិបក្ខ មិនអាចចូលគ្នាបានទេ។ បើ -- ឧទាហរណ៍៖ ពណ៌ស ដែលជាតំណាងសន្តិភាព បើទស្សនៈរបស់បដិវត្តន៍ថាមិនល្អទេ ជាអ្នកចុះចាញ់ វាទៅជាអ៊ីចឹងទៅវិញ។ អ៊ីចឹងទេទស្សនៈទាំងពីរនេះសូមឲ្យយើងដែលទៅរៀនសូត្រនេះ គេពន្យល់យើងឲ្យយើងកាន់ឈរលើទស្សនៈបដិវត្តន៍។ អ៊ីចឹងអ្វីដែលនិន្នាការយើងរៀនសូត្រក្នុងសម័យពីតូចរហូតមកដល់យើងមកសម័យ -- មកដល់ថ្ងៃ១៧ មេសា នេះ គឺជាទស្សនៈខុសឆ្គងរបស់យើងដែលរៀនសូត្រទទួលឥទ្ធិពលពីទស្សនៈមិនបដិវត្តន៍។ អ៊ីចឹងចាប់ពីពេល ម៉ោងពេលដែលគេបានខទ្ទេសនាម៣ថ្ងៃនេះ ចប់ទៅវិញគឺយើងឈរលើទស្សនៈបដិវត្តន៍ គឺលត់ដំខ្លួនទៅតាមចលនារស់នៅក្នុងរបបមួយថ្មី គឺរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងឯង។ ខ្ញុំសូមសង្ខេបតែប៉ុណ្ណេះ។

[១១:៤០:៤៣]

**ស៖** អរគុណលោកចំពោះការបកស្រាយ ហើយខ្ញុំនៅជាសំណួរដែលជាសំណួរចុងក្រោយពីររបស់ខ្ញុំទៀត។ គឺខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រៅពី តាសុត តើលោកដែលឮឈ្មោះអ្នកដឹកនាំខ្មែរក្រហមណាទៀតទេនៅក្នុងភូមិភាគពាយ័ព្យ? ជាពិសេសក្នុងខេត្តពោធិ៍សាត់។

**ឆ៖** ខ្ញុំធ្លាប់ -- ក្រៅពីលោក តាសុត ក្រៅពីតាសុត គណៈតំបន់ហ្នឹង គឺបន្ទាប់ពីគាត់បាត់បង់ទៅ គាត់ចេញទៅពីខេត្តពោធិ៍សាត់មាន តាទ្រី, តាសុត មកទៀត-- អ៎! តាទ្រី, តាតួយ មកបន្តបន្ទាប់ទៀត ពីរទៀតដែរ ប៉ុន្តែខ្ញុំមិនបានឃើញទេ ឮតែឈ្មោះទេ។ ប៉ុន្តែ តាសុត ខ្ញុំបានស្គាល់ច្បាស់ ឃើញគាត់ច្បាស់នៅពេលដែលគាត់បង្រៀន៣ថ្ងៃហ្នឹងឯង។ ប៉ុន្តែក្នុងឆ្នាំ១៩៧៧ ខ្ញុំឃើញឈ្មោះគាត់នៅគុកទួលស្លែងហ្នឹងឈ្មោះតាសុត។ ដោយឡែក តាតួយ, តាទ្រី ខ្ញុំអត់ដឹងទេ ហើយខ្ញុំមិនបានស្គាល់អ្នកដឹកនាំធំៗណាដែរ អត់ដែលបានស្គាល់ទេ។

[១១:៤២:០០]

**ស៖** សូមអរគុណលោក។ ចុះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដដែលនេះ តើលោកដែលឮឈ្មោះអ្នកដឹកនាំធំៗនៅក្នុងរបបហ្នឹងទេលោកដូចជា អៀង សារី, ខៀវ សំផន, ប៉ុល ពត, នួន ជា អីលោកដែលបានឮឈ្មោះអស់ហ្នឹងទេថា?

**ឆ៖** ឮតែឈ្មោះ ប៉ុន្តែពុំបានស្គាល់គាត់ពិតប្រាកដទេ។

**ស៖** ក្នុងរបបនុ៎ងលោកឮទេ លោកឮឈ្មោះហ្នឹងទេក្នុងរបបនុ៎ង? អ្នកដឹកនាំកម្ពុជាប្រជាធិប-តេយ្យ?

**ឆ៖** បាទ ធ្លាប់ឮឈ្មោះ ប៉ុន្តែខ្ញុំពុំបានស្គាល់។

**ស៖** ហើយមួយទៀតដែលជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកជាអ្នកស្រុកខេត្តពោធិ៍សាត់ ហើយលោកបានឆ្លើយនៅមុខសហចៅក្រមស៊ើបអង្កេតថា លោកបានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើការរៀបការនុ៎ងមានលក្ខណៈបែបណាលោក? ជាការរៀបការដោយស្ម័គ្រចិត្តឬក៏ជាការតម្រូវដោយអង្គការ?

[១១:៤៣:២៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមជំទាស់ប្រយោគនេះលោកប្រធាន។ គឺថាគាត់បានសួរសំណួរឆ្ងាយពីអង្គហេតុសម្រាប់ការជំនុំជម្រះនៅពេលនេះ។ សូមអរគុណ។

**លោកស្រី ជេត វណ្ណលី៖**

លោកប្រធាន ខ្ញុំអត់មានសំណួរអីទៀតទេ។ អរគុណលោកសាក្សីដែលបានឆ្លើយបំភ្លឺចំពោះមុខតុលាការ។ សូមអរគុណ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព ភាគីទាំងអស់ជាទីគោរព។ ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមចោទសំណួរបន្ថែមទៅលើប្រធានបទមួយចំនួនដែលនៅក្នុងសំណុំរឿងយើងនេះ។

[១១:៤៤:៤៥]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកសាក្សី ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហើយនិងនៅពេលដែលគេនាំទាហាន ឬក៏មន្ត្រីរាជការមួយចំនួនទៅទួលពោធិ៍ជ្រៃ ខ្ញុំចង់ដឹងថា តើលោកបានទៅណាដែរ ក្រោយពេលនុ៎ង?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ក្រោយព្រឹត្តិការណ៍នេះ គឺខ្ញុំបានចូលធ្វើជាកងចល័ត ជីទំនប់ លើកប្រឡាយ។

**ស៖** នៅក្នុងភូមិដែលលោកនៅហ្នឹង ហើយនិងនៅភូមិជុំវិញហ្នឹង តើមានអ្នកភៀសសឹកពីពោធិ៍សាត់ ឬក៏ពីក្រុងផ្សេងទៀតទេ?

**ឆ៖** ពេលថ្មីៗភ្លាមៗ ពុំមានទេ ប្រជាជនពុំមានទេ ថ្មីៗគឺមិនទាន់មានទេ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា ជនភៀសសឹក ឬក៏ជនជម្លៀសហ្នឹងទៅដល់ហ្នឹង ដល់ពេលណាដែរ ដែលគេហៅថាប្រជាជនថ្មីហ្នឹង?

**ឆ៖** ខ្ញុំនៅចាំបានថាហាក់ដូចជាឆ្នាំ១៩៧៦ ដល់៧៧ គឺមានប្រជាជនជម្លៀសមកពីភ្នំពេញ។

[១១:៤៦:៤៤]

**ស៖** តើលោកដឹងថាពួកគាត់ហ្នឹងមកពីភ្នំពេញតាមរបៀបណាដែរ ដោយរបៀបណា?

**ឆ៖** តាមការដែលខ្ញុំដឹងគឺមកតាមផ្លូវរថភ្លើងមានតាមឡាន ដែលអង្គការខាងកម្ពុជាប្រជាធិប-តេយ្យគេរៀបចំ។

**ស៖** តើលោកមានបានឃើញពួកគាត់ទាំងអស់គ្នាមកដល់ទេ?

**ឆ៖** នៅតាមភូមិនីមួយៗនៅខេត្តពោធិ៍សាត់ ភាគច្រើនទទួលច្រើនពីផ្នែកខាងពីភ្នំពេញមក លើកដំបូងជាលើកទី១ សូម្បីតែក្នុងភូមិខ្ញុំរស់នៅក៏មានច្រើន ប្រជាពលរដ្ឋកើន ភ្នំពេញ។

**ស៖** សូមអរគុណ។ លោកសាក្សីតើលោកអាចរៀបរាប់ពិពណ៌នាអំពីមនុស្សទាំងអស់នេះបានទេ គឺថាក្រុមគ្រួសារទាំងអស់ហ្នឹង គាត់មានសុខភាពល្អ គាត់ស្ថិតនៅក្នុងស្ថានភាពណាដែរ សូមលោកពិពណ៌នាពួកគាត់បន្តិចបានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនថា សំណួរនេះមិនស្ថិតនៅក្នុងសំណុំរឿង០០២/០១ទេ ប៉ុន្តែខ្ញុំកត់សម្គាល់ឃើញថាសាក្សីរូបនេះត្រូវបានកោះអញ្ជើញដោយអង្គជំនុំជម្រះ ដើម្បីគោលបំណងពិសេសមួយឱ្យផ្តល់ភស្តុតាងទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។ ខ្ញុំក៏កត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាក៏បានចាប់ផ្តើមពីម្សិលមិញនោះផងដែរនៅម៉ោងបីកន្លះ។ ហើយបានប្រើពេល២០នាទី។ ខ្ញុំមិនមានបញ្ហាទេ បញ្ហានោះ បើសិនជាអង្គជំនុំជម្រះឱ្យពេលយើងខ្ញុំកន្លះម៉ោងបន្ថែមនោះ។ ដូច្នេះ គឺក្នុងករណីដែលយើងត្រូវការពេលមិនគ្រប់គ្រាន់នោះ យើងនឹងអាចសួរលើសម៉ោងដែលបានកំណត់។ ហើយយើងខ្ញុំនឹងមានសំណើបែបនេះបាទ។

[១១:៤៩:៥០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្សរត៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ លោកប្រធានបាននិយាយអម្បាញ់មិញថា សាក្សីទាំងអស់នេះត្រូវឆ្លើយទៅសំណួរ មិនត្រូវតែលើទួលពោធិ៍ជ្រៃទេ តែឆ្លើយតបទៅនឹងការជម្លៀសដោយបង្ខំផងដែរ។ ព្រោះថាគាត់អាចផ្តល់ព័ត៌មានយើងមួយចំនួន យើងមានកំណត់ហេតុស្តាប់ចម្លើយគាត់ហើយ។ អ៊ីចឹងហើយយើងអាចសួរសំណួរទៅគាត់បាន។ សំណួរទាំងអស់នេះគួរឱ្យចាប់អារម្មណ៍។ ខ្ញុំត្រូវការពេលប្រហែលជា ១០នាទី អីនោះទេ យ៉ាងច្រើនបំផុតនោះ។ ខ្ញុំមិនគិតថាសំណួរដែលខ្ញុំសួរនេះវាប្រាសចាក

ពីខុសពីវិសាលភាពនោះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតសូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំសូមសួរលោកសាក្សីឡើងវិញ ប្រហែលជាលោកសាក្សីភ្លេចសំណួរខ្ញុំហើយអម្បាញ់មិញនេះ។ លោកបាននិយាយថា លោកបានឃើញពួកគាត់មកពីភ្នំពេញដោយឡាន ហើយនិងរទេះភ្លើង ហើយពួកគេត្រូវបែងចែកទៅតាមភូមិផ្សេងៗ។ តើលោកអាចពិពណ៌នាអំពីក្រុមគ្រួសារគាត់ ឬក៏អ្នកនៅតែឯង ហើយអាយុនិងស្ថានភាពសុខភាពពួកគាត់ជាដើមនេះ សូមជួយរៀបរាប់បន្តិចបានទេ?

[១១:៥១:០៥]

**ឆ៖** អ្វីដែលខ្ញុំបានដឹង អ្វីដែលខ្ញុំបានឃើញជាក់ស្តែងដែលគាត់មករស់នៅតាមភូមិឃុំដឹងស្រាប់ហើយយើងធ្លាប់នៅទីក្រុងដល់មកជនបទការផ្លាស់ប្តូរឥរិយាបថទាំងការរស់នៅ វាមិនទម្លាប់ទេ។ អ៊ីចឹងការរស់នៅរបស់គាត់មិនជាគាប់ប្រសើរទេ។ អ្វីដែលគាត់ធ្លាប់ស្រួលនៅទីក្រុង អ៊ីចឹងក៏ប៉ះជួបប្រទះនៅលើខាងស្រុកស្រែ ភាពលំបាក ភាពឈឺរបស់ពួកគាត់ជាបន្តបន្ទាប់រហូតដល់មានក្រុមគ្រួសារខ្លះក៏ដាច់ពូជអស់រលីងដែរ។ ជាក់ស្តែងនៅក្នុងសហករណ៍យើងខ្ញុំនេះឯង។

**ស៖** ខ្ញុំសូមអរគុណលោកសាក្សី។ តើមានបញ្ហាអាហារហូបចុកទេ? តើលោកដឹងថាមានបញ្ហានេះដែរឬទេ?

**ឆ៖** បញ្ហាហូបចុកមិនគ្រប់គ្រាន់ សូម្បីតែក្រុមយើងខ្ញុំក៏ពុំគ្រប់គ្រាន់ដែរ។

**ស៖** តើពួកគាត់ទាំងអស់នោះស្លាប់ដោយដាច់ពោះឬក៏យ៉ាងម៉េច?

**ឆ៖** ពួកគេស្លាប់មានមូលហេតុជំងឺ និងអាហារមិនគ្រប់គ្រាន់។

[១១:៥៣:០០]

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកបានឆ្លើយថា ខ្មែរក្រហមបានឲ្យអប់រំឲ្យមនុស្សលះបង់គំនិតចាស់ចោលហើយធ្វើតាមពួកខ្មែរក្រហម។ តើលោកមានដឹងថាអ្នកដែលមិនចង់ផ្លាស់ប្តូរគំនិតចាស់របស់ខ្លួននេះ មានរឿងអីកើតឡើងចំពោះពួកគាត់?

**ឆ៖** លើបញ្ហានេះខ្ញុំមិនដឹងថាគេស្មានយ៉ាងម៉េចទេ អ្នកខ្លះកែប្រែឥរិយាបថក៏មិនបានធ្វើឲ្យមាន

បញ្ហាគ្រោះថ្នាក់ដល់ខ្លួន ខ្លះគេត្រូវចាប់យកទៅដាក់ពន្ធនាគារ ជាបន្តបន្ទាប់លើសីលធម៌ អ្វីដែលផ្សេងៗខុសពីមាគ៌ារបស់ពួកគេ ដែលជាទស្សនៈរបស់ពួកគេ។

**ស៖** តើគេឃុំខ្លួនពួកគាត់ទាំងអស់នោះនៅកន្លែងណា? តើមានកន្លែងជាក់លាក់ណាមួយដើម្បីឃុំខ្លួនពួកគាត់ទេ?

**ឆ៖** កន្លែងទាំងនេះតាមខ្ញុំដឹងមានច្រើន ហៅថាការឃុំឃាំង មានច្រើនកន្លែងដូចខ្ញុំបានសរសេរបញ្ជាក់នៅក្នុងរបាយការណ៍ ឬកំណត់ហេតុស្រាយបំភ្លឺហើយ ដែលខ្ញុំបានដឹងមានច្រើនកន្លែង។

[១១:៥៥:០២]

**ស៖** សូមអរគុណលោក។ ខ្ញុំសូមបញ្ជាក់ លោកចង់និយាយថា គឺដូចដែលមាននៅក្នុងរបាយ-ការណ៍ស្តាប់ចម្លើយលោកដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតមែនទេ? លោកចង់យោងទៅពាក្យពេចន៍របស់លោកនៅក្នុងកំណត់ហេតុ ឬក៏របាយការណ៍ហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ជាការពិតនៅក្នុងកំណត់ហេតុដែលខ្ញុំបានបញ្ជាក់ហើយ នៅមន្ទីរឃុំឃាំង។

**ស៖** លោកសាក្សីនៅសម័យហ្នឹង ខ្ញុំចង់ដឹងថា តើលោកមានការភ័យខ្លាចទេ លោកផ្ទាល់?

**ឆ៖** មិនត្រឹមតែភ័យខ្លាចទេ ខ្ញុំគឺជាមនុស្សស្លាប់បាត់ទៅហើយ។

**ស៖** នៅទីបញ្ចប់សំណួរចុងក្រោយរបស់ខ្ញុំ លោកបាននិយាយថា លោកបានឃើញដោយផ្ទាល់ភ្នែក ហើយម្សិលមិញលោកបាននិយាយផងដែរ ថាលោកទទួលបានចម្លើយមួយចំនួននៅក្នុងឆ្នាំ១៩៧៩ ហើយលោកបាននាំយកចម្លើយទាំងអស់នោះមកភ្នំពេញនៅឆ្នាំ១៩៨០។ តើអ្នកដែលផ្តល់សក្ខីកម្មជូនលោក អ្នកដែលរៀបរាប់រឿងរ៉ាវជូនលោកនោះ មានបាននិយាយអំពីរឿងរ៉ាវទាំងឡាយណាដែលលោកបានជួបប្រទះដោយផ្ទាល់ដែរឬទេ?

[១១:៥៧:១១]

**ឆ៖** ដូចនៅក្នុងកំណត់ហេតុដែលខ្ញុំបានរៀបរាប់ជូនព្រឹត្តិការណ៍ក្រោយថ្ងៃរំដោះ ជាលើកទី២ថ្មីៗក្នុងឆ្នាំ៧៩ ទៅ៨០ ដែលខ្ញុំចុះទៅឃុំរំលេច ជាកន្លែងមួយដែលមានការស្លាប់ច្រើននៅពេលដែលប្រជាពលរដ្ឋមានការជ្រួលច្របល់ពីភាគីម្ខាងនៃកងទ័ពវៀតណាមមករំដោះ និងភាគីម្ខាងកម្ពុជាប្រជា-ធិបតេយ្យ ដែលគេទាំងអស់នោះជាជនស្លូតត្រង់ត្រូវចេញមករកជំនួយ ដែលថាមកខាងរំដោះ រំដោះថ្មីហ្នឹងគឺថាសកម្មភាពនោះ មានការបាញ់ស្មាក់ប្រជាពលហ្នឹងឯង ដែលយើងខ្ញុំទៅដល់ឃើញជាក់ស្តែងនៅមានឆ្អឹង អដ្ឋិធាតុ។ ដែលបច្ចុប្បនេះ នៅក្នុងរបាយការណ៍ក៏ខ្ញុំបានសរសេរដែរ ក៏ដូចបញ្ជាក់ដែរ។

ឆ្អឹងអដ្ឋិធាតុទាំងអស់នោះ គេបានសាងសងវត្តនៅក្នុងឃុំរំលេចនោះថ្មី។ សព្វថ្ងៃនេះ នៅដល់សព្វថ្ងៃ ដែលគេគោរពបូជា។ នេះជាព្រឹត្តិការណ៍មួយដែលខ្ញុំរន្ធត់ពន់ពេកទៅលើអ្វីដែលឃើញជាក់ស្តែង។ ហើយ ការរៀបរាប់នេះ គឺមានលោក ឌួង សូ ដែលជាប្រធានឃុំរំលេចនេះឯង។ សព្វថ្ងៃគាត់នៅរស់ទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកសាក្សី ខ្ញុំអរគុណលោកច្រើន។

ខ្ញុំសួរចប់ហើយ លោកប្រធាន។ លោកប្រធាន ខ្ញុំសូមអរគុណ។

[១១:៥៨:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អរគុណលោកសាក្សី។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះ ប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូល វិញ ដើម្បីបន្តកិច្ចដំណើការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬទីកន្លែង ណាមួយនៅក្នុងបរិវេណនៃ អ.វ.ត.ក សម្រាប់សាក្សីសម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មក កាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅម៉ោងមួយសាមសិននាទី រួមទាំងមេធាវីប្រឹក្សាសាក្សីផង។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាង ក្រោមសាលសវនាការនេះ និងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីជនជាប់ចោទ នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរ

ដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំឈ្មោះ សុន អរុណ ជាសហមេធាវីការពារលោក នួន ជា។ ជម្រាបសួរលោក ស៊ុម អាឡាត់។ ថ្ងៃនេះខ្ញុំនឹងមានសំណួរបួន, ប្រាំ, ប្រាំមួយ ដើម្បីសួរលោក។ សំណួរទី១របស់ខ្ញុំមានដូចតទៅ។ លោកសាក្សី លោកបានចូលធ្វើទាហានសម័យ លន់ នល់ ឆ្នាំ១៩៧២។ តើពេលនោះលោកមានអាយុពិតប្រាកដប៉ុន្មាន អាយុប៉ុន្មាន?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ខ្ញុំអាយុពិតប្រាកដនៅក្នុងឆ្នាំ១៩៧២ ខ្ទង់ប្រាំបី-ប្រាំបួនដណ្ដប់ហើយ។ ១៩ឆ្នាំហើយ។

**ស៖** អរគុណ។ លោកបានជម្រាបអង្គសវនាការថា ពេលដែលលោកចូលធ្វើជាទាហាន លន់ នល់ លោកមានឋានន្តរសក្តិ មានងារជាពលបាលត្រី នៅសេនាធិការខេត្ត។ សូមលោកបញ្ជាក់ឲ្យច្បាស់អំពីពាក្យ "សេនាធិការខេត្ត"។ លោកចង់និយាយថាយ៉ាងម៉េច "សេនាធិការខេត្ត" នោះ?

[១៣:៣៥:២៣]

**ឆ៖** ពាក្យនេះគឺការបកប្រែទេ។ តាមការពិតបច្ចេកទេសនៃពាក្យខាងទ័ព ខាងបារាំងគេហៅថា *អេតា-ម៉ាហ្ស័រស៊ុប ១ ដឺស៊ុយស្បុង (តាមសូរស័ព្ទ)* អាហ្នឹងគឺថាជាអគ្គសេនាធិការផ្នែកសឹករងខេត្តពោធិ៍សាត់។ និយាយរួមទៅផ្នែកការិយាល័យ។

**ស៖** ខ្ញុំចង់ឲ្យច្បាស់លាស់ពីរឿងថា អង្គសេនាធិការ ឬសេនាធិការខេត្ត។ ធម្មតាខាងមិនមានសេនាធិការ អគ្គសេនាធិការយោធានៅទុំងទេ។ ខេត្តជារដ្ឋបាលស៊ីវិល ហើយដល់សេនាធិការនេះសម្រាប់ទាហាន។ ត្រង់ហ្នឹងបានខ្ញុំចង់សួរបញ្ជាក់លោកឲ្យច្បាស់លាស់ពីរឿងលោកនិយាយពីសេនាធិការខាងទាហាន ម៉េចក៏ខាងខេត្តមានសេនាធិកាដែរ?

[១៣:៣៦:៣១]

**ឆ៖** សូមបញ្ជាក់ជូនអង្គប្រជុំ អង្គជំនុំជម្រះ។ នៅសម័យ លន់ នល់ កាន់ពីរអភិបាលខេត្តកាន់ពីរ។ ចាត់តាំងមកជាអភិបាលខេត្ត ជានាយទាហានទទួលបន្ទុកគឺមានសេចក្ដីសម្រេច ឬក៏ជាការរៀបចំ

នៃរាជរដ្ឋាភិបាលពីមុននោះ នៅកាលប្រទេសជាតិមានសង្គ្រាម គឺយោធាជាអ្នកកាន់កាប់។ ដូច្នេះកាន់ទាំងយោធាកាន់ទាំងស៊ីវិល។ ដូច្នេះលោក ព្រំ លីហួន ជាអភិបាលចេញពីយោធា ហើយក៏មានផ្នែកខាងស៊ីវិលហ្នឹងផងដែរ។ អ៊ីចឹងបានជាហេតុនៅក្នុងខេត្តដឹកនាំមានអគ្គសេនាធិការ។

**ស៖** ខ្ញុំចង់ឲ្យលោកកុំឲ្យមានការច្រឡំរវាងខេត្ត និងយោធា។ ទោះបីលោកថៅហ្វាយគាត់ជាទាហាន គាត់មកកាន់ថៅហ្វាយ ក៏នៅចែកដាច់ឡែកពីគ្នាដែរ។ ត្រង់ហ្នឹងខ្ញុំចង់បញ្ជាក់។ សូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់។ បើកាលណាលោកនិយាយមិនច្បាស់លាស់ មានន័យថាលោកនិយាយហ្នឹងមិនសូវប្រាកដប្រជាទេក្នុងខ្លួនលោក។ បើអ៊ីចឹងខ្ញុំសូមសួរតទៅទៀត--

[១៣:៣៧:៥៥]

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនដឹងថាតើនេះគឺជាសំណួរ ឬក៏មេធាវីការពារក្តីកំពុងតែផ្តល់ភស្តុតាងនៅក្នុងតុលាការ។ ខ្ញុំសូមថាកុំធ្វើសេចក្តីថ្លែងពាក់ព័ន្ធទៅនឹងថា គាត់យល់ពីរចនាសម្ព័ន្ធ ឬមិនយល់នោះ។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា ដើម្បីផ្ចាញ់ទៅសាក្សីថានិយាយពិត ឬក៏មិនពិតពីរឿងខ្លួនគាត់។ ត្រង់ខ្លួនគាត់ផ្ទាល់គាត់និយាយមិនពិត អាហ្នឹងក៏ធ្វើសក្ខីកម្មអត់កើតដែរ។

[១៣:៣៨:៥៥]

**ប្រធានអង្គជំនុំ៖**

ការស្តាប់សក្ខីកម្មពិត ឬមិនពិតជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ មិនមែនជារឿងរបស់មេធាវីដែលត្រូវបង្ហាញថាសាក្សីនិយាយមិនពិត ឬក៏និយាយកុហកនៅក្នុងកិច្ចដំណើរការសវនាការនោះទេ។ លោកសួរទៅបានលទ្ធផលយ៉ាងម៉េច អង្គជំនុំជម្រះនឹងយកមកពិចារណាហើយ។ បញ្ហាសំណួរប្រភេទនេះអង្គជំនុំជម្រះបានជម្រាបជូនភាគីច្រើនលើកច្រើនសាមកហើយ បើគិតរយៈពេលនៃការដេញដោលជិត២ឆ្នាំមកហើយ។ គួរតែត្រូវបានចងចាំនូវរបៀប និងទម្រង់ទាំងឡាយដែលអង្គជំនុំជម្រះកំណត់ឲ្យ

សួរដេញដោល ហើយប្រភេទសំណួរទាំងឡាយដែលអង្គជំនុំជម្រះហាមមិនសួរដេញដោល។ មិនមែនដាក់ធ្វើឲ្យបង្ហាញនូវការភូតកុហក ឬក៏និយាយមិនពិត នាំឲ្យសាក្សី ឬក៏គោលដៅដែលត្រូវទទួល ត្រូវឆ្លើយហ្នឹងបាត់បង់នូវជំនឿចិត្តរបស់ខ្លួននោះទេ។

សូមលោកមេធាវីជ្រាប។ លោកមេធាវីអាចសួរបាន ហើយការសួរក៏សូមឲ្យច្បាស់លាស់ដែរ រវាងអាចសំណួរហ្នឹងវាមិនច្បាស់លាស់ ជួនកាលសួរចូលគ្នាទៅមិនច្បាស់លាស់ សូមអង្គុន់សំណួរឲ្យបានច្បាស់លាស់ បើវាមិនខុសទេ រវាងអគ្គសេនាធិការ ឬសេនាធិការ។

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំបន្តសំណួរទៅមុខទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកបានជម្រាបទៅតុលាការថា លោកបានទៅកាន់សមរភូមិប្រយុទ្ធនៅស្រុកភ្នំក្រវាញជាសមរភូមិធ្ងន់ធ្ងរជាងគេនៅឆ្នាំ១៩៧៣។ ពេលនោះ តើលោកមានកាន់តួនាទីជាអ្វីនៅក្នុងកងទ័ពរបស់ លន់ នល់ នោះ?

[១៣:៤១:១៥]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ក្នុងនាមយើងធ្វើជាការិយាល័យ បុគ្គលិកការិយាល័យនៃអគ្គសេនាធិការទទួលបន្ទុកខាងប្រតិបត្តិការសឹក គេឲ្យយើងទៅតំណាងផ្នែកការិយាល័យហ្នឹងចុះផ្ទាល់ដល់សមរភូមិ។ អ៊ីចឹងខ្ញុំជាបុគ្គលិកទៅតាមគេទេ គឺមាន*បាត់ទីយ៉ុង (តាមសូរស័ព្ទ)*គេ មានអី ទ័ពគេទៅ ប៉ុន្តែផ្នែកអគ្គសេនាធិការគឺត្រូវមានមុខទៅជាមួយគេ។

**ស៖** ពេលដែលលោកទៅជាមួយគេនៅភ្នំក្រវាញនោះ លោកទៅជាមួយកងឯកភាពណា? ឯកភាពលេខប៉ុន្មាន? ហើយទៅនៅរយៈពេលប៉ុន្មាន?

**ឆ៖** ជាលក្ខណៈបច្ចេកទេសយោធា ចុះទៅប្រយុទ្ធក្នុងសមរភូមិ មានបែងចែកជាអេតា-ម៉ាហ្ស៊័រនៅក្នុងហ្នឹងដែរ អ៊ីចឹងជាលក្ខណៈយុទ្ធវិធីនៃសមរភូមិចុះទៅជាប់ជាមួយទ័ពផ្នែកខាងទាហានលន់ នល់ ចុះទៅរំដោះប្រជាពលរដ្ឋនៅភ្នំក្រវាញជាមុនមួយសប្តាហ៍។

**ស៖** ពេលនោះលោកចុះទៅជាមួយកងឯកភាពណាមួយ? ឧទាហរណ៍ថា កងវរសេនាធំលេខប៉ុន្មាន? កងវរសេនាតូច អនុសេនាធំលេខប៉ុន្មានអ៊ីចឹងទៅ?

[១៣:៤៣:២៣]

**ឆ៖** ខ្ញុំជម្រាបជូនហើយ គឺអគ្គសេនាធិការមានអង្គភាព ដឹកនាំទ័ព ដឹកនាំពលទាហានទៅគឺគេមាន*ស៊ិចស្យុង* គេមាន*កុំប៉ាញ៉ េ (តាមសូរស័ព្ទ)*គេ ប៉ុន្តែនៅក្រោមការបញ្ជារបស់អភិបាលខេត្តហ្នឹងឯង។

**ស៖** អរគុណ។ នៅខែមេសា ឆ្នាំ១៩៧៥ អង្គភាពឲ្យលោកទៅកាន់សមរភូមិស្ពានស្វាយដូនកែវ។ តើលោកចាំទេថាលោកទៅស្វាយដូនកែវនៅថ្ងៃទីប៉ុន្មាន? លោកបាននិយាយថានៅខែមេសា ឆ្នាំ១៩៧៥ តើនៅចាំ លោកចាំថ្ងៃទីប៉ុន្មានទេ?

**ឆ៖** ខ្ញុំនៅចាំស្ទាក់ស្ទើរដែរ ថ្ងៃ ប៉ុន្តែឆ្នាំប្រហែលជាខ្ញុំបានទៅបម្រើការងារចេញពីអគ្គសេនា-ធិការសាលាខេត្តទៅប្រហែលបាន១ឆ្នាំ។ ទៅកាន់កាប់នៅស្វាយដូនកែវហ្នឹងប្រហែលជា១ឆ្នាំចុងក្រោយ។

**ស៖** ពេលដែលលោកទៅស្វាយដូនកែវហ្នឹង លោកនៅក្នុង -- ជាបុគ្គលិករបស់សេនាធិការដដែល ឬក៏លោកនៅអង្គភាពណាផ្សេងទៀត?

**ឆ៖** អង្គភាពផ្សេងទៀត ប៉ុន្តែនៅក្រោមអគ្គសេនាធិការនៃផ្នែកសឹករងទាំងអស់។

**ស៖** បើតាមនៅក្នុងសំណួរចម្លើយរបស់ចៅក្រមស៊ើបអង្កេត លោកថាលោកបាននៅក្នុងអង្គ-ភាពកាំភ្លើងធំ។ អ៊ីចឹងមែនទេ?

[១៣:៤៥:៥៣]

**ឆ៖** ពិតជាអ៊ីចឹងមែន។

**ស៖** លោកនៅអង្គភាពកាំភ្លើងធំ ពេលនុំងលោកកាន់ជាអ្វី? មុនងារលោកជាអ្វីនៅក្នុងអង្គភាពកាំភ្លើងធំ?

**ឆ៖** ខ្ញុំកាន់ជាអ្នកក្រុមរៀបចំបាញ់។ បច្ចេកទេសសរសេរអក្សរកាត់ អឺ.ប៉េ.តេ – *អេគីបប្រេប៉ារេស្យុង ឌុយ ទៀរ (តាមសូរស័ព្ទ)* ។

**ស៖** ខ្ញុំសូមត្រឡប់ក្រោយវិញបន្តិច។ ខ្ញុំសូមសួរថា ពេលដែលលោកចូលធ្វើជាទាហានសាធារណរដ្ឋលន់នល់ តើលោកបានចូលហាត់រៀននៅសាលាយោធាទេ? ហើយលោកបានហាត់រៀនមានរៀនបច្ចេកទេសអ្វីទេ?

**ឆ៖** ពេលដែលចូលបម្រើទាហានផ្នែកលន់នល់ យើងខ្ញុំបានទៅរៀនស្ងួត្រមជ្ឈមណ្ឌលផ្នែកខាងសឹករងថ្មើរជើង នៅមណ្ឌលកំបូល – សេ.អ៊ី. កំបូល – នៅភ្នំពេញ។

**ស៖** ប៉ុន្តែលោកបានរៀនអំពីបាញ់កាំភ្លើងធំដូចលោកទៅកាន់នៅស្វាយដូនកែវហ្នឹងទេ?

[១៣:៤៧:៤៧]

**ធ៖** មុននឹងទៅកាន់កាំភ្លើង យើងខ្ញុំរៀនចំនួន ៣ខែ។

**ស៖** អរគុណ។ ត្រង់ចម្លើយរបស់លោកទៅកាន់ចៅក្រមស៊ើបអង្កេតថា "ទាហាន លន់ នល់ ខេត្តពោធិ៍សាត់ បានទទួលការណែនាំពីភ្នំពេញឲ្យទម្លាក់អាវុធតាមការប្រកាស តាមវិទ្យុពីលោក ម៉ី ស៊ីចន ឧត្តមសេនីយ៍នៅអគ្គសេនាធិការនៅភ្នំពេញ"។ ខ្ញុំសួរថា តើលោក ម៉ី ស៊ីចន ប្រកាសឲ្យទម្លាក់អាវុធនៅថ្ងៃណា? ហើយលោកបានឮផ្ទាល់ខ្លួនលោកទេ តាមវិទ្យុនោះ?

**ធ៖** ថ្ងៃខែមិនកំណត់ទេ។ ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំឮនឹងត្រចៀក។

**ស៖** ពេលលោក ម៉ីស៊ី -- ឧត្តមសេនីយ៍ ម៉ី ស៊ីចន បានប្រកាសនោះ ឬមុនពេល ម៉ី ស៊ីចន បានប្រកាសនោះ លោកដែលឮឈ្មោះឧត្តមសេនីយ៍ ម៉ី ស៊ីចន ទេ? ហើយពេលប្រកាសនោះលោកដឹងថា ម៉ី ស៊ីចន ហ្នឹងកាន់មុខងារអ្វីទេ?

**ធ៖** នៅពេលដែល ម៉ី ស៊ីចន ប្រកាសនោះ មិនបានដឹងជាគាត់កាន់អីទេ ប៉ុន្តែគាត់ជាឧត្តមសេនីយ៍ទោ គាត់បានខ្លួនគាត់ថាអ៊ីចឹង។ ឧត្តមសេនីយ៍ ម៉ី ស៊ីចន តំណាងឲ្យអគ្គសេនាធិការ -- *ដេហ្វង់ណាស្យូណាល់* ភ្នំពេញ -- បញ្ជាមកឲ្យទម្លាក់អាវុធ គ្រប់អង្គភាព។ គាត់តំណាង ជាតំណាងឲ្យយោធា ជាតំណាងឲ្យកងពលខេមរៈជាតិ។

[១៣:៤៩:៣៤]

**ស៖** អរគុណ។ លោកបានជម្រាបតំណាងសហព្រះរាជអាជ្ញាព្រឹកមិញថាមុនថ្ងៃលើកទង់ជ័យស ១ថ្ងៃ ទាហានលន់ នល់ បានទម្លាក់អាវុធពីយប់ ហើយបានទៅរាំវង់ជាមួយទ័ពខ្មែរក្រហម។ តើរាំវង់នៅកន្លែងណា? ហើយពេលដែលរាំវង់នោះមានទាហានខ្មែរក្រហមរាំប៉ុន្មាននាក់? ហើយទាហានលន់ នល់ រាំប៉ុន្មាននាក់? តើលោកបានឃើញហ្នឹងភ្នែក ឬលោកបានចូលរាំជាមួយអ្នកទាំងអស់គ្នានោះទេ?

**ធ៖** ព្រឹត្តិការណ៍ដែលខ្ញុំជម្រាបជូននេះ គឺជាព្រឹត្តិការណ៍ខ្លួនខ្ញុំផ្ទាល់ដែលនៅសមរភូមិស្វាយដូនកែវ។

**ស៖** លោកឆ្លើយមកខ្ញុំវិញអស់នៅ?

**ធ៖** ព្រឹត្តិការណ៍ដែលខ្ញុំបានជម្រាបជូននេះ គឺជាខ្លួនខ្ញុំផ្ទាល់នៅសមរភូមិស្វាយដូនកែវ ដែលពីល្ងាច យើងទាំងសងខាងនៅជួរមុខ ចាប់ដៃគ្នាយ៉ាងរីករាយ រាំជាមួយគ្នា ប្រហែលជា១០ ទៅ២០នាក់។

**ស៖** ពេលនោះ ពេលដែលរាំនោះ លោកបានចូលរាំជាមួយគេទេ? ឬលោកនៅកន្លែងណា

បើមិនបានចូលរាំទេ?

**ឆ៖** ខ្ញុំមិនបានចូលរាំទេ ប៉ុន្តែកូនចៅយើង អង្គភាពយើង។ ការរីករាយណាស់ នៅពេលដែលបានឮសូរថាខ្មែរនិងខ្មែរត្រូវគ្នា។ ហើយឲ្យចងអាវុធ ប្រាប់ថាសន្តិភាពមានហើយ យើងសប្បាយទាំងអស់គ្នា។ ហ្នឹងពីល្ងាច សភាពការណ៍ពីល្ងាច។ ប៉ុន្តែព្រឹកឡើងផ្សេង។

[១៣:៥២:៤៤]

**ស៖** សូមលោកឆ្លើយថា ពេលដែលគេរាំរែកពីយប់ហ្នឹង ខ្លួនលោកផ្ទាល់ហ្នឹង លោកនៅណា?

**ឆ៖** សូមបញ្ជាក់ជូនហើយ គឺខ្ញុំនៅក្នុងអង្គភាពស្វាយដូនកែវនេះឯង។

**ស៖** លោកសាក្សីឆ្លើយជម្រាបចៅក្រមស៊ើបអង្កេតថា "ខ្មែរក្រហមបានកាន់កាប់ពោធិ៍សាត់ទាំងមូលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ហើយនៅថ្ងៃទី២៤ ឬ២៥ ខែមេសា ឆ្នាំ១៩៧៥ គណៈតំបន់ឈ្មោះ សុត បានស្នើចៅហ្វាយខេត្តពោធិ៍សាត់សម័យលន់នល់ គឺលោកឧត្តមសេនីយ៍ព្រំ លីហ្លួន ឲ្យមកប្រជុំនៅសាលាខេត្ត ដែលមានមនុស្សប្រហែល៥០០នាក់ ទាំងយោធា ទាំងមន្ត្រីរដ្ឋ ព្រមទាំងសិស្ស និស្សិត ដើម្បីទៅទទួលអង្គការនៅទួលពោធិ៍ជ្រៃ"។ ខ្ញុំសួរថា -- សូមឲ្យលោកបញ្ជាក់មើលថា រយៈពេលពីថ្ងៃ១៧ ទម្លាក់អាវុធដែលខ្មែរក្រហមចូលមកដល់ខេត្តពោធិ៍សាត់ រហូតដល់ថ្ងៃ២៤ ឬ២៥ ពេលនុំងមានប្រជុំនៅសាលាខេត្ត ដោយលោកចៅហ្វាយខេត្តឈ្មោះ ព្រំ លីហ្លួន ហ្នឹងជាអ្នកចូលប្រជុំដែរ មានទាំងយោធា មានទាំងមន្ត្រី ស៊ីវិល មានទាំងសិស្ស និស្សិត។ ចន្លោះពេលហ្នឹង ចន្លោះថ្ងៃ១៧ មកថ្ងៃ២៤ហ្នឹង ដែលខ្មែរក្រហមចូលមកដល់ទីក្រុងពោធិ៍សាត់ហើយ ប្រជាពលរដ្ឋទាំងអស់ហ្នឹង នៅណា? ចៅហ្វាយខេត្តគេចាប់ -- ពេលហ្នឹងគេចាប់ចោល ឬក៏គេដេញទៅណាហើយ ឬក៏នៅពោធិសាត់ហ្នឹងនៅធ្វើការជាធម្មតា?

[១៣:៥៥:២៥]

**ឆ៖** បាទ ព្រឹត្តិការណ៍ហ្នឹងគឺអត់មានទៅណាទេ នៅមូលទាំងអស់ កំពុងតែធ្វើការធម្មតា។

**ស៖** អ៊ីចឹងមានន័យថាបើពេលដែលខ្មែរក្រហមថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមចូលដល់ក្រុងហើយ ឈ្នះហើយ ការងាររដ្ឋការនៅក្នុងក្រុងទាំងមូល – នៅក្នុងខេត្តពោធិសាត់ទាំងមូល – នៅធ្វើការធម្មតាអ៊ីចឹងអី បើតាមលោកឃើញ?

**ឆ៖** បានសេចក្តីថា រដ្ឋការស៊ីវិល។ អ្នកបម្រើការងារក្នុងខេត្តមិនទាន់ទៅណាទេ។

**ស៖** ពាក្យលោកមាននិយាយថា ប្រជុំនៅថ្ងៃទី២៤ ឬ ២៥ ខែមេសា, ពាក្យថា២៤ឬ ២៥ លោក

ចង់និយាយថាយ៉ាងម៉េច? ប្រជុំតែ១ថ្ងៃទេ ឬក៏ប្រជុំ២ថ្ងៃ?

**ឆ៖** ព្រឹត្តិការណ៍ដែលខ្ញុំ -- ២៤ ឬ២៥ -- ឬហ្នឹង ពាក្យ “ឬ” គឺចង់សរុបចូលគ្នាតែម្តងទេ ព្រឹត្តិការណ៍តែម្តងទេ។

**ស៖** ខ្ញុំសុំសួរម្តងទៀត។ គេប្រជុំថ្ងៃ ២៤ ឬក៏ប្រជុំថ្ងៃ ២៥?

**ឆ៖** ពាក្យ ២៤ ឬ ២៥ នេះតែមួយទេ ខ្ញុំមិនចាំថ្ងៃដោយដាក់ “ឬ”។

[១៣:៥៧:៥៥]

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ ព្រឹកមិញលោកសាក្សីបានឆ្លើយជម្រាបមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថាលោកបានឃើញឈ្មោះ តាសុត នៅមន្ទីរសន្តិសុខស-២១ ក្រោយមក។ តើលោកឃើញ តាសុត នៅមន្ទីរស-២១ ដោយរបៀបណា? លោកមកឃើញដោយខ្លួនឯង ឬលោកឮគេប្រាប់?

**ឆ៖** នៅពេលដែលខ្ញុំមករៀនសូត្រផ្នែកខាងគ្រូបង្រៀន ខាងអប់រំ។ គេឲ្យយើងមកមើល ទស្សនានៅគុកទួលស្លែង។ ខ្ញុំឃើញឈ្មោះរបស់លោក កែ គឹមហួត ហៅ សុត – គណៈតំបន់ទី៧ – ត្រូវគេសម្លាប់ថ្ងៃណា១ គឺមាន*ដោតតេ(តាមសូរស័ព្ទ)*នៅហ្នឹងស្រេច ទើបខ្ញុំដឹងថាគាត់បានមកស្លាប់នៅគុកទួលស្លែង។

**ស៖** ខ្ញុំសូមអរគុណ។

**លោក សុន អរុណ៖**

លោកប្រធានខ្ញុំអស់សំណួរហើយ សហភាតារបស់ខ្ញុំនឹងសួរបន្ត។ សូមអរគុណលោក ឡាត់។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:៥៩:២០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា និងភាគីទាំងអស់ ហើយនិងជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនចង់សួរលោកទាក់ទងទៅនឹងហេតុការណ៍នៅជុំវិញការប្រជុំពីរលើកនៅសាលាខេត្តដែលលោកបានលើកឡើងនោះ។ មុននឹងចូលដល់ប្រធានបទនោះសូមលោកប្រាប់ខ្ញុំបន្ថែមទៀតអំពីការកោះឲ្យទៅប្រជុំនោះការហៅឲ្យទៅប្រជុំដែលគេប្រកាសឲ្យទៅអតីតទាហាន ហើយនិងរាជការលន់នល់ ឲ្យទៅសាលាស្រុក។ ថាតើ

ផ្សព្វផ្សាយ ឬក៏ការជូនដំណឹងឲ្យមកប្រជុំហ្នឹងគេធ្វើរបៀបម៉េច?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ការផ្សព្វផ្សាយដែលឲ្យមកប្រជុំនោះ គឺហៅតៗគ្នាមក។ ដំណឹងតៗគ្នាមក ឲ្យជួបគ្នាថ្ងៃណាៗអ៊ីចឹង។

**ស៖** តើខ្ញុំយល់ត្រូវដែរឬទេ ថាពេលវេលាដែលគេប្រកាសឲ្យមកប្រជុំនោះ គឺក្រោយពេលដែលមានការជម្លៀសប្រជាជនចេញទីរួមខេត្តពោធិ៍សាត់ហើយ តើអ៊ីចឹងត្រូវឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ។

[១៤:០១:១៣]

**ស៖** តើខ្ញុំយល់ត្រូវដែរឬទេ ថារចនាសម្ព័ន្ធហើយនិងការិយាល័យនៃទាហានលន់ នល់ ត្រូវបានផ្អាកសកម្មភាពលែងដំណើរការតទៅទៀតហើយ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ថ្មីៗ ពេលថ្មីៗ មិនទាន់បែកទៅណាទេ នៅដំណើរការនៅឡើយ។

**ស៖** តើលោកចង់និយាយថា ការិយាល័យហើយនិងរចនាសម្ព័ន្ធនៃទាហានលន់ នល់ នៅដំណើរការនៅឡើយ មួយសប្តាហ៍ ឬក៏ពីរបីថ្ងៃក្រោយការរំដោះទីក្រុងពោធិ៍សាត់ហ្នឹងឬ?

**ឆ៖** ពិតមែនហើយ។

**ស៖** ប៉ុន្មានថ្ងៃមុនមានការប្រជុំនៅសាលាខេត្តពោធិ៍សាត់នោះ តើទាហានលន់ នល់ នៅតែធ្វើការនៅទីកន្លែងដែលគេធ្វើការហ្នឹងដែរឬទេ?

**ឆ៖** ថ្មីៗ ពុំទាន់នៅណាទេ នៅស្តាប់មេគើយនៅឡើយ។

**ស៖** សូមឲ្យលោកបញ្ជាក់ឲ្យច្បាស់ ក្នុងថ្ងៃ១៧ ខែមេសា ជាថ្ងៃរំដោះ ហើយនៅថ្ងៃពេលដែលមានការប្រជុំនៅសាលាខេត្តនោះ អតីតទាហានលន់ នល់ នៅតែដំណើរការនៅស្លៀកពាក់ឯកសណ្ឋានហើយនៅមានសកម្មភាពការងាររបស់គេនៅឡើយ តើអ៊ីចឹងមែនឬទេ?

[១៤:០៣:៣៩]

**ឆ៖** មានតែសកម្មភាព ប៉ុន្តែរូបភាពនៅមានបន្តិចខ្លះជាស៊ីវិល មិនចេញមិនបង្ហាញមុខទៅជាសម្លៀកបំពាក់ទ័ពនោះទេ។

**ស៖** ព្រឹកមិញនេះ លោកសាក្សី លោកបានឆ្លើយសំណួរទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីមេបញ្ជាការ ប៊ិល ហើយនិងមេបញ្ជាការ រ៉ុម។ តាមដែលខ្ញុំយល់ចម្លើយរបស់លោកនោះ

លោកពិតជាមិនបានស្គាល់អ្នកទាំងពីរហ្នឹងជាអ្នកណាទេ?

**ឆ៖** ពិតមែន។

**ស៖** ផ្អែកតាមភស្តុតាងដែលលោកបានឆ្លើយទៅអង្គជំនុំជម្រះពីខាងដើមនោះ ខ្ញុំយល់ឃើញថា មេបញ្ជាការ រុន និង ប៊ុល នោះជាមេបញ្ជាការបន្ទាយនៅទួលពោធិ៍នៅក្នុងភូមិពោធិ៍។ តើជាព័ត៌មានដែលលោកបានដឹងជាធម្មតាទេកាលនោះ តាមសមត្ថភាព ជាសមត្ថភាពដែលលោកពលបាលត្រីដែលទាហាន លន់ នល់ នោះ?

**ឆ៖** ខ្ញុំគ្រាន់តែបានដឹងថានៅក្រោមអនុសេនីយ៍ត្រីម្នាក់ឈ្មោះលោក សារុធ ប៉ុន្តែប៉ុស្តិ៍នៅទួលពោធិ៍ជ្រៃ គឺជាប៉ុស្តិ៍ជាជួរមុខ មិនដឹងគេដាក់ឈ្មោះស្អីខ្ញុំមិនដឹងទេ។ ប៉ុន្តែនៅក្រោមលោកអនុសេនីយ៍ត្រីមួយនាក់ដែលកាន់កាប់រួម ឈ្មោះលោក រុធ។

[១៤:០៦:១៥]

**ស៖** តើគាត់ជាអនុសេនីយ៍ត្រីឈ្មោះ ប៊ុល ហ្នឹងមែនទេ?

**ឆ៖** មិនមែនទេ។

**ស៖** បាទ តើមុខងាររបស់មេបញ្ជា ប៊ុល នោះ លោកដឹងទេមុនឆ្នាំ១៩៧៥ គាត់មានឋានៈអ្វី?

**ឆ៖** មិនបានដឹងទេ។

**ស៖** តើលោកដឹងមុខងាររបស់មេបញ្ជាការឈ្មោះ រុំ នោះទេ -- រ៉ុម បាទ?

**ឆ៖** អត់ដឹងទេ។

**ស៖** លោកក៏បានបញ្ជាក់ថា លោកបានដឹងខ្លះៗអំពីបន្ទាយទួលពោធិ៍ជ្រៃ ប៉ុន្តែមិនច្បាស់។ ទាក់ទងទៅនឹងការដឹងអំពីបន្ទាយនៅភូមិពោធិ៍ តើលោកដឹងពីអ្វីខ្លះអំពីបន្ទាយនៅភូមិពោធិ៍ដែរឬទេ?

**ឆ៖** ក្តាប់មិនបានទេ ខ្ញុំអត់បានដឹងទេនៅភូមិពោធិ៍។

**ស៖** តើលោកអាចពន្យល់ដោយសង្ខេបបានឬទេ តើការដឹងឮរបស់លោកទាក់ទងទៅនឹងមុខងារ ឬក៏សមត្ថកិច្ច ដែលថាអំណាចរបស់ឃោធារបស់ លន់ នល់ នៅក្នុងខេត្តពោធិ៍សាត់នោះ?

[១៤:០៨:១៩]

**ឆ៖** សុំសំណួរម្តងទៀត។

**ស៖** នៅក្នុងម៉ុខែមេសា ឆ្នាំ១៩៧៥ តើមុខងារជាក់លាក់របស់លោក ហើយនិងក្នុងឋានៈជាពលបាលត្រី តើភារកិច្ច ឬក៏ការចាត់តាំងហ្នឹងមានការងារអ្វីខ្លះនៅក្នុងអំឡុងពេលនោះ?

**ឆ៖** ក្នុងឆ្នាំ១៩៧៥ ក្រោយពេលៗក្រុមខ្មែរក្រហមចូលមកកាន់កាប់ហើយ រចនាសម្ព័ន្ធរបស់រដ្ឋការ លន់ នល់ ជាពិសេសគឺខាងទាហានរដ្ឋការ លន់ នល់ បានបែកខ្ញែក ពុំសូវជាល្អទេ បែកខ្ញែកហើយគឺថារប៉ាត់រប៉ាយហើយ។ ដូច្នេះការទទួលខុសត្រូវ ពុំមានអ្វីដែលក្រឹត្យក្រមនោះទេ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត ប៉ុន្តែខ្ញុំសូមជម្រាបថា ខ្ញុំនៅឆ្ងល់អំពីរឿងហេតុដែលថាលោកមិនស្គាល់ថាមេបញ្ជាការទាំងពីរនាក់នេះ ហើយលោកក៏មិនដែលស្គាល់បន្ទាយនៅភូមិពោធិ៍។ តើលោកអាចពន្យល់អង្គជំនុំជម្រះបានទេ ថាហេតុអីបានជាលោកមិនបានដឹងពីរឿងហេតុទាំងអស់នេះ ពីព្រោះទីកន្លែងនិងមនុស្សទាំងអស់នេះនៅកន្លែងជិតរបស់លោក -- កន្លែងរបស់លោក?

**ឆ៖** មូលហេតុដែលយើងពុំបានទាក់ទងគ្នានោះ គឺចម្ងាយដែលយើងខ្ញុំកាន់កាប់នៅសមរភូមិស្វាយដូនកែវ បែកខាងលិចទល់ដែន ព្រំដែនបាត់ដំបង-ពោធិ៍សាត់។ ឯភូមិពោធិ៍ គឺបន្ទាយពោធិ៍ជ្រៃគឺនៅខាងស្រុកកណ្ដៀងឯណោះ។ ដូច្នេះការទំនាក់ទំនងពុំបានដឹងច្បាស់លាស់ទេ។

[១៤:១១:00]

**ស៖** សំណួរចុងក្រោយអំពីប្រធានបទនេះលោកសាក្សី តើលោកដឹងទេថាមេបញ្ជាការ ប៊ិល ហើយនិង រុន ហ្នឹងជួបជោគវាសនាដូចម្ដេចដែរ ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំពុំដែលបានទទួលដំណឹងអ្វីទាំងអស់។

**ស៖** ខ្ញុំនឹងចូលទៅដល់ពេលខាងមុខទៀត ១ថ្ងៃ ឬ២ថ្ងៃដែលមានការប្រជុំនៅអគាររបស់សាលាខេត្ត។ ព្រឹកមិញនេះលោកបានឆ្លើយសំណួរសហព្រះរាជអាជ្ញានិយាយអំពីអគារមួយដែលគេរៀបចំការប្រជុំនៅទីនោះ។ ដែលនិយាយពីបញ្ហានេះដោយសង្ខេប ប៉ុន្តែខ្ញុំនឹងសួរលម្អិតតទៅទៀត។ លោកបាននិយាយថាមានមនុស្ស ៥00នាក់ដែលប្រមូលគ្នាមកចូលរួមប្រជុំ។ តើលោកអាចពន្យល់ម្ដងទៀតបានដែរឬទេថា តើអគារមួយណាដោយប្រាកដ ដែលថាមនុស្ស៥00នាក់ហ្នឹងអាចបានប្រមូលផ្ដុំគ្នាដើម្បីប្រជុំនោះ។ អគារមួយណា?

**ឆ៖** ខ្ញុំបានជម្រាបជូនជ្រាបព្រឹកមិញហើយ ឯកសារបង្ហាញពីអគារនោះគឺបើយើងចូលពីខាងមាត់ផ្លូវ អគារដែលប្រជុំនោះគឺនៅខាងឆ្វេងនៃអគារព្រឹកមិញ នៅខាងឆ្វេង។ ប្រហែលជា ៣0 ទៅ ៤0 ម៉ែត្រមានអគារមួយទៀតមួយជាន់ទេ ហៅថាសាលាខេត្ត មិនមែនប្រហ្គង់អូតែលទេ សាលាខេត្ត។

[១៤:១៣:១៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញជូនសាក្សីម្តងទៀតនូវរូបថតពីរ។ សូមអនុញ្ញាតបង្ហាញលើអេក្រង់ពីឯកសារ D25/217, អង់គ្លេសគឺ 00294216, ខ្មែរ 6077014 (*ស៊ីក*)។ ហើយសូមអនុញ្ញាតបើបញ្ចាំងរូបថតទាំងពីរនេះលើអេក្រង់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** តើលោកសាក្សីឃើញរូបថតទាំងពីរនេះដែរឬទេ? រូបថតមួយខាងលើគឺជាអគារដែលមានរបងនៅខាងមុខ ហើយរូបថតខាងក្រោមគឺរូបថតដដែល ប៉ុន្តែមានមនុស្សម្នាក់ឈរនៅខាងស្តាំនៃច្រកចូល។ តើលោកបានឃើញរូបទាំងពីរនេះច្បាស់ហើយឬនៅ?

**លោក ស៊ុំ អាឡាត់៖**

**ឆ៖** បាទ ឃើញហើយ។

**ស៖** រូបថតអគារដែលយើងឃើញក្នុងរូបថតទាំងពីរ តើហ្នឹងគឺជាសាលាខេត្ត ជាមន្ទីរអគារសាលាខេត្ត តើអ៊ីចឹងទេ?

**ឆ៖** នេះ គឺជាសណ្ឋាគារខេត្ត សណ្ឋាគារសម្រាប់អភិបាលខេត្តនៅទេ។ មិនមែនសាលាខេត្តធ្វើការរដ្ឋបាលទេ។

[១៤:១៥:៣៥]

**ស៖** តើលោកច្បាស់ទេអំពីចម្លើយ -- បាទ តើជាកន្លែងដែលអភិបាលខេត្តរស់នៅសព្វថ្ងៃហ្នឹង ឬក៏យ៉ាងម៉េចដែរអគារនេះ?

**ឆ៖** អគារពីរជាន់នេះ គឺជាអគាររបស់អភិបាលខេត្តនៅជំនាន់សម័យ លន់ នល់។ ពេលដែលគេផ្លាស់មកខេត្ត គឺគេទទួលឱ្យនៅត្រង់ហ្នឹង គឺសណ្ឋាគារ ហ្រ្គង់អូតែល១។ ដោយឡែកមានខាងឆ្វេងដៃមានសាលាមួយទៀត មួយខ្នងវែង គេហៅថាសាលាខេត្ត កន្លែងធ្វើការ។

**ស៖** តើលោកចូលទៅក្នុងអគារហ្នឹង លោកចូលទៅតាមច្រកទៅបត់ឆ្វេង ឬក៏មានផ្លូវមួយទៀតខាងឆ្វេងដៃ មុនចូលទៅដល់អគារនោះបាទ អគារដែលថាសាលាខេត្តនោះបាទ?

**ឆ៖** ទ្វារមានពីរ។ អម្បាញ់មិញ គឺទ្វារនៅទល់មុខសណ្ឋាគារ។ ទ្វារខាងឆ្វេងដៃមានទ្វារមួយ

ចូលហៅថាចូលទៅសាលាខេត្ត។

[១៤:១៧:០៧]

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់ទៅចំណុចនៅថ្ងៃនោះ គឺថាប្រហែលលោកឃើញមនុស្ស៥០០នាក់ ដែលទៅកន្លែងហ្នឹង ដែលចូលតាមច្រកដែលលោកឃើញនៅក្នុងរូបថតនេះ ឬក៏ចូលតាមច្រកមួយទៀត ដែលលោកនិយាយអម្បាញ់មិញ?

**ឆ៖** ចូលច្រកមួយទៀតៗ ច្រកខាងឆ្វេងដៃទ្វារមួយទៀត។

**ស៖** ខ្ញុំសួរលោកសាក្សីបន្ថែមទៀតឲ្យលោកគិតឲ្យប្រុងប្រយ័ត្ននៅក្នុងការឆ្លើយ ហើយព្យាយាម រំឮកឲ្យឃើញថា តើថាមនុស្សមិនចូលតាមខ្លោងទ្វារនេះទេ គឺចូលតាមខ្លោងទ្វារមួយទៀតនៅខាងឆ្វេង។ អ៊ីចឹងសូមឲ្យលោកគិត ខ្ញុំនឹងសួរបន្ត។

**ឆ៖** ខ្លោងទ្វារទី១ ដែលចូលមកតាមហ្នឹង គឺជាខ្លោងទ្វារប៉ែកខាងរៀបចំអគ្គសេនាធិការ ផ្នែក ខាងយោធា។ ខាងឆ្វេងដៃគឺផ្សេងរដ្ឋបាលស៊ីវិល។ កាលដែលប្រជុំនេះ គឺប្រជុំនៅផ្នែកខាងឆ្វេងដៃខ្លោង ទ្វារទី២ ក៏ប៉ុន្តែក៏មិនបិទខ្លោងទ្វារទី១ដែរ កាលដែលប្រជុំនោះ។

[១៤:១៩:០៧]

**ស៖** ខ្ញុំនឹងពន្យល់ជូនលោកពីមូលហេតុអ្វីដែលខ្ញុំបន្តសួរសំណួរនេះ ថាអគារមួយណាដែលគេ ប្រជុំនោះ។ លោកបានឃើញហើយនៅក្នុងរូបថតទាំងពីរនេះ ជាពិសេសយើងឃើញច្បាស់ រូបថតនៅ ខាងក្រោមមានមនុស្សម្នាក់ដែលឈរនៅក្បែរខ្លោងទ្វារចូល។

បាទ ហ្នឹងសូមអនុញ្ញាតបង្ហាញរូបថតនេះនៅលើអេក្រង់ម្តងទៀត។

លោកសាក្សី តើលោកឃើញបុរសនេះដែលឈរនៅខាងស្តាំដៃនៃខ្លោងទ្វារហ្នឹងទេ?

**ឆ៖** ឃើញហើយ។

**ស៖** បុរសនៅក្នុងរូបថតនេះដែលលោកឃើញនេះជាបុគ្គលម្នាក់ដែលបានមកធ្វើជាសាក្សីនៅ ទីនេះកន្លងមកនេះឯង។ គាត់បានធ្វើសក្ខីកម្មជូនអង្គជំនុំជម្រះថា តាមពិតគាត់នៅកន្លែងនោះ គឺថាក្នុង សប្តាហ៍បន្ទាប់ពីថ្ងៃទី១៧ ខែមេសា។ ហើយគាត់បានបញ្ជាក់ប្រាប់តុលាការអំពីអង្គប្រជុំដែលលោកបាន និយាយនេះឯង។ គាត់ថាអង្គប្រជុំនោះគឺបានរៀបចំនូវអគារដែលយើងបានឃើញនៅក្នុងរូបថតនេះឯង ហើយគាត់បានរៀបរាប់ពីទិដ្ឋភាពនៃអគារនេះជាផ្នែកនៃសក្ខីកម្មរបស់គាត់នៅថ្ងៃនោះ គឺថាមានមនុស្ស រហូតទៅដល់២០០នាក់ជាង ដែលបានប្រជុំ ហើយគាត់ជាអ្នកយាមនៅពេលនោះ។ បាទ នេះជាសេចក្តី

សង្ខេបខ្លះជូនលោកដើម្បីឲ្យលោកគិត ដើម្បីនឹងឆ្លើយ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:២១:១៤]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុចពីរដើម្បីលើកឡើង។ ទី១ ខ្ញុំមិនច្បាស់ ហើយខ្ញុំមិនប្រាកដថាតើមេធាវីត្រូវយកមកបញ្ជាក់ដែរឬអត់ ដែលថារូបថតនេះដែលបង្ហាញនៅលើអេក្រង់នេះ គឺជារូបថតដែលបានបង្ហាញទៅសាក្សីដែលមកផ្តល់សក្ខីកម្មជាមុននោះទេ។ បើសិនជាករណីនោះមែន ប៉ុន្តែមិនមែនជាករណីនោះទេ សេចក្តីសន្និដ្ឋានដែលថាសាក្សីនោះបានបញ្ជាក់សក្ខីកម្មថាមានការប្រជុំនៅអគារទាំងអស់នោះ។ ខ្ញុំមិនគិតថាជាភាពសមស្របដើម្បីសួរផ្ទុញនឹងសាក្សីរូបនេះទេ។ ជាការល្អមេធាវីគ្រាន់តែសួរសាក្សីថាតើរបងហ្នឹងដែលគាត់ឃើញរាល់ថ្ងៃហ្នឹង ដូចរបង ដូចច្រកទ្វារកាលពីមុនឆ្នាំ១៩៧៥ ដែរឬទេ? មានការកែប្រែឬអត់? ហើយខ្ញុំមិនគិតថាសាក្សីពីមុននោះបានបង្ហាញ ទទួលឃើញរូបថតនេះនោះទេ។

[១៤:២២:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

រូបថតនេះបានបង្ហាញទៅសាក្សី អ៊ុង ឆាត គឺទំព័រមកពីរបាយការណ៍ដែលរៀបចំឡើងដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយយើងនឹងអាចឃើញនៅក្នុងទំព័រដដែលហ្នឹងនៅខាងស្តាំដៃនិយាយថា៖ “សាក្សី អ៊ុង ឆាត រៀបរាប់អំពីទិដ្ឋភាពជញ្ជាំងរបងរបស់ទីបញ្ជាការខេត្ត”។ ហើយយើងមានសាក្សីមកធ្វើសក្ខីកម្ម មកបង្ហាញសក្ខីកម្មនេះ គឺថាមិនមានអ្វីឆ្ងល់ទេ សាក្សីបានយោងទៅអគារនោះឯង។ ហើយយើងឃើញថា យើងសួរសាក្សីថាតើដើម្បីឲ្យធ្វើការវាយតម្លៃមានចំនួនមនុស្សប៉ុន្មាននាក់នៅក្នុងសាលសាធារណៈយើងបានសួរសាក្សីរូបនោះ។ អ៊ីចឹងគឺថាគាត់និយាយអំពីការប្រជុំដដែលនៅកន្លែងដដែល ហើយគាត់បានផ្តល់សក្ខីកម្មនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយគាត់នោះបានបញ្ជាក់ថា នេះឯងគឺជាអគារដែលគាត់និយាយថាមានការប្រជុំនាកាលនោះ។ ហើយខ្ញុំមិនឃើញថាមានការភ័ន្តច្រឡំទាក់ទងទៅនឹងសក្ខីកម្មណាមួយរបស់អតីតអ្នកយាម អ៊ុង ឆាត និយាយអំពីអ្វីនោះទេ យើងច្បាស់ហើយ។ ដូច្នេះ ខ្ញុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីប្រឈមតទល់ជាមួយ

សាក្សីនេះ ដែលខ្ញុំយកសក្ខីកម្មរបស់អតីតអ្នកយាម គាត់មិនបាននិយាយថាមានការរៀបចំអង្គប្រជុំនៅអគារផ្សេងនោះទេ។

**លោក វីណ្ឌៀម ស្មីត៖**

លោក លោកស្រីចៅក្រម ប្រហែលនេះគឺជាការចង្អុលបង្ហាញនៅក្នុងរបាយការណ៍នេះ ដែលប្រៀបធៀបមកនឹងសក្ខីកម្ម គឺការដែលមេធាវីបញ្ជាក់ថាមិនមានអ្វីសង្ស័យផ្អែកលើនេះ គឺថាមិនត្រឹមត្រូវទេ។ ហើយសាក្សីបាននិយាយថា ការប្រជុំនោះធ្វើឡើងនៅសាលាខេត្ត គេនិយាយអំពីបរិវេណជាមួយគ្នា។ នៅក្នុងបរិវេណធំនោះវាមានអគារជាច្រើន វាអាចជាករណីដែលថាសាក្សីអាចនឹងបានគិតថានោះគឺជាអគារមែននោះហើយ។ ដូច្នេះ យើងមិនទាន់ច្បាស់ថាតើគេពិភាក្សាអ្វីអំពីនៅក្នុងតុលាការ ដែលថាតាមពិតនោះគឺជាអគារដែលបង្ហាញ។ ប៉ុន្តែមេធាវីមិនអាចធ្វើសេចក្ដីសន្និដ្ឋានទៅឲ្យសាក្សីនេះសម្រេចទេ ត្រូវតែសួរសំណួរឲ្យគាត់ឆ្លើយ។ ដូច្នេះគឺថា យើងខ្ញុំយល់ថាមេធាវីមិនគប្បីធ្វើការសន្និដ្ឋានបែបនេះឲ្យសាក្សីបញ្ជាក់នោះទេ។

[១៤:២៥:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៧:៣០]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ! អង្គជំនុំជម្រះសូមជម្រាបលោកថា ទំនងជាលោកអាចភាន់ច្រឡំទៅលើកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្ម អ៊ុង ឆាត មិនមានការបង្ហាញនូវរូបភាពអគារដែលលោកលើកបង្ហាញនាពេលនេះទេ។ទី២ សាក្សីដែលបានផ្ដល់សក្ខីកម្មកន្លងមកនេះមិនទាន់មានសាក្សីណាមួយចង្អុលបង្ហាញពាក់ព័ន្ធទៅនឹងទីបញ្ជាការខេត្តទេ។ សុទ្ធតែបញ្ជាក់ថាជួបជុំនៅសាលាខេត្តពោធិ៍សាត់ទាំងអស់។ ទី៣ រូបភាពដែលលោកបានបង្ហាញនេះ ទី១ គឺដាក់ថាទីបញ្ជាការខេត្តមិនមែនសាលាខេត្តទេ។ ទី២ គ្រាន់តែចង្អុលបង្ហាញថា អ៊ុង ឆាត កាលពីព្រឹត្តិហេតុ ព្រឹត្តិការណ៍ដែលកើតមានឡើងនោះ គឺគាត់ឈរនៅទីនុំងឯង។ ដូច្នេះ មិនមានមូលដ្ឋានអីមកសួរដេញដោលឲ្យសាក្សីរូបនេះឆ្លើយតាមតែបំណងរបស់លោកមេធាវីនោះទេ។ ព្រោះអង្គហេតុដែលលោកលើកឡើងសង្ខេបនេះមិនសមស្របទេ។ លោកអាចតាំងសំណួរដេញដោលបន្តទៅទៀតក្នុងស្ថានភាពដែលក្នុងនាមជាសាក្សី។ មិនផ្អែកលើមូលដ្ឋាននៃរូបភាពដែលលោកកាន់នេះដែលមិនមានការដេញដោលចំពោះសាក្សីលើកមុនទេ ហើយការដកស្រង់ក៏មិនត្រឹម

ត្រូវដែរ។ សូម្បីតែពាក្យពេចន៍ពីបញ្ហាការខេត្តនិងសាលាខេត្ត ខុសគ្នាឆ្ងាយណាស់លោកមេធាវី។

[១៤:២៩:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

យើងឃើញថា ខ្ញុំបានទៅទីនោះ ខ្ញុំយល់ថាខ្ញុំធ្វើត្រឹមត្រូវ។ ខ្ញុំគិតថាមិនមានអគារមួយផ្សេងទៀតនៅខាងឆ្វេងដែដូចដែលសាក្សីនិយាយទេ។ ហើយអ្នកអង្កេតបានធ្វើកំណត់ទីតាំងនោះ ក៏គាត់បានបញ្ជាក់បែបនេះដែរ។ ក្នុងការបញ្ជាក់សាក្សី អ៊ុង ឆាត បានឈរនៅមុខអគារនេះ ហើយសាក្សីបាន គាត់ថាមានអគារមួយទៀត ប៉ុន្តែអគារដែលគាត់និយាយនោះ មិនមែនទៅទីនោះទេ វាអត់ឃើញទេ។ ដូច្នេះហើយបានខ្ញុំបង្ហាញរូបថតនេះ ថាតើស្គាល់ ឬមិនស្គាល់? ដូច្នេះ យើងបានរបាយការណ៍ដោយមានរូបថតដោយ អ៊ុង ឆាត គាត់បានស្បថ ហើយគាត់បានបញ្ជាក់ចង្អុលបង្ហាញ។ ដូច្នេះ នេះជាការពិតហើយថាពិតជាអគារនោះ។

**ប្រធានអង្គជំនុំ៖**

ច្បាស់លាស់ហើយថាបញ្ហា អ៊ុង ឆាត -- ប៉ុន្តែ អ៊ុង ឆាត បញ្ជាក់ថាកន្លែងហ្នឹងគឺគាត់ឈរ នៅទីនោះ នៅក្នុងអំឡុងពេលដែលព្រឹត្តិការណ៍ដែលកើតមានឡើង។ មិនមែនគាត់ចង្អុលថាកន្លែងអគារដែលគាត់ឈរពីមុននេះជាកន្លែងប្រជុំទេ។ អ៊ុង ឆាត ឆ្លើយច្បាស់លាស់ណាស់ គឺកន្លែងជួបជុំគ្នានៅសាលាខេត្តពោធិ៍សាត់ ហើយសាលាខេត្តពោធិ៍សាត់បើសិនជាមិនច្រឡំទេ តាំងពីដើមមករហូតដល់ពេលនេះមិនមានការផ្លាស់ប្តូរទីតាំងទេ។

[១៤:៣១:១៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដោយសារថាពេលវេលាមានកំណត់ ខ្ញុំនឹងបន្តទៅមុខ ប៉ុន្តែខ្ញុំនឹងសួរបន្តទៅទៀតដើម្បីបញ្ជាក់ជាមួយសាក្សីរូបនេះ។ លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

បើលោកចង់សួរច្បាស់ លោកផ្អែកលើប្រតិចារឹកដែលសួរ អ៊ុង ឆាត យកមកធ្វើជាមូលដ្ឋានក្នុងតាំងសំណួរ ដើម្បីជៀសវាងមានការភាន់ច្រឡំ ពីព្រោះអក្សរខ្មែរគឺសរសេរច្បាស់ ខុសគ្នាឆ្ងាយណាស់ ហើយរូបថតនេះមិនទាន់ដែលបង្ហាញនៅក្នុងកិច្ចពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

តើរបាយការណ៍កំណត់ទីតាំងហ្នឹង នឹងមានប្រយោជន៍ជាដូចម្ដេច បើយើងប្រើមិនកើតនោះ។

**ស៖** លោកសាក្សី លោកបាននិយាយខាងដើមថាមានមនុស្ស៥០០នាក់ ដែលគេប្រមូលមកឱ្យប្រជុំនៅអគារមួយ។ តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើលោកអាចរាប់ដូចម្ដេចទើបដឹងថា៥០០នាក់នោះ?

[១៤:៣២:២៤]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំមិនចង់រំខានច្រើនទេពេលវេលា។ សាក្សីបានឆ្លើយទៅនឹងសំណួរគឺថា មនុស្ស៥០០នាក់មិនអាចចូលក្នុងអគារទាំងអស់ទេ មានអ្នកខ្លះនៅខាងក្រៅអគារ។ ដូច្នេះ យើងឃើញច្បាស់ហើយនៅក្នុងចម្លើយរបស់គាត់។ គាត់ថា -- សួរថា៥០០នាក់នៅក្នុងអគារឬអត់? គាត់ឆ្លើយថា៖ "មិនមែននៅក្នុងហ្នឹងទាំងអស់ទេ មានអ្នកខ្លះនៅក្រៅអគារ"។ អ៊ីចឹងយើងច្បាស់ពីគាត់។

**លោក វ៉ិចទ័រ កូប៉េះ៖**

គឺត្រូវហើយ ខ្ញុំនឹងរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី ព្រឹកមិញនេះ លោកនិយាយថាមានប្រហែល១០០ -- អ៎! ៥០០នាក់នៅក្នុងនិងជុំវិញអគារដែលគេរៀបចំប្រជុំនោះ។ តើលោកអាចពន្យល់អង្គជំនុំជម្រះដូចម្ដេច ថាតើលោករាប់ ឬក៏លោកដឹងតាមរបៀបណាថា៥០០នាក់ហ្នឹង?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ប្រហាក់ប្រហែល ការប៉ាន់ស្មានទេ។ មិនបានរាប់ មួយ ពីរ បី បួន ប្រាំ ទេ។

**ស៖** តើលោកផ្អែកទៅលើការប៉ាន់ប្រមាណដោយផ្ទាល់ខ្លួនហ្នឹង តើលោកកំណត់ចំនួន៥០០ហ្នឹងដូចម្ដេច ម៉េចមិនថា៤០០? ៤៥០ ឬក៏៣០០? ម៉េចក៏លោកច្បាស់ថា៥០០?

[១៤:៣៣:៥៩]

**ឆ៖** ច្បាស់ខ្លួនឯងថា៥០០ ព្រោះវាប្រហែលតែ៥០០ហ្នឹងឯង មិនដឹងយ៉ាងម៉េចទៀតឱ្យច្បាស់។

**ស៖** តើលោកបានរាប់ទេ? តើលោកបានធ្វើការប៉ាន់ប្រមាណផ្អែកលើអ្វី? តើលោកមានបទពិសោធន៍ក្នុងការរាប់ក្រុមមនុស្សធំបែបនេះ ហើយលោករាប់ស្មានត្រូវ ឬដូចម្ដេច?

**ឆ៖** ចំនួនទិដ្ឋភាពនៅតាមខាងក្នុង និងខាងក្រៅ បើប៉ាន់ប្រមាណប្រហាក់ប្រហែលទៅតាមស្ថានភាពដែលយើងប្រជុំនៅពេលនោះ។

**ស៖** នៅតែមានភាពច្របូកច្របល់ជាមួយចម្លើយរបស់លោក។ មនុស្ស៥០០នាក់ គឺថាច្រើនណាស់។ តើនៅពេលហ្នឹងមនុស្សឈរទាំងអស់គ្នា ឬក៏មានឈរ មានអង្គុយខ្លះ មាននៅក្នុងអគារ មាននៅក្រៅអគារ ដើរចុះដើរឡើងជុំវិញអគារ ឬក៏យ៉ាងណា? សូមលោករៀបរាប់ប្រាប់បន្តិចមើល។

**ឆ៖** មានអង្គុយ មានឈរ មានដើរគ្រប់ផ្នែកទាំងអស់។ មិនមែនមូលអង្គុយក្តុំទាំងអស់ទេ មានអង្គុយខាងក្នុង ខាងក្រៅហូរហៀរ និងដើរខាងក្រៅខ្លះ។ គឺគេប្រជុំ គេប្រជុំយើងទៅស្តាប់ គេផ្សព្វផ្សាយអំពីអ្វី? អ៊ីចឹងយើងអាចនៅខាងក្រៅ នៅខាងក្នុង អ៊ីចឹងមនុស្សច្រើន។

[១៤:៣៦:១៣]

**ស៖** ខ្ញុំមានសំណួរដូចគ្នានេះដែរ និយាយពីចំនួន២០០។ នៅក្នុងចំណោមមនុស្ស៥០០នាក់ហ្នឹង គឺ២០០នាក់ -- ប្រហែលជា២០០នាក់ជាទាហាន។ តើធ្វើម៉េចបានលោកដឹង? លោករាប់ម្តងមួយៗរហូតដល់២០០ហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំប៉ាន់ប្រមាណទេ បើតាមការស្គាល់ ការឃើញ ធ្លាប់ស្គាល់ខ្លះ ប៉ាន់ប្រមាណទេមិនបានរាប់ មួយ ពីរ បីទេ។

**ស៖** អ៊ីចឹងថាតើអាច១៥០ ឬក៏២១០ ឬក៏១០០អ៊ីចឹងដែរទេ?

**លោក វីល្លៀម ស្មីត៖**

សូមជំទាស់លោកប្រធាន។ មេធាវីការពារក្តី គឺគាត់សួរទៅសាក្សីឲ្យឆ្លើយស្មានៗ។ សាក្សីស្មានជារឿងរបស់គាត់ ប៉ុន្តែចំពោះមេធាវីមិនអាចសួរបន្ថែមឲ្យសាក្សីឆ្លើយស្មានបែបនេះបានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងមេធាវី -- សាក្សីអាចឆ្លើយស្មានបាន តែខ្ញុំមិនអាចសួរឲ្យឆ្លើយស្មានបានទេ អ៊ីចឹងឬយ៉ាងម៉េច?

**លោក វីល្លៀម ស្មីត៖**

សាក្សីគាត់អាចឆ្លើយស្មាន គឺសិទ្ធិរបស់គាត់ក្នុងឆ្លើយចំនួនណាមួយនោះ។

[១៤:៣៧:៥៣]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់មានមូលហេតុ ហេតុផលសមស្រប។ សាក្សីមិនបាច់ឆ្លើយទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីការពារក្ដីនេះទេ។

ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី រួមទាំងមេធាវីប្រឹក្សាសាក្សីផង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមបញ្ជាក់ផងដែរ ថាតើបែងចែកពេលវេលាជាមួយនឹងមេធាវីការពារក្ដីលោក ខៀវ សំផន យ៉ាងម៉េចដែរ ពេលវេលាដែលសេសសល់នេះ? លោក កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន យើងទើបពិភាក្សាគ្នាអម្បាញ់មិញនេះ។ នេះគឺសំណើសុំតំណាងឱ្យក្រុមមេធាវីការពារក្ដីទាំងពីរសូមបន្ថែមម៉ោងផងដែរ។ ដូច្នេះ គោលបំណងរបស់យើងខ្ញុំគឺ ខ្ញុំអាចនឹងបញ្ចប់នូវម៉ោងបួន ហើយក្រុម ខៀវ សំផន សូមបន្តជាប់រហូតដល់ម៉ោងបួនសាមសិបនាទី។

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជំនុំជម្រះអនុញ្ញាតបន្ថែមឲ្យ ២០នាទី ស្មើគ្នាជាមួយនឹងភាគីម្ខាងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាក ខ្ញុំសួរអំពីចំនួនមនុស្សនៅក្នុង និងនៅជុំវិញអគារនោះ បើសិនជាខ្ញុំយល់មិនច្រឡំទេសក្ខីកម្មរបស់លោកគឺនិយាយថាមានមនុស្សប្រហែលជា៣០នាក់នៅក្នុងចំណោមក្រុមហ្នឹងគឺជាទាហានដែលមកពីទួលពោធិ៍ជ្រៃ។ សូមលោកជម្រាបអង្គជំនុំជម្រះថា ធ្វើម៉េចបានជាលោកដឹងថានៅក្នុងចំណោមនុ៎ងមានទាហានប្រហែលជា៣០នាក់មកពីបន្ទាយទួលពោធិ៍ជ្រៃនោះ?

[១៥:០៣:២៧]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ការណ៍នេះគឺជា គេហៅថាប្រមូលផ្តុំគ្រប់អង្គភាពដែលមានស្តាប់ហ្នឹង ឲ្យមកស្តាប់ហ្នឹង ប្រហែលជាគេឲ្យមកគ្រប់ទិសទី ប៉ុន្តែក្នុងនោះខ្ញុំបានស្គាល់ខ្លះៗ ទៅតាមមិត្តភក្តិដែលមកពីណាៗ ការដែលជួបគ្នាហ្នឹង ទើបខ្ញុំស្មានប្រហែលជាប៉ុណ្ណឹង។

**ស៖** តើលោកមាននៅចាំឈ្មោះ ឬឋានន្តរសក្តិទាហានដែលមកពីបន្ទាយទួលពោធិ៍ជ្រៃនោះដែរឬទេ?

**ឆ៖** មិនបានចាំទេ។

**ស៖** លោកក៏បានផ្តល់សក្ខីកម្មថាលោកស្គាល់មនុស្សនៅ-- ប្រហែលជាពី ១០ ទៅ ២០នាក់ក្នុងចំណោម៥០០នាក់ហ្នឹង គឺលោកស្គាល់ដោយផ្ទាល់តែម្តង ដោយសារថាអ្នកទាំងនោះគឺជាអតីតទាហានលន់ នល់ ជាមួយគ្នា តើលោកនឹកមើល តើលោកនៅមានចាំឈ្មោះ និងឋានន្តរសក្តិអ្នកដែលពី ១០ ទៅ ២០ ដែលលោកថាស្គាល់ដោយផ្ទាល់ហ្នឹងបានទេ?

**ឆ៖** ចាំបានតិចណាស់។

**ស៖** ក៏ប៉ុន្តែយ៉ាងហោចណាស់ក្នុងចំណោមហ្នឹងក៏លោកអាចនឹងចាំឈ្មោះ និង ឋានន្តរសក្តិ ក្នុងចំណោមមនុស្ស៥០០នាក់ដែលលោកបានឃើញនោះដែរ?

[១៥:០៥:៣៧]

**ឆ៖** ចាំ ប៉ុន្តែឥឡូវនេះក៏មិនបាននៅនេះដែរ ដូចជាគ្មានឃើញតទៅទៀតទេ។ ខ្ញុំនៅចាំបានមានមិត្តភក្តិខ្ញុំខ្លះម្នាក់គាត់អះអាងថាគាត់នៅនុ៎ងដែរ។ ឡេង កើន អង្គាល់ហ្នឹងគាត់រៀនជាមួយគ្នាពីតូចៗមក

បាទ គាត់ជាកូនទាហាន។ ជួបបានម្នាក់ ឬពីរនាក់ ប៉ុន្តែខ្ញុំបានសួរទៅប្រហែលជាអាចមកច្រើនត្រឹម ២០នាក់ ៣០នាក់ តាមរយៈរបស់មិត្តហ្នឹងឯង។

**ស៖** លោកនិយាយឈ្មោះ ឡេង គើន។ ពេលហ្នឹងគាត់នៅទីនោះដែរ ហើយសព្វថ្ងៃគាត់នៅរស់រានមានជីវិតទេ?

**ឆ៖** ឡើងទៅទួលពោធិ៍ជ្រៃហើយ។

**ស៖** លោកសាក្សី ខ្ញុំសួរថាគាត់នៅរស់ទេសព្វថ្ងៃ?

**ឆ៖** ទៅរៀនសូត្រនៅទួលពោធិ៍ជ្រៃហើយ។

[១៥:០៧:៣១]

**ស៖** ឥឡូវនេះ លោកបានលើកឈ្មោះម្នាក់ដែលមានវត្តមាននៅទីនោះ ហើយលោកក៏បាននិយាយផងដែរថាលោកស្គាល់ដោយស្គាល់ដោយផ្ទាល់តែម្តងពី១០ ទៅ២០នាក់ នៅក្នុងចំណោមមនុស្សប្រហែលជា ៥០០នាក់ ដែលភាគច្រើន គឺថាស្លាប់ហើយ។ ខ្ញុំគិតថា យ៉ាងហោចណាស់ក៏លោកស្គាល់ -- តើលោកអាចស្គាល់មនុស្សណាម្នាក់ដែលមានឋានៈវរសេនីយ៍អីនៅក្នុងចំណោមមនុស្សទាំងអស់ហ្នឹងទេ?

**ឆ៖** មិនស្គាល់ទេ។ វរសេនីយ៍ធំណាស់ អត់ស្គាល់ទេ។

**ស៖** ខ្ញុំដឹងថា ពិបាកនឹងចាំហើយលោកសាក្សី លោកថាលោកស្គាល់ដោយផ្ទាល់ខ្លួនពី ១០ ទៅ ២០នាក់ដែរ។ ហើយជាការពិតនោះ យ៉ាងហោចណាស់ក៏លោកនៅចាំឈ្មោះម្នាក់នៃអតីតមិត្តរួមអាវុធដែលចូលរួមនៅក្នុងកិច្ចប្រជុំនោះដែរ លោកអាចចាំបានទេ?

**ឆ៖** សូមលោកបញ្ជាក់ម្តងទៀតអំពីអ្នករួមប្រជុំ និងអ្នកមកពីទួលពោធិ៍ជ្រៃ។ សូមបញ្ជាក់ម្តងទៀត។

[១៥:០៩:១៥]

**ស៖** ឥឡូវខ្ញុំឈប់សួរលោកអំពីទាហានមកពីបន្ទាយទួលពោធិ៍ជ្រៃហើយ ខ្ញុំនិយាយតែពីមនុស្សពី ១០ ទៅ ២០នាក់ ដែលលោកបានផ្តល់សក្ខីកម្មពីខាងដើមថា លោកស្គាល់ហ្នឹងដោយផ្ទាល់តែម្តង។ សំណួររបស់ខ្ញុំថា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះតែមនុស្សម្នាក់ក៏បានដែរក្នុងចំណោមពី ១០ទៅ ២០នាក់ ដែលស្គាល់ហ្នឹង គឺឈ្មោះនិងឋានន្តរសក្តិរបស់គាត់?

**ឆ៖** សូមសំណួរបញ្ជាក់ម្តងទៀត អំពីទាហានមកពីទួលពោធិ៍ជ្រៃមកប្រជុំនៅសាលាខេត្ត ឬក៏អង្គប្រជុំសាលាខេត្តទាំងមូលដែលខ្ញុំត្រូវបង្ហាញឈ្មោះ។

**ស៖** ខ្ញុំសួរឲ្យលោកសូមប្រាប់ឈ្មោះម្នាក់ឋានៈត្រឹមតែអនុសេនីយ៍ អតីតទាហានលន់នល់ដែលមានវត្តមាននៅក្នុងអង្គប្រជុំហ្នឹងតែម្តង។

**ឆ៖** ដូចខ្ញុំបានជម្រាបជូនហើយ នៅក្នុងអង្គប្រជុំអ្នកដែលមកចូលរួមប្រជុំនៅថ្ងៃនោះ ខ្ញុំបានស្គាល់ពី១០ ទៅ ២០នាក់។ ខ្ញុំបានរៀបរាប់ពីព្រឹកមិញអស់ហើយ មានឧត្តមសេនីយ៍ មានអនុសេនីយ៍ មានវរសេនីយ៍គឺជាអ្នករដ្ឋការរបស់លន់នល់ ក្នុងនោះខ្ញុំបានជម្រាបជូនហើយ ដឹកនាំដោយឧត្តមសេនីយ៍-ត្រី ព្រំ លីហួន, វរសេនីយ៍ឯក នាង ឈុំ, ឆោម ឈុំ ជាច្រើនទៀតដែលខ្ញុំមិនចាំអស់ទេ សុទ្ធតែឋានន្តរសក្តិធំៗប្រមូលជុំគ្នាទាំងអស់។

[១៥:១១:៤៥]

**ស៖** លោកសាក្សី តាមសក្ខីកម្មរបស់លោកគឺថានៅថ្ងៃបន្ទាប់នោះ មានការប្រមូលផ្តុំប្រជុំអតីតទាហានលន់នល់ ហើយក៏ប្រហែលជាមានរដ្ឋការលន់នល់ផងដែរ។ លោកផ្តល់សក្ខីកម្មថា "បាទ មានការប្រជុំបន្ទាប់មកទៀតប្រហែលជា៥០០នាក់ដែរ"។ សំណួរ ដូចគ្នាទៅនឹងសំណួរដែលខ្ញុំសួរមុនពេលឈប់សម្រាក។ តើលោកអាចធ្វើម៉េចបានដឹងថាមានមនុស្សចូលរួមប្រជុំប្រហែលជា៥០០នាក់ទៀតនៅពេលបន្ទាប់មកទៀតនោះ?

**ឆ៖** ការប្រជុំប្រហាក់ប្រហែលគ្នា ចំនួនគឺមិនខុសគ្នាពីលើកមុនៗទេ គឺនៅបន្តបន្ទាប់គ្នាហ្នឹង តាមខ្ញុំស្មានគឺប្រហែលៗគ្នាទេ ព្រោះមនុស្សអស់ហ្នឹងមិនមកពីណាក្រៅទេ នៅតែប៉ុណ្ណឹងរដ្ឋការស៊ីវិល រដ្ឋការទាហាន ហើយនិងចំនួនប្រហែលតែប៉ុណ្ណឹងឯងដែលជួបជុំគ្នា។

**ស៖** លោកកំពុងតែនិយាយថា មនុស្សនៅប្រជុំនៅថ្ងៃបន្ទាប់ហ្នឹង ជាមនុស្សដែលចូលប្រជុំកាលពីថ្ងៃមុនដដែលហ្នឹងឬក៏យ៉ាងម៉េច?

[១៥:១៣:២១]

**ឆ៖** សមាសភាពតែមួយ។

**ស៖** អ៊ីចឹងសុំលោកមេត្តាជួយជម្រាបឈ្មោះម្នាក់មករួមទាំងឋានន្តរសក្តិរបស់គាត់ផងគឺមនុស្សដែលចូលរួមប្រជុំនៅថ្ងៃបន្ទាប់។

**ឆ៖** មនុស្សដដែល សមាសភាពដដែល មកប្រជុំបន្តបន្ទាប់។

**ស៖** លោកសាក្សី នៅថ្ងៃទី២ តើមានអាចមានបញ្ជីឈ្មោះរួមទាំងឋានន្តរសក្តិទោះជាអ្នកប្រជុំពីពេលមុននិងពេលមកដល់ថ្ងៃបន្ទាប់ហ្នឹងជាមនុស្សដដែលក៏ដោយ តើអាចមានបញ្ជីឈ្មោះអ៊ីចឹង ដែល

លោកអាចបញ្ជាក់ឈ្មោះបានទេ?

**ឆ៖** មិនអាចទេ។

**ស៖** បាទ នេះគឺជាសំណួរខ្ញុំព្យាយាមសួរម្តងទៀត។ លោកបានផ្តល់សក្ខីកម្មថាមានមនុស្សចូលរួមប្រជុំនៅថ្ងៃទី២នេះ គឺថាប្រហែលជា៥០០នាក់ ហើយបានចូលទៅជិះរថយន្តធំចាកចេញទៅ ហើយក្រោយមកត្រូវបានគេសម្លាប់ចោល។ ឥឡូវនេះខ្ញុំដឹងច្បាស់ថា អាចមានផលប៉ះពាល់យ៉ាងខ្លាំង។ ដូច្នេះសំណួររបស់ខ្ញុំថាតើយ៉ាងហោចណាស់ លោកអាចចាំឈ្មោះមនុស្សម្នាក់ដែលមានវត្តមានប្រជុំនៅថ្ងៃទី២ហ្នឹងដែរឬទេ?

[១៥:១៥:៤៣]

**ឆ៖** កុំច្រឡំនឹងថ្ងៃទី២។ ទី២ ដែលខ្ញុំអត្ថាធិប្បាយនេះគឺជាពេលចុងក្រោយហើយ ពេលចុងក្រោយហើយ អត់មានក្រោយទីទួលពោធិ៍ជ្រៃ អត់មានទៀតទេ។ ទី១, ទី២ នេះគឺការប្រជុំពុំបានសម្រេចដល់ពេលសម្រេច គឺថ្ងៃក្រោយហ្នឹងឯង ចប់គឺចប់ទួលពោធិ៍ជ្រៃហ្នឹងហើយ អត់មានក្រោយមកប្រជុំទៀតទេ។ ទី១, ទី២ ដែលខ្ញុំអត្ថាធិប្បាយនេះ គឺក្នុងរយៈពេលគេប្រជុំគ្នាទៅរៀនទួលពោធិ៍ជ្រៃនោះឯង។

**ស៖** ខ្ញុំ -- លោកចង់ -- លោកឥឡូវនេះ លោកកំពុងនិយាយថាមានពេលប្រជុំហ្នឹងតែពីរលើកទេ ឬក៏មានដល់ទៅបីលើក?

**ឆ៖** ខ្ញុំចង់បញ្ជាក់។ និយាយដែលខ្ញុំដឹងប្រជុំពីរលើក គឺលើកទី២ចុងក្រោយនេះគឺឡើងទៅទួលពោធិ៍ជ្រៃហ្នឹងឯង។

**ស៖** លោកសាក្សី នៅកិច្ចប្រជុំលើកទី២ ហើយក៏ជាលើកចុងក្រោយហ្នឹង តើលោកមានឃើញអ្នកណាម្នាក់ក្នុងចំណោមមនុស្សប្រហែល៥០០នាក់ហ្នឹង ស្លៀកឯកសណ្ឋានយោធា ទោះជាស្បែកជើងក្តី ទោះបីជាសាក់កាដូក្តី ឬក៏ជាសម្លៀកបំពាក់ឯកសណ្ឋានយោធាក្តី ឬក៏ជាស្ទីមួយដែលសម្គាល់សញ្ញាណជាយោធាហ្នឹង លោកនៅចាំទេ?

**ឆ៖** នៅពេលនោះ ឯកសណ្ឋានយោធាមានពាក់កណ្តាលទៅទៀតណោះ មិនមែនត្រឹមតែទាំងអស់ស៊ីវិលនោះទេ យោធានៅមានពាក់ខោអាវយោធា ចំណែកខាងលន់ នល់ ហ្នឹងនៅមាន។

[១៥:១៧:៥៨]

**ស៖** តើលោកអាចនៅចាំឋានន្តរសក្តិអ្នកណាខ្លះនៅក្នុងចំណោមនេះទេ?

**ឆ៖** ក្នុងចំណោមនោះ គឺគេមិនពាក់សក្តិទេ នៅពេលនោះ គឺគេដោះសក្តិហើយ ប៉ុន្តែខ្ញុំនៅចាំ។

មានឧត្តមសេនីយ៍ ព្រុំ លីហួន ហ្នឹងឯង លោក នាង ឈុំ – *កុងស៊ីញ៉េប៉ូលីទិក* – ដែលខ្ញុំបានរៀបចំព្រឹកមិញហើយ បានជម្រាបជូនហើយ ឋានន្តរសក្តិធំៗហ្នឹងគឺទៅជុំគ្នា។ ខាងផ្នែកស៊ីវិល មានភូឈ្លួយខេត្ត នូសុន។ មន្ត្រីរាជការទាំងអស់បានចូលរួម។

**សៈ** លោកដឹងទេ ហេតុអ្វីបានជាទាហានហ្នឹង ដោះស្លាកសញ្ញា ឬក៏ដោះស័ក្តិហ្នឹងចេញ?

**ធៈ** នេះជារឿងគេ ខ្ញុំមិនបានដឹងទេ។

**សៈ** លោកចាំទេ កាលហ្នឹងលោកមានបានធ្វើសេចក្តីសម្រេចចិត្ត ការសម្រេចចិត្ត ដើម្បីដោះសម្លៀកបំពាក់យោធា ហើយស្លៀកសម្លៀកបំពាក់ស៊ីវិលនោះ។ អ៊ីចឹងនៅថ្ងៃទី២នោះ លោកស្លៀកពាក់ម៉េចដែរ?

**ធៈ** សំណួរនេះ គឺសួរចំពោះរូបខ្ញុំផ្ទាល់ ឬមួយយ៉ាងម៉េច?

[១៥:១៩:៥០]

**សៈ** បាទ សួរទៅលោកផ្ទាល់។ តើពេលហ្នឹង លោកស្លៀកពាក់ឯកសណ្ឋានយោធា ឬក៏លោកស្លៀកសម្លៀកបំពាក់ស៊ីវិលនៅថ្ងៃទី២ហ្នឹង?

**ធៈ** នៅថ្ងៃទី២នេះ គឺខ្លួនខ្ញុំស្លៀកស៊ីវិលហើយ។

**សៈ** បាទពីខាងដើម គឺព្រឹកមិញលោកបាននិយាយថា មានអ្នកយាមប្រហែលជា៥០ ទៅ៦០នាក់គឺជាទាហានខ្មែរក្រហម។ តើអ្នកទាំងនោះមានវត្តមានទាំងនៅថ្ងៃទី១ និងទាំងនៅថ្ងៃទី២ឬ?

**ធៈ** បាទ។

**សៈ** ហើយព្រឹកមិញនេះក៏លោកបាននិយាយ បើខ្ញុំចាំមិនច្រឡំទេ គឺចូលរួមប្រជុំហ្នឹងថ្ងៃទី១ប្រហែលជា២ទៅ៣ម៉ោង។ ចុះថ្ងៃទីពីរវិញប្រជុំអស់រយៈពេលប្រហែលប៉ុន្មានម៉ោងដែរ?

**ធៈ** ប្រហាក់ប្រហែលគ្នា។

**សៈ** ហើយពីខាងដើមនេះលោកក៏បាននិយាយអំពីវត្តមានរបស់ តាសុត។ តើ តាសុត គាត់ចូលរួមប្រជុំទាំងពីរលើកហ្នឹងឬ?

**ធៈ** ជាការពិត។

[១៥:២១:៣២]

**សៈ** ហើយលោកក៏បាននិយាយអំពីមេដឹកនាំកំពូលខ្មែរក្រហមដទៃទៀតមានវត្តមាន។ ម៉េចបានលោកថាមេដឹកនាំជាន់ខ្ពស់ ឬក៏ថាមេដឹកនាំកំពូលអីនេះ? តើមានមូលដ្ឋានអីដែលឲ្យលោកថាមេដឹកនាំ

ធំៗខ្មែរក្រហមហ្នឹង។ លោកអាចប្រើពាក្យហ្នឹងបាន?

**ឆ៖** មិនយល់សំណួរ មិនយល់ សូមម្ដងទៀត។

**ស៖** បាទ លោកនិយាយថា តាសុត គាត់ជាអ្នកនិយាយនៅក្នុងអង្គប្រជុំទាំងពីរលើកហ្នឹង។ គាត់និយាយអំពីការផ្សះផ្សា ការកសាងជាតិជាដើម ។ល។ ហើយលោកក៏បាននិយាយផងដែរ សូមដកស្រង់៖ លោកថាមានមេដឹកនាំធំៗខ្មែរក្រហមដទៃទៀតក៏មានវត្តមានដែរ។ តើធ្វើដូចម្ដេចទើបលោកដឹងថាអ្នកទាំងនោះគឺជាមេដឹកនាំខ្មែរក្រហមធំៗដទៃទៀតនោះ?

[១៥:២២:៤០]

**ឆ៖** តាមខ្ញុំឃើញសកម្មភាពដែលឈរនៅជិត តាសុត ហ្នឹងមានសម្លៀកបំពាក់ឯកសណ្ឋានមានមួកអីត្រឹមត្រូវ គឺប្រហែលជាមេដឹកនាំហើយ តែខ្ញុំមិនស្គាល់ មកជាមួយលោក តាសុត ហ្នឹង។

**ស៖** លោកមានស្គាល់ឈ្មោះមេដឹកនាំធំនុំងដែរ?

**ឆ៖** ខ្ញុំស្គាល់តែ តាសុត មួយគត់។

**ស៖** ហើយលោកក៏បានផ្ដល់សក្ខីកម្មដែលថា តាសុត និយាយអំពីការផ្សះផ្សាជាតិ ការកសាងប្រទេសជាតិ។ តើលោកនៅចាំអ្វីទៀតដែលគាត់និយាយដោយផ្ទាល់ទេ? នៅចាំសម្ដីដែលគាត់និយាយដោយផ្ទាល់មាត់របស់គាត់ខ្លះទៀតទេ?

**ឆ៖** ក្នុងពេលប្រជុំនោះ គឺខ្ញុំក្ដាប់ពុំបានច្បាស់ទេ ប៉ុន្តែក្នុងការរៀនសូត្រនៅ៣ថ្ងៃនោះ គឺគាត់បានឧទ្ទេសនាមច្បាស់។

**ស៖** លោកនិយាយថា ការរៀនសូត្រ៣ថ្ងៃ ឬក៏លោកច្រឡំទេ?

[១៥:២៤:២៩]

**ឆ៖** នៅក្នុងប្រជុំសាលាខេត្តដោយឡែក ខ្ញុំមិនបានទទួលការណែនាំគាត់ទេ ប៉ុន្តែគាត់ទៅបង្រៀននៅពេលដែលរៀនសូត្រ៣ថ្ងៃ នៅសាលាស្វាយហ្លួង។ នៅ -- គេបើកវគ្គបណ្ដុះបណ្ដាល និយាយអំពីទស្សនៈបដិវត្តន៍ និងបដិវត្តន៍នោះ ដែលខ្ញុំនិយាយខាងដើម គឺគាត់ឧទ្ទេសនាមផ្ទាល់។

**ស៖** លោកបានផ្ដល់សក្ខីកម្មពីខាងដើមថា តាសុត ក៏មានវត្តមាននៅក្នុងការប្រជុំទាំងពីរថ្ងៃនោះ បាទ គឺការប្រជុំនៅសាលាខេត្ត។ តើបើ តាសុត មានវត្តមាននៅទីនោះតើគាត់និយាយអ្វីដែរ?

**ឆ៖** គាត់និយាយជុំវិញដែលក្នុងការដែលរួបរួមគ្នា ក្នុងការដែលយើងឯកភាពទៅទទួលអង្គការ។

**ស៖** តាមខ្ញុំចាំគឺគាត់និយាយដល់ទៅបីម៉ោង តើលោកនៅចាំគាត់និយាយអីលើសពីនេះទៀតទេ?

**ឆ៖** មិនលើសទេ មិននិយាយអីក្រៅពីហ្នឹងទេ។

**ស៖** តើមានអ្នកណាក្រៅពីគាត់និយាយទៀតទេ ព្រោះកិច្ចប្រជុំនេះគឺវាលើសពីបីម៉ោងឯណោះ?

**ឆ៖** មានបន្តបន្ទាប់ដែរ ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ទៅលើខ្លឹមសារហ្នឹងទេ។

[១៥:២៥:៥៧]

**ស៖** កិច្ចប្រជុំនៅថ្ងៃទី២ គឺថ្ងៃបន្ទាប់ក្រោយពីបញ្ចប់ទៅ គឺម្នាក់ៗត្រូវបានចាកចេញពីសាលាខេត្តហ្នឹង។ តើលោកអាចរៀបរាប់បានទេ គេចាកចេញពីសាលាហ្នឹង បាទ គេចាកចេញពីច្រកចេញសាលាខេត្តហ្នឹងដោយរបៀបណាទៅ?

**ឆ៖** នៅពេលចប់គឺយើងអាចចេញបាន ពេលចប់ប្រជុំអាចចេញបាន។

**ស៖** បាទ ខ្ញុំយល់ហើយ។ តើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានទេថា នៅពេលបញ្ចប់ការប្រជុំនោះ តើម្នាក់ៗគេទៅឯណា? គេទៅតាមផ្លូវថ្នល់ហ្នឹង? គេទៅកន្លែងណាដែលគេរស់នៅ ឬក៏គេចាកចេញទៅដោយរបៀបណា នៅក្នុងឆ្នាំ១៩៧៥នុ៎ង?

**ឆ៖** នៅក្នុងឆ្នាំ១៩៧៥ កាលពីក្រោយប្រជុំគេចេញធម្មតា ហាក់ពុំដូចជាមានអ្វីភ្ញាក់ផ្អើលនោះទេ ព្រោះកាលគេប្រជុំប្រាប់ យើងពុំបានចាប់អារមម្មណ៍ថាគេមានសភាពការណ៍យកទៅសម្លាប់ដែរ។ ដូច្នេះយើងអ្នកស្ដាប់មិនមានជាការភិតភ័យអីទេ។ ចេញទៅតាមភូមិ តាមអីខ្លួនឯង ធម្មតា។

[១៥:២៨:៥១]

**ស៖** សូមលោកជម្រាបជូនយើងខ្ញុំបន្តិចបានទេថា តើអ្នកប្រជុំហ្នឹងចាកចេញពីអគារហ្នឹង ពីសាលប្រជុំហ្នឹងទៅឯណា? គេទៅឆ្វេង ទៅស្ដាំ ទៅផ្ទះ ឬក៏អ្នកខ្លះនៅត្រេតត្រតនៅខាងមុខអគារប្រជុំហ្នឹង លោករៀបរាប់ឲ្យបានច្រើនជាងនេះបន្តិចបានទេ?

**ឆ៖** សភាពការណ៍នោះ គឺវាមិនបានចាប់អារម្មណ៍ទៅលើការ -- ចាប់អារម្មណ៍ថាគេនៅច្រើន ឬនៅតិចឡើយ ពេលចប់ខ្ញុំក៏ចេញដូចតែគេដូចតែឯងដែរ មិនបានចាប់អារម្មណ៍ទៅលើសភាពការណ៍ជាទូទៅទេ។

**ស៖** ប៉ុន្តែលោកសាក្សីបានបញ្ជាក់នៅព្រឹកថ្ងៃនេះថា ម្នាក់ៗហ្នឹងមានការភ្ញាក់ផ្អើល គេចង់ទៅជិះឡាន ហើយខ្លួនលោកផ្ទាល់ក៏បានព្យាយាមឡើងជិះឡាននោះដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្ណៀម ស្មីត៖**

មិនមែនជាការជំទាស់នោះទេ ប៉ុន្តែខ្ញុំគិតថា ពីដំបូងការសន្ទនា គឺនិយាយអំពីការប្រជុំទី២ ប៉ុន្តែមួយនាទីកន្លងមកនេះ គឺបែរទៅជានិយាយពីរឿងប្រជុំថ្ងៃទី១ ហើយមេធាវីក៏សួរទៅប្រជុំ គាត់ -- សួរគាត់ពីការប្រជុំលើកទី២វិញ។ ដូច្នេះ គឺថាសំណួរចុងក្រោយពីរនេះ គឺថាយោងទៅរកការប្រជុំទី១ ហើយការសួរវិញ គឺផ្អែកលើការប្រជុំថ្ងៃទី២ទេ។ ដូច្នេះធ្វើឲ្យសាក្សីភ័ន្តច្រឡំ។

[១៥:៣០:៥៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ប្រសិនបើមិនច្បាស់ទេ គឺសូមអភ័យទោស គឺថា២០នាទីចុងក្រោយនេះ ខ្ញុំនិយាយអំពីការប្រជុំទី២ទេ។ អ៊ីចឹងលោកសាក្សីសូមលោកឲ្យចាំថា យើងសួរនេះគឺនិយាយពីថ្ងៃទី២ទេ។ តើមានស្ថានភាពដូចម្ដេចនៅថ្ងៃទី២ ហ្នឹងពេលដែលក្រុមមនុស្សដែលលោកនិយាយថា៥០០នាក់ហ្នឹង ចប់ប្រជុំទៅចាកចេញដោយវិធីណា? របៀបដែលចាកចេញហ្នឹងស្ថានភាពម៉េច?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ព្រឹត្តិការណ៍នៅថ្ងៃទី២ គឺការប្រជុំឯកភាពគ្នាហើយ គឺជាការឯកភាពគ្នាឡើងឡានហើយ គឺជាការឯកភាពឡើងឡានដែលឡានតម្រៀបនៅខាងក្រៅ គឺគេនាំឲ្យឡើងឡានហ្នឹងហើយ។ អត់មានចេញទៅណាទេ ឡើងមកឡានហ្នឹងទាំងអស់។ នេះសភាពការណ៍ប្រជុំទី២ជាថ្ងៃបញ្ចប់។ ហើយសូម្បីតែខ្លួនខ្ញុំដែលថាកាក់ឡានហ្នឹង គឺថាខ្ញុំចេញមកក្រៅ គេដើរមកខាងក្រៅនេះ ប៉ុន្តែគេមកមុនខ្ញុំទៀត គេឡើងពេញអស់ហើយ។ ដែលមូលហេតុគេមិនឲ្យយើងឡើងហ្នឹងពីព្រោះវាចង្អៀតពេក។

[១៥:៣២:២៨]

**ស៖** តើលោកនៅចាំទេ តើឡានដែរគេចាំនោះចាំនៅកន្លែងណា? នៅខាងមុខសាលាខេត្ត មន្ទីរសាលាខេត្ត នៅពីមុខអគារលោកទើបបានឃើញនៅក្នុងរូបថត ឬក៏នៅចាំខាងមុខអគារដែលលោកបាននិយាយថា នៅខាងឆ្វេងនោះ?

**ឆ៖** តម្រៀបគ្នានៅខាងមុខមួយខ្សែហ្នឹងទាំងអស់។ មួយបរិវេណសាលាខេត្តហ្នឹងឯង នៅខាងមុខសាលាខេត្តហ្នឹងឯង។

**ស៖** នៅពេលដែលលោកចាកចេញពីអគារនោះ ដូចថាអ្នកទាំងអស់គ្នាត្រូវតែទៅខាងឆ្វេងដែរ។

តើអ៊ីចឹងដែរឬទេ?

**ផ៖** មិនទៅឆ្វេងដែទេ ឡើងបកក្រោយមកវិញ មកឡើងថ្នល់ ចេញមកឡើងថ្នល់។ ចេញមករកឡាន។

**ស៖** សូមលោក -- ខ្ញុំសួរលោកឲ្យបានជាក់លាក់។ តើគេចេញនៅថ្ងៃទី២ មនុស្សទាំង៥០០នាក់ហ្នឹង គឺថាតើពួកគេចេញតាមច្រកណា? ច្រកចេញមួយណាដើម្បីទៅឲ្យដល់ឡានដែលចាំនោះ?

**ផ៖** ច្រកទាំងពីរ។

[១៥:៣៤:១២]

**ស៖** អ៊ីចឹងច្រកដែលលោកឃើញនៅក្នុងរូបថតដែលបញ្ចាំងបង្ហាញហ្នឹងឬទេ?

**ផ៖** ហ្នឹង គឺជាច្រកទី១។

**ស៖** ហើយមនុស្សទាំងនោះក៏ចេញនៅច្រក បាទ ច្រកមួយទៀតដែលលោកបាននិយាយថានៅខាងឆ្វេងដៃ។ តើអ៊ីចឹងឬទេ?

**ផ៖** ពិតមែនហើយ។

**ស៖** តើលោកអាចឃើញថា តើមានមនុស្សប៉ុន្មាននាក់ដែលនៅលើឡានរួចហើយមុនពេល បាទ ដែលថាគេជិះលើរថយន្ត ដែលថាមានឯកសណ្ឋានជាកងទ័ពជាទាហាននៅឡើយ? បាទ ដែលថាតើអ្នកណាខ្លះ ចំនួនប្រហែលប៉ុន្មានដែលនៅលើឡានស្រេចហើយមានឯកសណ្ឋានជាទាហាននោះ?

**ផ៖** នៅលើឡាននីមួយៗ ឯកសណ្ឋាននៃទាហានមានចម្រុះៗ ទាំងស៊ីវិល ចម្រុះទាំងទាហានមិនមែនដោយឡែកៗទេ។ មានតាំងពីកូនសិស្ស មានតាំងពីស៊ីវិល មានតាំងពី -- ប្រជាជនខ្លះក៏អាចមានដែរក៏មិនដឹង ប៉ុន្តែក្នុងនោះតឹនុយទាហាន គឺមានច្របូកច្របល់គ្នាជាមួយស៊ីវិល។

[១៥:៣៦:០៥]

**ស៖** តើលោកអាចធ្វើការប៉ាន់ប្រមាណទេ ដែលថាអ្នកដែលមានឯកសណ្ឋានលាយឡំជាមួយនឹងអ្នកស្លៀកពាក់ស៊ីវិល ថាតើលោកអាចប៉ាន់ប្រមាណបានទេថាតើលាយឡំគ្នាឯកសណ្ឋានទាហាននិងស៊ីវិលហ្នឹងអាចប្រមាណបានទេ? ទាហានប៉ុន្មាន ស៊ីវិលប៉ុន្មាន?

**ផ៖** មិនអាចប៉ាន់ស្មានទេ។

**ស៖** តើលោកអាចនិយាយថាពាក់កណ្ដាលជាទាហាន ពាក់កណ្ដាលជាស៊ីវិលអ៊ីចឹងបានទេ?

**ប្រធានអង្គជំនុំ៖**

កុំបាច់ឆ្លើយអីសំណួរនាំមុខអ៊ីចឹងកុំបាច់ឆ្លើយ! ជាប្រភេទសំណួរនាំមុខ។

[១៥:៣៧:១៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីតើលោកអាចបញ្ជាក់ពីចំនួនភាគរយនៃជនស៊ីវិល ហើយនិងជនយោធានៅលើឡានទាំងអស់នោះបានទេ?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** មិនអាចបានទេ។

**ស៖** ខ្ញុំព្យាយាមម្តងទៀត។ តើលោកអាចនិយាយបានទេថាភាគច្រើនឬភាគតិចដែលស្លៀកពាក់ឯកសណ្ឋានយោធា ដែលនៅលើឡានទាំងអស់នោះ?

**ឆ៖** ជាភាគតិច។

**ស៖** អ៊ីចឹងអ្នកដែលស្លៀកពាក់ជាទាហាននោះគឺភាគតិច តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** តើនៅពេលដែលលោកឈរហ្នឹងនៅពេលដែលលោកឈរនៅច្រកចេញនៅត្រង់ច្រកចេញនៃសាលាខេត្តនោះ ថាតើរថយន្តទាំងនោះចេញសំដៅទៅទិសខាងណា?

**ឆ៖** ទិសខាងកើត បានសេចក្តីថាខាងក្រោមទឹក។

**ស៖** បើសិនជា បើលោកឈរបែរខ្នងទៅខាងអគារហ្នឹងតើឡានទៅខាងឆ្វេងដៃលោក ឬក៏ទៅខាងស្តាំដៃលោក? លោកបែរខ្នងទៅខាងអគារសាលាខេត្ត?

**ឆ៖** បាទ បែរខ្នងទៅអគារសាលាខេត្ត ឡានចេញមកឆ្វេងដៃ។

[១៥:៣៩:៤៨]

**ស៖** លោកបានព្យាយាមឡើងទៅជិះឡានមួយ ប៉ុន្តែលោកមិនជោគជ័យទេ ហើយលោកបានឃើញឡានចាកចេញទៅ។ តើនៅពេលដែលលោកមើលឃើញឡានហ្នឹងគឺមើលឃើញរយៈប៉ុន្មានបានឃើញថាអស់ លែងឃើញឡាន?

**ឆ៖** រយៈពេលមួយម៉ោងជាងដែរ។

**ស៖** ប្រហែលជាលោកសាក្សីមិនស្តាប់ខ្ញុំយល់ច្បាស់ទេ។ នៅពេលដែលឃើញរថយន្តមួយ

ចេញទៅចំពោះមុខលោក តើលោកអាចមើលឃើញរយៈពេលប៉ុនណាបានបាត់ឡានទៅមើលលែងឃើញ?

**ឆ៖** ម្តងទៀត មិនយល់សំណួរទេ។

**ស៖** លោកឈរនៅលើផ្លូវ នៅក្បែរផ្លូវ តើលោកឃើញឡានហ្នឹងរយៈពេលប៉ុនណា? បាទ ដែលមើលតាមឃើញឡានហ្នឹង គឺថាមើលទៅរយៈពេលប៉ុនណាបានបាត់ឡានហ្នឹង ថា១នាទី ២នាទី ៥នាទី ឬក៏ប៉ុន្មាននាទីបានឡាននោះវាបាត់មើលលែងឃើញ?

[១៥:៤១:១៨]

**ឆ៖** ខ្ញុំមិនឈរចាំនៅមុខខ្លោងទ្វារទេ គឺខ្ញុំរត់តាមឡាន។ រត់តាមឡានគេឡើង គេមិនឲ្យឡើង ហើយឡានហួសទៅជាយូរដែរ។ មកមួយទៀត ពីរទៀត ក៏គេមិនឲ្យឡើងដែរ ព្រោះណែនអស់ហើយឡាន។ អ៊ីចឹងរយៈពេលដែលឡានទៅហ្នឹង គឺរយៈពេលយូរដែរ តាំងពី១៥នាទី ទៅ៣០នាទី បានឡានចេញផុត។

**ស៖** តើលោកច្បាស់ពីរឿងហ្នឹងទេ លោកសាក្សី សូមលោករៀបរាប់ពីទីតាំងភូមិសាស្ត្រផ្លូវ តើផ្លូវហ្នឹងយ៉ាងដូចម្តេច ដែលលោកឈរបែរខ្នងទៅ ដែលឡានចេញតាមផ្លូវហ្នឹង តើលោកអាចតាមមើលឃើញបានចម្ងាយប៉ុនណា តាមផ្លូវហ្នឹង សូមលោករៀបរាប់ពីតាំង ភូមិសាស្ត្រផ្លូវ ទីកន្លែង?

**ឆ៖** ផ្លូវចេញពីសាលាខេត្តទៅរកទួលពោធិ៍ជ្រៃ។ បើយើងមិនឡើងឡាន យើងឈរចាំមើលឡានឲ្យរហូត ប្រហែលជា១គីឡូ ១គីឡូម៉ែត្រលែងឃើញឡានហើយ ព្រោះផ្លូវហ្នឹងវាកាច់ដែរ។

[១៥:៤២:៥៨]

**ស៖** បាទ បត់ទៅខាងណា? ដែលលោកនិយាយថា១គីឡូមើលលែងឃើញនោះ វាកាច់កោងនោះ កោងទៅខាងណា?

**ឆ៖** ឈរបែរខ្នងមកសាលាខេត្ត នៅខាងឆ្វេងដៃ។

**ស៖** លោកបានឃើញឡានហ្នឹងទៅខាងឆ្វេង ហើយផុតពី១គីឡូម៉ែត្រទៅមើលលែងឃើញហើយ តើអ៊ីចឹងឬទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** តើត្រូវដែរឬទេ និយាយថាលោកឃើញឡានហ្នឹងទៅខាងឆ្វេង ប៉ុន្តែលោកមិនបានឃើញថាឡានហ្នឹងទៅរហូតដល់ទួលពោធិ៍ជ្រៃទេ បាន១គីឡូបាត់។ តើលោក តើអ៊ីចឹងឬទេ?

**ឆ៖** ពិតមែនហើយ។

**សៈ** លោកគ្រាន់តែឃើញ បាទ ឃើញឡានហ្នឹងត្រូវបានបើកបរចេញទៅ ហើយបត់ទៅស្ដាំក៏បាត់ទៅ។ តើអ៊ីចឹងទេ? បត់ឆ្វេង (សូមកែតម្រូវ)។

**ផះ** ពិតមែនហើយ។

**សៈ** ឥឡូវខ្ញុំនឹងទៅដល់ប្រធានបទចុងក្រោយ។ លោកសាក្សី លោកនិយាយថា៣ថ្ងៃក្រោយពីបានឃើញឡានហ្នឹងចាកចេញទៅ លោកបានជួប ផាត ហើយនិង ដោ។ តើលោកដឹង តើលោកនៅចាំដូចម្ដេចថា៣ថ្ងៃក្រោយពីឡានហ្នឹងបានចាកចេញទៅនោះ?

**ផះ** សំណួរម្ដងទៀត។

[១៥:៤៤:៥៨]

**សៈ** លោកបាននិយាយថា លោកបានជួប ផាត ហើយនិង ដោ ៣ថ្ងៃក្រោយពីលោកបានឃើញឡានចាកចេញពីសាលាខេត្តទៅ។ តើលោកអាចពន្យល់ខ្ញុំបានទេ តើលោកដឹងដូចម្ដេចថា៣ថ្ងៃ តើដឹងដោយរបៀបណាថា៣ថ្ងៃ ទើបបានជួបពីរនាក់ហ្នឹង?

**ផះ** ខ្ញុំបានជួបពីរនាក់នោះ ដោយគេរៀបរាប់ថាគេរត់គេចចេញពីកន្លែងទួលពោធិ៍ជ្រៃ។ តែមួយភ្លែតទេ គ្រាន់តែខ្សឹបប្រាប់ថាគេសម្លាប់។ ដូចក្នុងរបាយការណ៍ស្រេច ដូចខ្ញុំរៀបរាប់ ដល់ក្រោយមកគឺ២សប្ដាហ៍ក្រោយមក គេតាមចាប់សម្លាប់ពីរនាក់នេះឯង។

**សៈ** ប៉ុន្តែខ្ញុំសួរលោកថា ហេតុអីក៏លោកប៊ានអះអាងថា ៣ថ្ងៃក្រោយពីឡានហ្នឹងចេញទៅលោកបានជួបពីរនាក់ហ្នឹង? បាទតើអាចលោកសម្គាល់លើថ្ងៃសុក្រ -- ថាជួប -- ហើយប្រជុំចុងក្រោយនោះប៉ុន្មានថ្ងៃមុនហ្នឹង។ តើលោកអាចបញ្ជាក់ថា៣ថ្ងៃហ្នឹង លោកផ្អែកលើអី?

**ផះ** រយៈពេលនោះគឺមិនហួសពី៣ថ្ងៃហ្នឹងទេ។ ផ្អែកទៅលើឡាន ឡានហ្សីមីដែលចុះទៅហ្នឹងចុះទៅហ្នឹងគឺសម្គាល់ថា ឡានហ្សីមីនៅលុបសាកសព។

[១៥:៤៧:០០]

**សៈ** ឥឡូវនេះលោកបាននិយាយស្មានហើយលោកសាក្សី។ តើលោកអាចបញ្ជាក់ហេតុការណ៍ជាក់ស្ដែងពិតប្រាកដ ដែលលោកនិយាយថា លោកបានឃើញឡានចេញទៅ ហើយ៣ថ្ងៃក្រោយមកលោកថាបានជួប ផាត ហើយនិង ដោ។ តើលោកផ្អែកលើអី? រាប់យ៉ាងម៉េច លើថ្ងៃ ឬក៏លើអ្វី?

**ផះ** ផ្អែកនៅពេលដែលឡានហ្សីមីចុះទៅ។ ដឹងច្បាស់ថា៣ថ្ងៃគឺឡានហ្សីមីចុះទៅហើយ នៅក្នុងថ្ងៃឡានហ្សីមីហ្នឹងឯង គឺខ្ញុំបានជួប។ ដូច្នេះព្រឹត្តិការណ៍ហ្នឹងរួចទៅហើយ សម្លាប់រួចទៅហើយ។ គេមក

ខ្សឹបប្រាប់ខ្ញុំទៀតផង ឲ្យប្រយ័ត្នខ្លួន។

**ស៖** តើ ផាត ហើយនិង ដោ បានវត្តមានបានចូលរួមក្នុងការប្រជុំថ្ងៃទីពីរនោះដែរឬទេ?

**ឆ៖** ខ្ញុំពុំបានឃើញទេ ប៉ុន្តែព្រឹត្តិការណ៍នេះគេបានខ្សឹបខ្ញុំថា គេជាអ្នកជនរងគ្រោះចេញពីកន្លែងនុំង កន្លែងទួលពោធិ៍ជ្រៃហ្នឹង។

[១៥:៤៨:៣៥]

**ស៖** ដូច្នេះលោកមិនចាំថា ផាត និង ដោ ហ្នឹងបានទៅប្រជុំនៅថ្ងៃទី១ ឬថ្ងៃទី២ទេ។ តើអ៊ីចឹងឬទេ?

**ឆ៖** ពិតមែនហើយ មនុស្សច្រើនពេក។

**ស៖** តើលោកនៅចាំពីព័ត៌មានពិស្តារអំពី ផាត ហើយនិង ដោ ប្រាប់លោកអំពីអ្វីដែលពួកគាត់បានឃើញ២ថ្ងៃមុនហ្នឹងទេ?

**ឆ៖** យើងជួបមិនបានបរិយាយប្រាប់គ្នាទេ សុទ្ធតែអ្នកមានខ្លួនឯងទាំងអស់ គ្រាន់តែប្រាប់ថាឲ្យប្រយ័ត្នខ្លួនតែប៉ុណ្ណឹង។

**ស៖** ខ្ញុំស្តាប់លោកបានច្បាស់ហើយ ខ្ញុំយល់ថាសក្ខីកម្មរបស់លោក ហើយថាពួកអ្នកទាំងពីរនាក់នោះបានឃើញការកាប់សម្លាប់ ហើយពីរបីថ្ងៃក្រោយបានជួប ហើយគេអាចប្រាប់លោក គេបានប្រាប់អំពីហេតុការណ៍ដែលបានឃើញពីមុន។ អ៊ីចឹងគេអាចនិយាយប្រាប់លោកច្រើនជាងហ្នឹងទៀត?

**ឆ៖** មិនអាចនិយាយបានច្រើនទេ ព្រោះយើងជាជនរងគ្រោះ មិនអាចជួបជុំគ្នាបានទេ ក្នុងការតាមដាន ក្នុងការគេស៊ើបអង្កេត។

[១៥:៥០:២៧]

**ស៖** លោកសាក្សី លោកទើបតែបានពន្យល់ថាលោកបានទៅប្រជុំដែលមានមនុស្ស ៥០០នាក់ ហើយមានមនុស្សមួយចំនួនគេបញ្ជូនតាមឡានទៅក្រៅ ហើយលោកថា៣ថ្ងៃក្រោយមក ផាត និង ដោ បានប្រាប់លោកថាអ្នកទាំងអស់នោះគេដឹកយកទៅសម្លាប់អស់ហើយ។ សូមលោកព្យាយាមនឹកឡើងវិញថាតើពួកគាត់បានពន្យល់លោកពិស្តារអ្វីទៀតទេ ថាតើ ដោ និង ផាត ហ្នឹងបានឃើញហេតុការណ៍ហ្នឹងយ៉ាងម៉េច អ្នកណារស់ អ្នកណាស្លាប់យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ សាក្សីឆ្លើយគ្រប់គ្រាន់ហើយ តបនឹងសំណួរដែលលោកមេធាវីសួរ។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ លោកប្រធាន។ ខ្ញុំគិតថា ខ្ញុំសូមបញ្ចប់ការតាំងសំណួររបស់ខ្ញុំត្រឹមប៉ុណ្ណេះ សូមអរគុណ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ អាកទួរ វែកគែន ខ្ញុំជាមេធាវីអន្តរជាតិការពារលោក ខៀវ សំផន។ បាទ ខ្ញុំសូមចោទសំណួរសួរ សុំបំភ្លឺមួយចំនួន និងសូមផ្ទៀងផ្ទាត់ជាមួយលោកនូវចំណុចមួយចំនួនដែលខ្ញុំមិនសូវយល់ច្បាស់។ កិច្ចប្រជុំទី១ ថ្ងៃប្រជុំទី១ ដែលលោកបានចូលរួមបន្ទាប់ពីលន់ នល់ ចាញ់ទាហាន។ ប្រជុំនោះពិតជានៅសាលាស្រុកបាកានមែនទេ?

[១៥:៥២:២៥]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** ព្រឹត្តិការណ៍នោះគឺខ្ញុំបានជម្រាបជូន ចេញពីស្វាយដូនកែវមក គឺខ្លួនខ្ញុំផ្ទាល់បានមកជួបព្រឹត្តិការណ៍ប្រជុំនៅស្រុកបាកាននៅពេលវេលាយប់។ ដែលខ្ញុំបានជម្រាបជូនក្នុងកំណត់ហេតុហើយ គឺប្រជុំនៅស្រុកបាកាន។

**ស៖** តើប្រជុំហ្នឹងនៅសាលាស្រុកបាកាន ដែរឬយ៉ាងម៉េច? ហើយបើលោកឆ្លើយថានៅបាកានហ្នឹង តើស្រុកបាកានហ្នឹងនៅកន្លែងណា? នៅក្នុងក្រុងណាដែរ?

**ឆ៖** ស្រុកបាកាន ទីតាំងស្រុកបាកានជាប់នៅថ្នល់ជាតិលេខ៥ ក្នុងស្រុកបាកានហ្នឹងតែម្តងទីតាំងស្រុក។

**ស៖** តើសាលាស្រុកបាកានហ្នឹងនៅក្នុងភូមិមួយ ឬក៏ក្រុងតូចមួយដែលឈ្មោះថា ត្រពាំងជង។ អ៊ីចឹងមែនទេ?

**ឆ៖** នៅខាងលិចត្រពាំងជង ចម្ងាយប្រហែលជា ៣០០ម៉ែត្រ ទៅ៥០០ម៉ែត្រ។

[១៥:៥៤:០៦]

**ស៖** តើកន្លែងហ្នឹងនៅចម្ងាយប៉ុន្មានគីឡូម៉ែត្រពីពោធិ៍សាត់? គឺថាសាលាក្រុង -- សាលាស្រុកបាកានហ្នឹង នៅចម្ងាយប៉ុន្មានពីទីរួមខេត្តពោធិ៍សាត់?

**ឆ៖** ប្រហែលជា ១០-១៥គីឡូម៉ែត្រ។

**ស៖** នៅក្នុងពេលប្រជុំទី១ ដែលប្រព្រឹត្តទៅសាលាស្រុកបាកានហ្នឹង តើលោកនៅតែពាក់ឯកសណ្ឋានទាហានដែរឬទេ?

**ឆ៖** ជម្រាបជូន គឺពេលនោះ ខ្ញុំនៅឯកសណ្ឋានជាទាហាននៅឡើយ។

**ស៖** តើកិច្ចប្រជុំហ្នឹងចាប់ផ្តើមនៅម៉ោងប៉ុន្មាន គឺប្រជុំនៅសាលាស្រុកបាកានហ្នឹង?

**ឆ៖** ការចាប់ផ្តើមនៃការប្រជុំនេះ ខ្ញុំពុំបានដឹងទេ តែខ្ញុំមកធ្វើដំណើរមកដល់ទីនេះ គឺគេប្រជុំទៅហើយ ហើយគេឃាត់ពួកយើងឲ្យចូល។

**ស៖** តើកិច្ចប្រជុំហ្នឹងបញ្ចប់នៅម៉ោងប៉ុន្មានដែរ?

**ឆ៖** ខ្ញុំពុំបាននៅជួបជុំ ប្រជុំចប់ចុងចប់ដើមទេ។ ខ្ញុំបានបញ្ជាក់ជូននៅក្នុងកំណត់ហេតុហើយ គឺខ្ញុំលួនចេញ ដោយបន្តលួនចេញធ្វើដំណើរទៅមុខទៀត។

[១៥:៥៦:២៣]

**ស៖** តើលោករត់ចេញពីកិច្ចប្រជុំហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ជាវិធីលួចរត់ចេញ។

**ស៖** ហេតុអ្វី?

**ឆ៖** មានមូលហេតុដែលយើងដើរមួយថ្ងៃនេះ គេបាញ់រះយើងទៅហើយ បានសេចក្តីថា គេមិនទុកចិត្តយើងទេ។

**ស៖** តើគេបាញ់រះលើលោកនៅពេលដែលលោកប្រជុំនៅសាលាស្រុកបាកាន ឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលដែលខ្ញុំចេញពីស្វាយដូនកែវ។

**ស៖** ប៉ុន្តែហេតុអីក៏លោកលួចលួនរត់ចេញពីពេលប្រជុំហ្នឹង តើមានមូលហេតុអីច្បាស់លាស់ទេនៅពេលដែលលោករត់ លួចរត់ចេញហ្នឹង? ពេលប្រជុំនុំងលោកលួចរត់ហ្នឹង មុនពេលដែលគេប្រជុំចប់ហ្នឹងមានមូលហេតុអីជាក់លាក់ទេ?

[១៥:៥៨:១២]

**ឆ៖** មូលហេតុខ្លួនខ្ញុំផ្ទាល់ គឺចង់ប្រញាប់ធ្វើម៉េចឲ្យបានទៅជួបជុំគ្រួសារ។

**ស៖** បាទ នៅពេលដែលលោកនិយាយថាលោកទៅជួបជុំគ្រួសារនោះ តើលោកចង់ទៅភូមិកំណើតនៅស្វាយល្អុងមែនទេ?

**ឆ៖** សូមទោសស្វាយហ្លួង។

**ស៖** បាទ ខ្ញុំគិតថាខាងបកប្រែជាភាសាបារាំងនោះ ប្រហែលជាមកពីខ្ញុំអានខ្មែរមិនសូវច្បាស់។ អ៊ីចឹងខ្ញុំសួរថាតើលោកទៅស្រុកកំណើតរបស់លោកដើម្បីជួបក្រុមគ្រួសារលោកនោះ អ៊ីចឹងខ្ញុំសួរថាតើ

ស្រុកកំណើតលោកឈ្មោះអីដែរ?

**ឆ៖** ភូមិស្វាយហ្លួង ឃុំបាក់នឹម ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** តើនៅក្នុងភូមិហ្នឹងហើយឬដែលលោកបានទៅបន្ទាប់ពីពេលកិច្ចប្រជុំទី១ ដែលបានប្រព្រឹត្តទៅនៅសាលាស្រុកបាកានហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

[១៥:៥៩:៥២]

**ស៖** តើលោកបានបោះបង់ ឬក៏ដោះឯកសណ្ឋានទាហានចោលហ្នឹងនៅពេលណាដែរ?

**ឆ៖** ស្អែកឡើងនៅពេលរៀបភ្លឺឡើងមកដល់ភូមិ។ ពេលនោះគឺយើងដោះអស់ហើយ អ្វីៗនៅតែខ្លួនទេ។ គឺដោះចោលបណ្តែតទឹកស្ទឹងពោធិ៍សាត់។

**ស៖** ហេតុអ្វីក៏លោកបោះខោអាវលោកចោលទៅក្នុងស្ទឹង ដើម្បីកុំឲ្យគេរកខោអាវទាហានលោកនៅផ្ទះឬក៏យ៉ាងម៉េច?

**ឆ៖** ជាការពិត។

**ស៖** ហេតុអីក៏លោកមិនចង់ឲ្យគេឃើញឯកសណ្ឋានយោធារបស់លោកនៅផ្ទះលោក?

**ឆ៖** បានជាមូលហេតុមិនឲ្យឃើញ តែឃើញយើងមុខជាក្ស័យជីវ៉ាហើយ។

**ស៖** ក៏ប៉ុន្តែនៅថ្ងៃដដែលនោះ កាលនោះលោកទៅពោធិ៍សាត់ នៅក្នុងថ្ងៃដដែលទៅសាលាខេត្តដើម្បីចូលរួមកិច្ចប្រជុំដ៏ធំមួយដែលនៅក្នុងពេលនោះលោកស្គាល់មនុស្សច្រើនដែលមានទាហានច្រើនដែលលោកធ្លាប់ធ្វើការជាមួយ។ អ៊ីចឹងខ្ញុំចង់សួរថាតើនេះមិនមែនជាការគ្រោះថ្នាក់ធំទេឬក្នុងពេលដែលលោកទៅចូលកិច្ចប្រជុំហ្នឹង នៅក្នុងខណៈដែលលោកព្យាយាមលាក់ឯកសណ្ឋានយោធារបស់លោក ហើយលោកបែរជាទៅប្រជុំនៅសាលាខេត្តពោធិ៍សាត់ទៅវិញ។

[១៦:០២:២៧]

**ឆ៖** មិនមែនតែរូបខ្ញុំទេសូម្បីតែភាគច្រើនក៏ត្រូវតែដោះខោអាវយោធាអ៊ីចឹងដែរ ដើម្បីបន្លំខ្លួនជាប្រជាជន។

**ស៖** ប៉ុន្តែត្រឹមហ្នឹងលោកប្រថុយនឹងស្លាប់ព្រោះថាលោកជាទាហាន។ លោកបាននិយាយហើយអំមិញនេះ នៅពេលប្រជុំទីពីរនៅសាលាខេត្តពោធិ៍សាត់ហ្នឹងលោកស្គាល់មនុស្សច្រើននៅទីនោះ។ បើអ៊ីចឹងខ្ញុំមិនយល់ថាហេតុអីបានជាលោកប្រថុយនឹងស្លាប់យ៉ាងដូច្នេះ ព្រោះថានៅក្នុងពេលទន្ទឹមគ្នា មុននឹងបន្តិច

លោកខំលាក់ឯកសណ្ឋានយោធានេះ។

**ឆ៖** ខ្ញុំយល់ពីអ្វីដែលលោកចង់សួរ *(ឮមិនច្បាស់)* ខ្ញុំអត់ទាន់យល់ ហេតុអីបានថាមានគ្រោះថ្នាក់។ អ៊ីចឹងសូមម្តងទៀត។

**សៈ** លោកនៅសមរភូមិគេបាញ់លោក ហើយលោកដកថយហើយលោកលើកទង់ជ័យស ហើយលោកបានចូលរួមកិច្ចប្រជុំមួយនៅសាលាស្រុកបាកាន ហើយលោកបានរត់ចេញពីកិច្ចប្រជុំនោះ ហើយលោកត្រឡប់ទៅភូមិកំណើតរបស់លោក លោកចោលខោអាវទាហានរបស់លោក ចោលទៅក្នុងស្ទឹង ពីព្រោះលោកដឹងថាលោកប្រថុយនឹងគ្រោះថ្នាក់ដល់ជីវិត បើសិនជាគេរកឃើញឯកសណ្ឋានទាហានលន់នល់របស់លោក។ ក៏ប៉ុន្តែទន្ទឹមនឹងនោះទោះបីជាមានការភ័យខ្លាចដូច្នេះក៏ដោយ ក៏លោកនៅតែប្រថុយទៅសាលាខេត្តពោធិ៍សាត់ដើម្បីចូលរួមកិច្ចប្រជុំមួយដែលមានសហការីរបស់លោកទាំងអស់ រួមបញ្ចូលទាំងទាហាន និងជនស៊ីវិលដែលគេអាចប្រាប់ថា លោកជាអតីតទាហាន លន់ នល់ ទៀតផង។ អ៊ីចឹងសំណួរខ្ញុំចង់សួរថា ហេតុអ្វីក្នុងខណៈដែលលោកធ្វើការប្រុងប្រយ័ត្នជាមុន ក៏ប្រុងប្រយ័ត្ន។ ដូច្នេះហើយម៉េចក៏ប្រថុយទៅប្រជុំទី២នៅសាលាខេត្តពោធិ៍សាត់នេះ?

[១៦:០៥:២៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

ខ្ញុំមិនជំទាស់នឹងការសេចក្តីរួមរបស់សំណួរទេ ប៉ុន្តែភស្តុតាងគឺថាសាក្សីមិនបានទៅការប្រជុំទី១ ហើយខុសគ្នាទេ គឺថាការប្រជុំនៅសាលាខេត្តគឺមួយអាទិត្យក្រោយមក។ សំណួរវាអាចនឹងមានភាពពាក់ព័ន្ធ ព្រោះថាអង្គជំនុំជម្រះស្តាប់ហើយគឺថ្ងៃ២៤ ឬថ្ងៃ២៥ ការប្រជុំនៅសាលាខេត្តពោធិ៍សាត់។ រីឯការប្រជុំនៅសាលាស្រុកបាកាននោះ គឺនៅថ្ងៃ១៧ មេសា។ ដូច្នេះ គឺឃ្លាតគ្នាមួយអាទិត្យ។ ដូច្នេះហើយ គឺថាទោះបីជាសំណួរនោះពាក់ព័ន្ធក៏ដោយ ប៉ុន្តែការប្រជុំមិនមែនចំថ្ងៃជាមួយគ្នាទេ។ អ៊ីចឹងចំណុចនេះ មិនពាក់ព័ន្ធ មិនមែនជាភស្តុតាងពាក់ព័ន្ធទេ។

[១៦:០៦:៣៣]

**លោក អាកទូរ វែកគែន៖**

បាទ ខ្ញុំសូមអរគុណដែលបានបំភ្លឺដ៏សំខាន់នេះលោកព្រះរាជអាជ្ញា ក៏ប៉ុន្តែសំណួរខ្ញុំនៅតែមានតម្លៃដដែល។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកបានប្រុងប្រយ័ត្នសម្បើមណាស់ ជៀសវាងកុំឲ្យគេដឹងថាលោកជាអតីតទាហានលន់ នល់។ ហេតុអ្វីក៏លោកនៅតែប្រថុយស្លាប់ទៅប្រជុំនៅសាលាខេត្ត -- ប្រជុំលើកទី២នៅសាលាខេត្តពោធិ៍សាត់នោះ ខ្ញុំចង់ដឹងមូលហេតុហ្នឹង ហេតុអ្វីក៏ប្រថុយដល់ថ្នាក់ហ្នឹង?

**លោក ស៊ុម អាឡាត់៖**

**ឆ៖** មិនមែនជាការប្រថុយប្រថានទេ គឺជាការប្រុងប្រយ័ត្នខ្ពស់បំផុត។ តើគេនិយាយអំពីអ្វី គឺតាមដានព្រឹត្តិការណ៍។

[១៦:០៧:៣២]

**ស៖** អ៊ីចឹង ដូច្នេះគឺថា ដោយសារតែលោកចង់ដឹងខ្លាំងនេះ គឺថាប្រថុយស្លាប់តែម្តង។ លោកចង់និយាយយ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ជាការពិត។

**ស៖** បាទ ខ្ញុំអត់ឮការបកប្រែជាភាសាបារាំងអម្បាញ់មិញ។ លោកសាក្សី លោកអាចឆ្លើយម្តងទៀតបានទេ ព្រោះអត់មានការបកប្រែទៅជាភាសាបារាំង។

**ឆ៖** សុំសំណួរម្តងទៀត។

**ស៖** អ៊ីចឹងខ្ញុំចង់សួរលោកថា ដោយសារតែលោកចង់ដឹងខ្លាំងនោះ អ៊ីចឹងលោកប្រថុយស្លាប់។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយប្រធានបទមួយទៀត នៅពេលដែលសហព្រះរាជអាជ្ញាសួរលោក លោកបានពន្យល់យ៉ាងយូរ ថាលោកជា -- ធ្វើការនៅក្រសួងអប់រំ ហើយបេសកកម្មនៃនាយកដ្ឋានដែលលោកធ្វើការនោះ គឺជាការថែរក្សាបេតិកភណ្ឌខ្មែរ រួមបញ្ចូលទាំងបេតិកភណ្ឌដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ តើខ្ញុំរៀបរាប់នេះត្រឹមត្រូវដែរឬទេ?

[១៦:០៩:២៧]

**ឆ៖** ពុំមានធ្វើការនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះទេ។

**ស៖** បាទ ខ្ញុំនិយាយអំពីសម័យក្រោយសម័យខ្មែរក្រហម?

**ឆ៖** អ៊ីចឹងព្រឹត្តិការណ៍ហ្នឹង ចង់និយាយអំពីឆ្នាំ១៩៧៩ មែនដែរឬទេ?

**ស៖** បាទ ខ្ញុំចង់ដឹងថាតើលោកជាសមាជិកសមាគម ឬក៏អង្គការដែលធ្វើការប្រមូលភស្តុតាងដើម្បីកាត់សេចក្ដីមេដឹកនាំខ្មែរក្រហម?

**ឆ៖** គឺនៅពេលដែលខ្ញុំបានរួចរាល់ពីរបបកម្ពុជាប្រជាធិបតេយ្យហើយ ចូលមកបម្រើការនៅក្នុងក្រោយឆ្នាំ១៩៧៩ គឺរូបខ្ញុំបានចូលបម្រើការងារអប់រំ ហៅថាក្រសួងអប់រំ ជាគ្រូបង្រៀន ផ្នែកខាងគ្រូបង្រៀន។ នៅពេលនោះគេបានឱ្យយើងខ្ញុំទៅបណ្ដុះបណ្ដាលនៅទីក្រុងភ្នំពេញ គឺឯកសារបានឆ្លុះបញ្ចាំងអំពីការប្រមូលភស្តុតាងគ្រប់ខេត្តនីមួយៗ មកធ្វើជាឯកសារ។ ក្នុងនោះដូចជាមានខ្ញុំម្នាក់ជាសមាជិកក្នុងប្រាំនាក់ តំណាងសាក្សីបំភ្លឺនៃការសម្លាប់រង្គាលនៅខេត្តពោធិ៍សាត់។

អ៊ីចឹងខ្ញុំបាននិយាយហើយ សៀវភៅងហ្នឹងគឺមានចងក្រងលើកទី១បំផុត និយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺបើកនៅខេត្តពោធិ៍សាត់ គឺមានឈ្មោះខ្ញុំម្នាក់ គឺឈ្មោះ ស៊ុម អាឡាត់ ហ្នឹងឯង។

[១៦:១២:១០]

**ស៖** តើលើសពីការងារជាអ្នកចាត់ចែងការងារនៅក្នុងការប្រមូលឯកសារហ្នឹង លោកត្រូវបានគេជ្រើសរើសជាសាក្សីដែរឬទេ?

**ឆ៖** ទាំងប្រាំនាក់នេះឯងជាកសិណសាក្សីសម្រាប់ខេត្តពោធិ៍សាត់។

**ស៖** ហើយក្រោយមកទៀត នៅក្នុងឆ្នាំបន្តបន្ទាប់ទៀតហ្នឹងក្នុងការបំពេញការងាររបស់លោក តើលោកធ្លាប់បានទទួលការបញ្ជាពីរដ្ឋាភិបាលឱ្យបំផ្លាញភស្តុតាងមួយចំនួន ដែលមាននៅក្នុងតំបន់របស់លោក ជាភស្តុតាងពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ព្រឹត្តិការណ៍នោះតាមខ្ញុំដឹង ដូចជាមានការឯកភាពពីថ្នាក់លើក្នុងការបំផ្លាញភស្តុតាងនៅតាមភូមិឃុំជាដើម ដូចជាបាត់មួយសា គឺឯកភាពទូទាំងប្រទេស។

**ស៖** បាទ គឺជាការបំផ្លាញឯកសារ ចង់និយាយថាប្រភេទឯកសារភស្តុតាងបែបណាដែរ កាលដែលគេឱ្យបំផ្លាញចោលនោះ?

**ឆ៖** នៅក្នុងឆ្នាំ១៩៧៩ ក្នុងតាមភូមិឃុំនីមួយៗបានប្រមូលអដ្ឋិធាតុធ្វើជាកន្លែងស្តូប តាមឃុំតាមកន្លែងខ្លះ តម្កល់នូវអដ្ឋិធាតុ ប៉ុន្តែក្រោយមកមានគោលការណ៍ដែលត្រូវរំលាយចេញ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានពេលវេលា៥នាទីទៀត ក្នុងការតាំងសំណួរនេះ។

**លោក អាកឡូរ វ៉ែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

[១៦:១៤:៤៥]

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** ក្រៅពីការរើអដ្ឋិធាតុចេញនេះ តើតាមការបញ្ជារបស់រដ្ឋាភិបាលដែលលោកដឹងតាមរយៈការណែនាំរបស់រដ្ឋាភិបាលនេះ បានលោកដឹងថាមានភស្តុតាងមួយចំនួនត្រូវបានបំផ្លាញចោល ភស្តុតាងទាក់ទងនឹងរបបខ្មែរ-- ជាឯកសារផងដែរ មានទេ?

**ឆ៖** ការណែនាំនេះ គឺជា មានជាឯកសារឲ្យណែនាំ គឺបំបាត់ចោល។

**ប្រធានអង្គជំនុំ៖**

សំណួរដូចមិនមែនអ៊ីចឹងទេ។ គេសួរថា តើការបំផ្លាញចោលហ្នឹងមានទាំងភស្តុតាងជាឯកសារដែរឬទេ? ហើយលោកឆ្លើយថា វាមានជាឯកសារក្នុងការណែនាំឲ្យបំផ្លាញភស្តុតាង។ អ៊ីចឹងរឿងហ្នឹងវាផ្ទុយគ្នា ពាក្យខ្មែរហ្នឹងមិនត្រូវគ្នាទេ។ លោកស្តាប់សំណួរឲ្យបាន បើសិនជាស្តាប់សំណួរមិនបានទេលោកអាចសួរឲ្យអ្នកសួរហ្នឹង សួរសំណួរលោកម្តងទៀត។

[១៦:១៦:០០]

**លោក ស៊ុម អាឡាត់៖**

សូមបញ្ជាក់ម្តងទៀត សំណួរ សូមបញ្ជាក់ម្តងទៀត។

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** តើនៅសម័យហ្នឹងឯកសារភស្តុតាងនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបំផ្លាញដែរឬទេ?

**ឆ៖** ឯកសារចងជាឯកសារមិនទាន់ មិនបានបំផ្លាញទេ នៅជាក្នុងឯកសារដដែល។

**ស៖** តើគេបានចេញបញ្ជាឬសេចក្តីណែនាំហ្នឹងនៅពេលណាដែរ លោកអាចជម្រាបជូនតុលាការបានដែរឬទេ?

**ឆ៖** បញ្ជាណែនាំអំពីអ្វី? សូមបញ្ជាក់ម្តងទៀត។

**ស៖** គឺការណែនាំឲ្យលោកបំផ្លាញភស្តុតាង។

**ឆ៖** បំផ្លាញភស្តុតាង បំផ្លាញស្លូបឧក្រិដ្ឋកម្មនៅតាមភូមិឃុំ គឺមានមួយសាទៅហើយ។ បាទ ឯកសារហ្នឹងគឺមិនទាំងឃើញទេ ប៉ុន្តែការដែលធ្វើទៅតាមភូមិនីមួយៗ ហាក់ដូចជាព្រមគ្នា។ ខ្ញុំឃើញគេតម្កល់អដ្ឋិធាតុហ្នឹងហើយ តែក្រោយមកគឺបាត់ទៅវិញ។ ត្រង់នេះការណែនាំពីលើឲ្យធ្វើយ៉ាងម៉េចៗខ្ញុំដូចជាមិនទាន់ចាំបានច្បាស់ដែរ ប៉ុន្តែឯកភាពដូចទៅតាមឃុំ តាមភូមិហ្នឹង គឺមានការៗរើរុះពីរឿងអដ្ឋិធាតុហ្នឹងឯង។

[១៦:១៨:៣០]

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំសូមជម្រាបជូនថា នៅពេលដែលលោកជួបអ្នកស៊ើបអង្កេតរបស់តុលាការនេះ ការណែនាំឲ្យបំផ្លាញឯកសារ ហើយនៅពេលដែលលោកបានទទួលសេចក្តីណែនាំនេះ លោកបានចាប់ផ្តើមបំផ្លាញឯកសារភស្តុតាងហ្នឹង តើលោកចាំទេថាលោកបានជម្រាបអ្នកស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមនេះអ៊ីចឹង?

**ឆ៖** មិនយល់ៗ ខ្ញុំអត់យល់។ សុំម្តងទៀត អត់យល់។

**ស៖** បាទគេប្រាប់ខ្ញុំថាប្រហែលជាការបកប្រែអាចធ្វើឲ្យលោកច្រឡំ អ៊ីចឹងខ្ញុំសូមសួរម្តងទៀត។ នៅពេលដែលលោកជួបអ្នកស៊ើបអង្កេតរបស់តុលាការយើងនេះនៅថ្ងៃទី១០ មិថុនា ឆ្នាំ២០០៨ លោកបានពន្យល់ប្រាប់ពួកគាត់ថារដ្ឋាភិបាលបានចេញសេចក្តីណែនាំឲ្យលោកបំផ្លាញឯកសារ ហើយលោកក៏បានឆ្លើយប្រាប់ពួកគាត់ផងដែរថា លោកបានចាប់ផ្តើមបំផ្លាញឯកសារជាភស្តុតាងនៅពេលនោះ។ តើលោកចាំថាលោកបាននិយាយយ៉ាងដូច្នេះជូនអ្នកស៊ើបអង្កេតដែរឬទេ?

**ឆ៖** ពាក្យច្រឡំប្រហែលជាមួយតឹក--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីអាចដកស្រង់នៅខ្លឹមសារនៃកថាខណ្ឌឬក៏លេខ ERN លេខប៉ុន្មានទៅ ហើយដកស្រង់ខ្លឹមសារនៃកំណត់ហេតុស្តាប់សក្ខីកម្មនេះឲ្យច្បាស់លាស់ ពីព្រោះអាចមានការច្របូកច្របល់គ្នារវាងភស្តុតាងជាឯកសារ។ អំមិញយើងបានបញ្ជាក់រួចហើយ ព្រោះអានេះរឿងធំណាស់ មិនមែនរឿងតូចទេ។ ការប្រើពាក្យពេចន៍មិនត្រឹមត្រូវ គឺនាំឲ្យមានការភ័ន្តច្រឡំ។ លោកអាចដកស្រង់បានទេ ដើម្បីយើងពិនិត្យផ្ទៀងផ្ទាត់នូវអ្វីដែលលោកមានបំណង -- លោកដកស្រង់យកមកសួរសាក្សីនៅ

ពេលនេះ សំណួរចុងក្រោយរបស់លោកនេះ។

[១៦:២១:០០]

**លោក អាកទួរ វ៉េកគែន៖**

បាទ ខ្ញុំមានការលំបាកដូចម្សិលមិញដែរ ដោយសារខ្ញុំពុំមានពេលវេលា ហើយដូចម្សិលមិញ អ៊ីចឹងពិបាក -- គឺជាខ្សែអាត់នៃកិច្ចសម្ភាសន៍របស់លោកសាក្សីនេះ ជាមួយនឹងអ្នកស៊ើបអង្កេតរបស់តុលាការយើង គឺឯកសារ D125/48R ចាប់ពីនាទីទី -- ចាប់ពីម៉ោង០១:៤៨:០៤នាទី។ សាក្សីនិយាយប្រាប់អ្នកស៊ើបអង្កេតថា គាត់បានទទួលសេចក្តីណែនាំពីរដ្ឋាភិបាលឲ្យបំផ្លាញភស្តុតាង ហើយពេលនោះក៏គាត់ចាប់ផ្តើមបំផ្លាញភស្តុតាងជាឯកសារ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប ហើយសូមឲ្យច្បាស់លាស់ណ៎ះ ភស្តុតាងជាឯកសារ គឺជាប្រភេទក្រដាសដែលប្រើប្រាស់ជាផ្លូវការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មួយទៀតវត្ថុតាង មួយទៀតភស្តុតាងណ៎ះ។ ភស្តុតាងវារួមទាំងអស់ បើភស្តុតាងជាឯកសារ គឺជាក្រដាស ឬក៏ឥឡូវនេះ គឺមានច្រើនទៀត ដែលមានដូចជា រូបថត អាត់សំឡេង ឬក៏អីផ្សេងៗតាមការវិវត្តន៍នៃសង្គម។ ប៉ុន្តែយើងសំដៅតែឯកសារក៏អាចយល់បានដែរ។ អ៊ីចឹងវាច្បាស់លាស់ ព្រោះអំមិញគេនិយាយច្បាស់លាស់អំពីការបំផ្លាញភស្តុតាងជាឯកសារ។

[១៦:២២:៤០]

**លោក ស៊ុម អាឡាត់៖**

**ឆ៖** សូមជម្រាបជូនព្រឹត្តិការណ៍នេះ គឺមិនមានឯកសារជាក្រដាសទេ ចង់បញ្ជាក់ថា ពីតឹកតាងអដ្ឋិធាតុ ដែលតម្កល់ៗ ទៅតាមឃុំនីមួយៗ គឺប្រមូលអដ្ឋិធាតុៗដែលដាក់តាំងនោះ គឺជាតឹកតាងគឺមានការបំផ្លាញ មានការបំបាត់ ដោយគេយល់ថា ហាក់ដូចជាស្តែងពេក សូមឲ្យបូជាទៅ។ ហ្នឹងគឺជាតឹកតាងទេ មិនមែនជាឯកសារទេ។ មិនមែនឯកសារចងក្រងជាក្រដាសនោះទេ ឯកសារនៅដដែល មិនដូរទៅណាៗ នៅដដែលៗ ប៉ុន្តែតឹកតាងអដ្ឋិធាតុនៅតាមឃុំនីមួយៗដែលដាក់តាំងសម្ដែង មានក្បាលខ្មោច មានអីអ្ហឹងវាថា ដូចជាវាស្ញប់ស្ញែងពេក គេនាំគ្នា ដោយសារតែព្រះពុទ្ធសាសនា ដោយសារតែប្រជាជនកម្ពុជាជឿទៅលើព្រះពុទ្ធសាសនា គេសុំឲ្យរំលាយទៅៗ ដែលគេធ្វើបុណ្យធ្វើទានទៅ កុំឲ្យឃើញស្ញប់ស្ញែង នាំឲ្យមានមនោសញ្ចេតនាសង្វេគ។ នេះមានការណែនាំមួយធ្វើឲ្យអ៊ីចឹង គឺការបំផ្លាញនេះ គឺមិន

បំផ្លាញឯកសារទេ សូមបញ្ជាក់ជូន គឺតឹកតាង វត្ថុតាងមានជាឆ្អឹងអដ្ឋិធាតុ។ ហ្នឹងទៅតាមដែលខ្ញុំដឹង។

[១៦:២៤:១២]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំមិនអាច--

**ប្រធានអង្គជំនុំ៖**

លោកអស់ពេលហើយ លោកសុំតែមួយត្រឹម២០នាទីទេ យើងឲ្យ២០នាទី ឥឡូវ២៥នាទីហើយ យើងបានរៀនពីភាគីដែលកំណត់អំពីពេលវេលា។ ដូច្នេះ យើងសម្រេចថាបញ្ឈប់ការសួរដេញដោលរបស់លោកត្រឹមនេះ។

លោក ស៊ុម អាឡាត់ ការស្ដាប់សក្ខីកម្មរបស់លោកដល់ពេលនេះចប់ហើយ។

យើងបញ្ឈប់ហើយ ព្រោះយើងឲ្យ២០នាទី លើស៥នាទីហើយ។ យើងសម្រេចឲ្យលោក២០នាទី គឺម៉ោងបួនម្ភៃនាទី។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំកំពុងតែចង់និយាយ ចង់ជម្រាបជូនលោកប្រធានថាខ្ញុំមិនអាចសួរទៅទៀតទេ ដោយសារពេលវេលាវាដល់ម៉ោងហើយ។ ខ្ញុំគ្រាន់តែចង់ជម្រាបជូនលោកប្រធានថា ខ្ញុំអាចសួរវែងឆ្ងាយទៀតទេ ហើយខ្ញុំសូមបញ្ជាក់ថា--

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ប៉ុណ្ណឹងបានហើយ។

**លោក អាកទួរ វែកគែន៖**

*(មិនឮសំឡេង)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លើស៦នាទីហើយ! យើងបានរំឭកលោកឯងរួចហើយ ថានៅសល់៥នាទីទៀតចប់ហើយអស់ពេលហើយ! យើងបានរំឭកមុនទៀត!

លោក ស៊ុម អាឡាត់ ការស្ដាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃកន្លង

មកនេះដោយភាពអត់ធ្មត់ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាពនិងលទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយអង្គជំនុំជម្រះសូមជូនពរលោកជួបតែសំណាងល្អ មានសុខភាពល្អ បានជួបតែសេចក្តីសុខ សេចក្តីចម្រើន។ ហើយសវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះសាលា ដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៨ ខែកក្កដា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការការដាក់ឯកសារគន្លឹះរបស់ភាគីនៅចំពោះមុខអង្គជំនុំជម្រះ ដោយស្តាប់ការកត់សម្គាល់ ឬអត្ថាធិប្បាយដោយក្រុមមេធាវីការពារក្តី នួន ជា លើបណ្តាឯកសារគន្លឹះទាំងឡាយដែលបានដាក់បង្ហាញចំពោះមុខអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅសវនាការចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។ សូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការអង្គជំនុំជម្រះសាលាដំបូង ហើយនិងសាធារណជនជ្រាប។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក ស៊ុម អាឡាត់ វិលត្រឡប់ទៅកាន់ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅឬ ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃច័ន្ទទី០៨ ខែកក្កដា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:២៨ នាទី)*